ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

## សារណា

# ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅ
# កម្រិតមធ្យមសិក្សាទុតិយភូមិ
# (ករណីសិក្សានៅខេត្តស្វាយរៀង)

**The Situation of School Improvement Plan Development**
**At Upper Secondary School in Svay Rieng**

ដោយ / By

**ចៅ ឧស្សាហ៍**

CHAO OUSA

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**
**ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥**

**ឆ្នាំសិក្សា ២០១៦-២០១៨**

**ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

**Supported by Cambodia International Education Support Foundation (CIESF)**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

# សារណា

# ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅ កម្រិតមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សានៅខេត្តស្វាយរៀង)

## The Situation of School Improvement Plan Development At Upper Secondary School in Svay Rieng

ដោយ / By

ចៅ ឧស្សាហ៍

CHAO OUSA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

ឆ្នាំសិក្សា ២០១៦-២០១៨

ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# សារណា

# ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សានៅខេត្តស្វាយរៀង)

## The Situation of School Improvement Plan Development At Upper Secondary School in Svay Rieng


ដោយ / By

ចៅ ឧស្សាហ៍

CHAO OUSA


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

សាស្ត្រាចារ្យណែនាំ: ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

សាស្ត្រាចារ្យជំនួយ: លោក ចាប រតនា

ឆ្នាំសិក្សា ២០១៦-២០១៨


វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា

National Institute of Education ( NIE )

Phnom Penh, Kingdom of Cambodia

គណៈកម្មការវាយតម្លៃនៃការការពារសារណា
សម្រាប់កម្មវិធី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ

វិទ្យាស្ថានជាតិអប់រំ

# សារណា

# ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សានៅខេត្តស្វាយរៀង)

# The Situation of School Improvement Plan Development At Upper Secondary School in Svay Rieng

**សារណានេះ ត្រូវបានឯកភាពដោយ៖**

១.សាស្ត្រាចារ្យណែនាំ:

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

២.តំណាងវិទ្យាស្ថានជាតិអប់រំ:

**បណ្ឌិត នួវ វីរ៉ា**

៣.តំណាងគណៈកម្មការវាយតម្លៃ:

**ឯកឧត្តមបណ្ឌិត ជ័យ សារិន**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា សារណាស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះ ពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ការទទួលសញ្ញាបត្រ នៅវិទ្យាស្ថានឬ សាកលវិទ្យាល័យណាណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ សារណាស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ.........................ខែភទ្របទ ឆ្នាំច សំរិទ្ធស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ហត្ថលេខាបេក្ខជន**

**ចៅ ឧស្សាហ៍**

## **សេចក្តីបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំ**

ក្នុងនាមសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណាស្រាវជ្រាវ សូមបញ្ជាក់ថា បេក្ខជន **ចៅ ឧស្សាហ៍** ពិតជាបានសរសេរសារណាសិក្សាស្រាវជ្រាវខាងលើនេះ ពិតប្រាកដមែន។

ថ្ងៃ.........................ខែភទ្របទ ឆ្នាំច សំរិទ្ធស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

ហត្ថលេខា

**បណ្ឌិត សៀខ សុវណ្ណា**

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់ វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា(Cambodia International Education Support Foundation CIESF) ដែលបានរៀបចំ និងផ្តល់នូវអាហារូបករណ៍ ដល់រូបខ្ញុំបាទបានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា**ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ណែនាំ និងកែលម្អរាល់ចំណុចខ្វះខាតទាំងអស់ដែលកើតមានឡើង ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទពេលនេះទទួលបានជោគជ័យ និងដោយភាពរលូន។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យដឹកនាំរង លោក **ចាប រតនា** ដែលតែងតែជួយណែនាំ ជួយកែសម្រួល និងបង្ហាញផ្លូវដល់ការសិក្សាស្រាវជ្រាវនេះផងដែរ។ ជាមួយគ្នានេះដែរ ខ្ញុំបាទក៏សូមអរគុណដល់មិត្តរួមជំនាន់ទី៥ ទាំងអស់ ដែលតែងតែបានផ្តល់នូវកម្លាំងចិត្ត តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និង ព័ត៌មានដើម្បីជួយឱ្យការសរសេរសារណានេះបានជោគជ័យ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡា និងសាលាវិទ្យាល័យគោលដៅនៅខេត្តស្វាយរៀងទាំងអស់ដែលបានចូលរួមជួយសម្របសម្រួល និងសហការណ៍ក្នុងដំណើរការនៃការចុះប្រមូលទិន្នន័យហើយធ្វើឱ្យការសិក្សានេះទទួលបានជោគជ័យ។

នៅទីបញ្ចប់នេះ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោកសាស្ត្រាចារ្យបណ្ឌិត និងមិត្តរួមថ្នាក់ទាំងអស់សូមឱ្យមានសុខភាពល្អ កម្លាំងមាំមួន ប្រកបការងារទទួលបានជោគជ័យ ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន............ i
សេចក្តីបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំ............ ii
សេចក្តីថ្លែងអំណរគុណ............ iii
មាតិកា............ iv
បញ្ជីរូបភាព............ vii
បញ្ជីតារាង............ ix
មូលន័យសង្ខេប............ xi


## ជំពូកទី១
## សេចក្តីផ្តើម


១.១. លំនាំបញ្ហានៃការស្រាវជ្រាវ............ ១
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ............ ៤
១.៣. គោលបំណងនៃការស្រាវជ្រាវ............ ៥
១.៤. សំណួរស្រាវជ្រាវ............ ៦
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ............ ៦
១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ............ ៦


## ជំពូកទី២
## រំឭកទ្រឹស្តី


២.១. ពន្យល់ពាក្យគន្លឹះ............ ៨
២.២. សមាសភាពសំខាន់ៗក្នុងការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន............ ៩
២.៣. គោលបំណង និងសារៈសំខាន់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន............ ១០
២.៤. ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន............ ១១


## ជំពូកទី៣
## វិធីសាស្ត្រស្រាវជ្រាវ


៣.១. ការជ្រើសរើសសំណាក............ ១៣
៣.២. ឧបករណ៍ស្រាវជ្រាវ............ ១៤
៣.៣. កម្រងសំណួរ និងគោលបំណង............ ១៥
៣.៤. នីតិវិធី និងដំណើរការប្រមូលទិន្នន័យ............ ១៦
៣.៥. ការវិភាគទិន្នន័យ............ ១៨

៣.៥.១ ឧបករណ៍វិភាគទិន្នន័យ.....................................................................១៩
៣.៥.២ ដំណាក់កាលនៃការវិភាគទិន្នន័យ.........................................................១៩
៣.៥.៣ ការវិភាគទិន្នន័យ.............................................................................២០
៣.៥.៤ ការវិភាគទិន្នន័យលើកម្រងសំណួរជាព័ត៌មានផ្ទាល់ខ្លួន..............................២០
៣.៦. ក្រមសីលធម៌នៃការស្រាវជ្រាវ...................................................... ................២៣

## ជំពូកទី៤
## លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

៤.១ ការយល់ដឹងពីទម្រង់ និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍សាលារៀន……….. ………….....២៦
៤.២ ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន....... ................... ...................៣៦
៤.៣ ដំណាក់កាលក្រោយរៀបចំផែនការអភិវឌ្ឍន៍សាលារៀន...... ..................... .............៥០
៤.៤ សំយោគនិន្នន័យកម្រងសំណួរ.............................................................................៦៦

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងសំណូមពរ

សេចក្តីសន្និដ្ឋាន ................................................................................................ ៧៥
សំណូមពរ.................................................................................................................. ៧៦
ឯកសារយោង .......................................................................................................... ៧៩
ឧបសម្ព័ន្ធ ...............................................................................................................៨០

# បញ្ជីរូបភាព


រូបទី ៣.១ ចំនួនអ្នកចូលរួមតាមស្រុក/ក្រុងគោលដៅ ...................................................... ២២
រូបទី ៣.២ ចំនួនអ្នកចូលរួមសរុបបែងចែកតាមតួនាទី ......................................................២៣
រូបទី៤.១ ការយល់ដឹងពីការរៀបចំផែនការនានានៅតាមវិទ្យាល័យគោលដៅ ................. ២៨
រូបទី៤.២ កម្រិតនៃការយល់ដឹងពីខ្លឹមសារ និងសកម្មភាពដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន.......................................................................................................................... ៣១
រូបទី៤.៣ កម្រិតយល់ដឹងទាក់នឹងនឹងផែនការអភិវឌ្ឍន៍សាលារៀនបែងចែកតាមតួនាទីអ្នកចូលរួម ................................................................................................................................ ៣៣
រូបទី៤.៤ ភាគរយអ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន៣៦
រូបទី៤.៥ របៀបនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ..............................................៤០
រូបទី៤.៦ បញ្ហាប្រឈមសំខាន់ៗរបស់សាលារៀន ........................................................... ៤៣
រូបទី៤.៧ ផែនការអភិវឌ្ឍន៍សាលារៀនផ្ដោតទៅលើសកម្មភាពចម្បងៗ......................... ៤៧
រូបទី៤.៨ កម្រិតនៃការពេញចិត្តនឹងផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើត ...........៥០
រូបទី៤.៩ កម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនបន្ទាប់ពីរៀបចំ.........................៥៤
រូបទី៤.១០ កម្រិតនៃភាពពេញចិត្តទៅលើលទ្ធផលនៃការអនុវត្តផែនការក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ.......................................................................................................................... ៥៧
រូបទី៤.១១ ការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ..................................៦១
រូបទី៤.១២ ភាពឆ្លើយតបរវាងថវិកាដែលសាលារៀនទទួលបានពីរដ្ឋ និងតម្រូវការជាក់ស្ដែងរបស់សាលារៀន ..................................................................................................... .៦២
រូបទី៤.១៣ ការដោះស្រាយរបស់សាលារៀនពេលថវិកាដែលទទួលបានពីរដ្ឋមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង ....................................................................................................៦៤
រូបទី ៤.១៤ កម្រិតនៃការប្រជុំផ្សព្វផ្សាយបង្ហាញខ្លឹមសារ និងសកម្មភាពដែលគ្រោងអនុវត្តនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធ ...........................................................៦៦

# បញ្ជីតារាង

តារាងចំនួនវិទ្យាល័យ ចំនួនបុគ្គលិកអប់រំ ចំនួនសំណាកជ្រើសរើស..............................១៤

# មូលន័យសង្ខេប


ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការអភិវឌ្ឍន៍សាលារៀនដើម្បីឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យសាលារៀន និងនាយកសាលាល្អ តាមរយៈការជំរុញឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីផលិតផែនការដែលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែង ព្រមទាំងចូលរួមចំណែកក្នុងការធ្វើឱ្យសាលារៀនមានការផ្លាស់ប្តូរីកចម្រើន និងលើកកម្ពស់ការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ក្នុងន័យនេះ យើងនឹងធ្វើការសិក្សាស្រាវពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តស្វាយរៀង។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីសិក្សាពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងសិក្សាពីកម្រិតនៃការពេញចិត្តលើផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំ។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលតាមរយៈការប្រើប្រាស់កម្រងសំណួរសួរទៅគណៈគ្រប់គ្រងសាលាចំនួន១៨នាក់ មន្ត្រីរដ្ឋបាល/គណនេយ្យចំនួន៨នាក់ ថ្នាក់ដឹកនាំក្រុមបច្ចេកទេសចំនួន៥៦នាក់ និងលោកគ្រូ អ្នកគ្រូចំនួន២២៩នាក់ ដែលមកពីវិទ្យាល័យចំនួន០៨ ក្នុងខេត្តស្វាយរៀង។ ដើម្បីសិក្សាទៅលើប្រធានបទមួយនេះឱ្យបានជោគជ័យ យើងបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពីរបែបគឺ បែបបរិមាណ និងបែបគុណភាព ហើយវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធីExcel និង SPSS។

តាមរយៈការសិក្សាបានបង្ហាញឱ្យឃើញថា ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន មិនត្រូវបានរៀបចំស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡានោះទេ ដោយភាគច្រើនត្រូវបានរៀបចំឡើងដោយមិនមានតម្លាភាព គណនេយ្យភាព និងមានការចូលរួមទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ។ ជាទូទៅ ផែនការអភិវឌ្ឍន៍សាលារៀន៩០%ត្រូវបានរៀបចំដោយភាគីមួយចំនួនតូចតែប៉ុណ្ណោះ មិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់អ្នកពាក់ព័ន្ធដទៃទៀត ដែលធ្វើឱ្យខ្វះការគាំទ្រ និងកិច្ចសហការពីអ្នកពាក់ព័ន្ធនានា។ ការយល់ដឹងនៅមានកម្រិត និងធ្វើឱ្យការអនុវត្តមិនបានសម្រេចជោគជ័យពេញលេញ ពិសេសវាជាមូលហេតុចម្បងដែលធ្វើឱ្យបែកបាក់សាមគ្គីភាពផ្ទៃក្នុង និងការកើនឡើងនូវទំនាស់ផលប្រយោជន៍។ កត្តាទាំងនេះជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ដំណើរការអភិវឌ្ឍន៍ និងកែលម្អសាលារៀន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានរកឃើញខាងលើ សំណូមពរមួយចំនួនត្រូវបានដាក់ចេញស្នើដល់ស្ថាប័ន និងភាគីពាក់ព័ន្ធមួយចំនួន។ សម្រាប់ថ្នាក់ដឹកនាំវិទ្យាល័យគួរតែផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួម ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងអនុវត្តឱ្យបានពេញលេញទៅតាមនីតិវិធីដែលក្រសួងបានកំណត់ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលា-រៀន ការអនុវត្ត និងលទ្ធផលសម្រេចបានដល់អ្នកពាក់ព័ន្ធទាំងអស់។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងក្រុមតាមដានត្រួតពិនិត្យ និងបណ្តុះបណ្តាលថ្នាក់ស្រុក គួរតែចូលរួមតាមដានត្រួតពិនិត្យពីដំណើរការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនឱ្យបានច្បាស់លាស់ និងផ្តល់វគ្គបំប៉នសមត្ថភាពបន្ថែមពីនីតិវិធីក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។ អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមជាមួយអ្នកពាក់ព័ន្ធ និងធ្វើការសិក្សាស្រាវជ្រាវនៅខេត្តផ្សេងទៀត៕

## Abstract

Ministry of Education, Youth and Sport (MoEYS) has paid close attention to improving school to meet the criteria of good school and director by pushing each school to prepare school improvement plan (SIP) with broad participation from all relevant stakeholders in order to produce SIP to meet the real challenges and specific need and participate in making school be progressive and improving the provision of educational service with quality and efficiency. With this regards, the study of the situation of SIP organization for upper secondary school will be proposed and examined. The objective of this research is to study the situation of SIP organization and the satisfaction level of prepared SIP.

Data of this research was collected by the use of questionnaire providing to 18 members of school management committee, 08 admin/accountant officers, 56 leaders of technical group and 229 teachers from 08 high schools in Svay Rieng province. In order to make research get successful, we use two analysis methods like qualitative and quantitative analysis by using Excel and SPSS.

Based on the result of researching, we found that the process of SIP development was not followed the guideline and instruction of MoEYS which most of them were organized without transparency, accountability and broad participation from all relevant stakeholders. In general, 90% of SIP was prepared by minorities of people which causing the proposed plan not to meet the real facing issues and specific needs of other relevant stakeholders leading to the lack of supports and cooperation, limited understanding of school improvement and unsuccessful plan implementation especially the break of internal solidarity and the increase of benefit conflict. Those factors have negatively affected to the process of school improvement and development.

In order to deal with the above facing issues, the suggestion to relevant institutes is very crucial that each member of School Management Committee should provide the opportunities to all relevant stakeholders to participate broadly in preparing SIP and completely follow the guideline and instruction of MoEYS and disseminate widely to them about proposed plan, implementation and achievement. As for Provincial department of Education, Youth and Sport and District Training and Monitoring Team (DTMT), they

should join the process of monitoring and evaluation of organization and implementation of SIP and provide ongoing capacity building training. And for next researchers, they should extent limitation, target group and areas.

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងឆ្នាំ ២០១៥ និងអនុវត្តការធ្វើមូលនីយដ្ឋាននីយកម្មដើម្បីឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការជាក់ស្តែងរបស់ប្រទេស។ គោលដៅទី៤នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានផ្តោតលើការអប់រំ ដោយធានាការអប់រំបរិយាប័ន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (UNESCO, 2015)។ ការអប់រំបែបបរិយាប័ន្នបានផ្តោតជាសំខាន់ដល់ការលើកកម្ពស់ការអប់រំ តាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងការអភិវឌ្ឍ ដោយមិនប្រកាន់និន្នាការនយោបាយ ជាតិសាសន៍ វប្បធម៌ សាសនា វណ្ណៈសង្គម...ឡើយ។ ជាមួយគ្នានេះ និន្នាការថ្មីក្នុងតំបន់ដែលបានរួមគ្នាបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ក្នុងឆ្នាំ២០១៥ បានអនុញ្ញាតឱ្យមានលំហូរពលករជំនាញដោយសេរី ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ដែលជាកត្តាជំរុញឱ្យមានការប្រកួតប្រជែងមូលធនមនុស្ស និង ការផ្តោតយកចិត្តទុកដាក់ខ្លាំងលើការអភិវឌ្ឍវិស័យអប់រំ (The ACE blueprint 2008-2015)។ សម្រាប់ប្រទេសកម្ពុជា រាជរដ្ឋាភិបាល ក៏បានយកចិត្តទុកដាក់ខ្លាំងក្លាផងដែរដល់ការអភិវឌ្ឍន៍វិស័យអប់រំតាមរយៈការធ្វើកំណែទម្រង់អប់រំនានា សំដៅធានាដល់ការផលិតធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងគោលដៅអភិវឌ្ឍន៍ប្រទេសក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ (រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រជាតិ ២០១៤-២០១៨) ដើម្បីលើកកម្ពស់វិស័យអប់រំ រាជរដ្ឋាភិបាលបានបង្កើនថវិកាជាតិសម្រាប់ក្រសួងអប់រំជាបន្តបន្ទាប់ពី១៥.៥២% ក្នុងឆ្នាំ២០១៣ ដល់១៨.៣០%ក្នុងឆ្នាំ២០១៧ (ក្រសួងអយក ស្ថិតិអប់រំ និងសូចនាករ ២០១៧)។ ទន្ទឹមនឹងនេះ ក្រសួងអប់រំក៏បានរៀបចំ និងកសាងនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនានា និងបានអនុវត្តនូវសកម្មភាព និងកម្មវិធីជាច្រើន ដោយផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការលើកកម្ពស់សិទ្ធិកុមារ ការថែទាំសុខភាព និងសុវត្ថិភាព បង្កឱកាសគ្រប់បែបយ៉ាងដើម្បីជួយឱ្យកុមារ

គ្រប់រូបបានចូលរៀន ប្រកបដោយសមធម៌ និងគុណភាព។ ជាមួយគ្នានេះ ក្រសួងបានបន្តពង្រឹងនូវយុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីដើម្បីធានាបាន នូវការដឹកនាំគ្រប់គ្រងសាលារៀន ការរៀន បង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។

វិស័យអប់រំ ត្រូវបានចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយសាលារៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតធនធានមនុស្ស ឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពេញលេញប្រកបដោយសក្តានុពលសម្រាប់បម្រើដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស គេត្រូវការសាលារៀនជាចាំបាច់ ហើយដើម្បីពង្រឹងសេវាអប់រំរបស់ខ្លួនស្របតាមការវិវត្តសង្គម និងភាពរីកចម្រើននៃសកលលោក ការកែលម្អ និងអភិវឌ្ឍន៍សាលារៀនចាំបាច់ត្រូវអនុវត្តជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ បើមិនមានផែនការអភិវឌ្ឍន៍ទេ សាលារៀនមិនអាចផ្លាស់ប្តូររីកចម្រើនបានទេ ព្រោះផែនការជាផែនទីបង្ហាញផ្លូវថាតើគួរដឹកនាំសាលារៀនឆ្ពោះទៅគោលដៅណាមួយស្របតាមគោលនយោបាយជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ នៅដំណាក់កាលអនុវត្តគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា (EFA) ឆ្នាំ២០០០ ដល់២០១៥ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ខ្លាំងក្នុងការកសាងសាលារៀនឱ្យបានច្រើនដើម្បីបង្កិតសេវាអប់រំឱ្យទៅជិតសិស្សានុសិស្សនៅទូទាំងប្រទេស ពិសេសនៅតាមតំបន់ជនបទ និងយកចិត្តទុកដាក់ជំរុញដំណើរការអភិវឌ្ឍសាលារៀន។ តាមរយៈការអនុវត្តគោលដៅនេះ សាលារៀនបានកើនឡើងពីចំនួន ៦,៩០១នៅឆ្នាំ២០០១ ដល់១៤,២៩៨ នៅឆ្នាំ២០១៧ (ក្រសួងអយក ស្ថិតិអប់រំ និងសូចនាករ-២០១៧) ហើយគោលនយោបាយស្តីពីការអភិវឌ្ឍកម្រងសាលារៀន និងឯកសារណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានបង្កើតឡើងសម្រាប់សាលារៀននានានៅទូទាំងប្រទេស យកទៅអនុវត្ត។ តាមរយៈឯកសារគតិយុត្តទាំងនេះ សាលារៀននីមួយៗបានរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍សាលារៀនដែលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ការដឹកនាំអនុវត្ត និងតាមដាន វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការ។ ផែនការអភិវឌ្ឍន៍សាលារៀនផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពសាលារៀនក្នុងការផ្តល់សេវាកម្មអប់រំដល់សិស្សានុសិស្ស ពោលធ្វើ

ឱ្យសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស ហើយនាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀបចំឱ្យមានការផ្លាស់ប្តូរនេះ។ ក្នុងន័យនេះ នាយកសាលារៀនត្រូវបានចាត់ទុកជាអ្នកមានសក្តានុពល និងជាកូនសោ គន្លឹះក្នុងការបង្កើនគុណភាពអប់រំ ហើយជាអ្នកកំណត់នូវចក្ខុវិស័យ និងបេសសកម្មនៃផែនការរបស់សាលារៀន។ នាយកសាលារៀនត្រូវមានកិច្ចសហការជិតស្និទ្ធ ជាមួយមាតាបិតា អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការរៀបចំផែនការជាត្រីវិស័យគោល សម្រាប់អនុវត្តឈានទៅរកការអភិវឌ្ឍសាលារៀនបណ្តើរៗស្របតាមមជ្ឈដ្ឋានរស់នៅ តាមបរិបទសង្គម និងការវិវឌ្ឍន៍ តាមភាពជឿនលឿនលើវិស័យអប់រំសកលលោកផងដែរ។ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនបានជួយដល់ការអនុវត្តការងារដឹកនាំ និងគ្រប់គ្រងសាលារៀនដោយផ្តោតលើលទ្ធផល ដើម្បីធ្វើឱ្យសាលារៀនទទួលបាននូវការគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។ ម៉្យាងទៀតតាមរយៈការបំពេញការងាររបស់ខ្លួន សាលារៀនអាចធ្វើការឆ្លុះបញ្ចាំងទៅលើ គោលនយោបាយ សេចក្តីណែនាំ ឬលិខិតបទដ្ឋាននានា ដើម្បីប្រាកដថា ការដឹកនាំ និងគ្រប់គ្រងសាលារៀនស្ថិតនៅកម្រិតណា ហើយអាចឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ក្រសួងបានកម្រិតណាដែរ។ លើសពីនេះទៅទៀត ការរៀបចំរចនាសម្ព័ន្ធនេះ គឺរៀបចំឡើងដើម្បីពង្រឹងប្រព័ន្ធធ្វើការរួមគ្នា ក្នុងសាលារៀន និងសហគមន៍ដែលអាចអនុវត្តឱ្យបានទាំងគុណភាព និងប្រសិទ្ធភាពស្របទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការអភិវឌ្ឍសាលារៀនមួយប្រកបដោយនិរន្តរភាពបាន ទាមទារឱ្យអ្នកដឹកនាំ និងគ្រប់គ្រងមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើនឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដូចជា៖ សិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅមូលដ្ឋានក្នុងការអនុវត្តសកម្មភាព ដោយត្រូវធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីឱ្យដឹងពីចំណុចល្អ និងអ្វីត្រូវកែលម្អ រួចធ្វើផែនការអភិវឌ្ឍន៍សាលារៀនដោយផ្អែកលើចំណុចកែលម្អ និងធ្វើការពិនិត្យតាមដាន វាយតម្លៃសាលារៀនក្នុងឆ្នាំសិក្សានីមួយៗ (ក្រសួងអយក ឯកសារណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន-២០១៧)។ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននឹងមិនមានលក្ខណៈល្អប្រសើរ និង

ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀនបានទេ បើខ្វះការចូលរួមពីភាគីពាក់ព័ន្ធនានានោះ។ ការចូលរួម និងកិច្ចសហការទាំងនេះ វាមានសារៈសំខាន់ជាខ្លាំងក្នុងការប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើការវិភាគ និងរៀបចំផែនការមួយប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡាក៏បានចេញប្រកាសស្តីពីការកំណត់គោលការណ៍ លក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអបពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំ ដោយកំណត់លក្ខណវិនិច្ឆ័យនៃការវាយតម្លៃលើការរៀបចំផែនការ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដែលជាសូចនាករសំខាន់មួយក្នុងចំណោមសូចនាករដទៃទៀតក្នុងការវាយតម្លៃនាយក នាយិកាសាលារៀនល្អ (ក្រសួងអយក ប្រកាសលេខ៧៦១-២០១៦) និងចេញអនុក្រឹតស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាកម្មគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដោយកំណត់លើការបើកទូលាយឱ្យមានការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀនជាលក្ខណវិនិច្ឆ័យសំខាន់មួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់ដែលបញ្ជាក់ពីស្តង់ដារគំរូរបស់សាលារៀនល្អ (រាជរដ្ឋាភិបាល អនុក្រឹតលេខ៥៤-២០១៨)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅ គេទទួលស្គាល់ថាស្ថាប័នមួយដែលមានប្រសិទ្ធភាពបំផុតគឺជាស្ថាប័នដែលផ្តោតការយកចិត្តទុកដាក់ខ្លាំងពីគោលបំណង និងគោលដៅរបស់ស្ថាប័នខ្លួនជាក់លាក់ ដូចជាផ្តោតលើការចូលរួមរៀបចំផែនការប្រកបដោយកិច្ចសហការគ្នាល្អ និង ទូលំទូលាយពីអ្នកពាក់ព័ន្ធនានា ព្រមទាំងកៀរគការគាំទ្រដើម្បីសម្រេចគោលបំណង និងគោលដៅទាំងនោះ។ ដូចគ្នានេះដែរ ការអភិវឌ្ឍន៍សាលារៀនក៏ចាំបាច់ឱ្យមានការចូលរួម និងគាំទ្រ ដើម្បីឱ្យដំណើរការផ្លាស់ប្តូររីកចម្រើនប្រកបដោយគុណភាព និងប្រសិទ្ធភាព។ សាលារៀននីមួយៗត្រូវមានការចូលរួមពីសំណាក់ដៃគូ និងអ្នកពាក់ព័ន្ធនានា ដូចជា៖ មាតាបិតា អាណាព្យាបាលសិស្ស អាជ្ញាធរមូលដ្ឋាន និងសហគមន៍...ជាដើម ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ដើម្បីឱ្យមានការឯកភាពគ្នាលើយុទ្ធសាស្ត្រនៃការអនុវត្ត និងឆ្លើយតបសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗ។ ដូច្នេះការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនជាគន្លឹះសំខាន់ ក្នុង

ការអភិវឌ្ឍន៍វិស័យអប់រំដែលជាគោលបំណងរបស់គ្រប់ភាគីទាំងអស់ចង់បាន។ កង្វះការចូលរួមពីអ្នកពាក់ព័ន្ធ ជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដែលវាអាចធ្វើឱ្យផែនការដែលបង្កើតឡើងនោះ មិនបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមសាលារៀន ឬឆ្លើយតបតែទៅនឹងសេចក្តីត្រូវការ និងផលប្រយោជន៍របស់ភាគីណាមួយប៉ុណ្ណោះ និងនាំឱ្យកង្វះការចូលរួមគាំទ្រដែលធ្វើឱ្យការអនុវត្តផែនការមិនទទួលបានជោគជ័យ។

គោលបំណងនៃផែនការអភិវឌ្ឍសាលារៀនគឺ ធ្វើឱ្យមានការផ្លាស់ប្តូរ និងការច្នៃប្រឌិតសម្រាប់ការកែលម្អសាលារៀន ដែលវាជាដំណើរការផែនការដ៏វែងឆ្ងាយមួយ។ ក្នុងន័យនេះការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ត្រូវធ្វើជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំដែលមានគោលបំណងច្បាស់លាស់។ យោងតាមលោកប៉ែល (ឆ្នាំ១៩៩៨) គោលបំណងនៃការរៀបចំផែនការអភិវឌ្ឍន៍គឺដើម្បីជួយដល់សាលារៀនក្នុងការផ្លាស់ប្តូរប្រកបដោយភាពជោគជ័យ ដែលគុណភាពនៃការបង្រៀន និងស្តង់ដារនៃការសិក្សាត្រូវបានធ្វើឱ្យប្រសើរឡើង។ ចំណែកឯលោកJones (ឆ្នាំ ១៩៩៨) ចាត់ទុកការធ្វើផែនការសាលារៀនជាវិធីសាស្រ្តមួយដែលត្រូវបានគេអនុម័តយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងការផ្លាស់ប្តូរដែលបានគ្រោងទុក និងត្រូវបានគាំទ្រជាយន្តការសម្របសម្រួលមួយដើម្បីជួយដល់ការអនុវត្តនវានុវត្តន៍ជាច្រើនដែលមាននៅក្នុងប្រព័ន្ធអប់រំ។ ដំណើការកសាងផែនការអភិវឌ្ឍន៍ត្រូវការការយល់ដឹងជ្រៅជ្រះអំពីអ្វីដែលជាគោលបំណងរបស់វា និងរបៀបដែលវាត្រូវធ្វើដើម្បីសម្រេចបានផែនការដ៏ល្អមួយ។ ជាទូទៅយើងសង្កេតឃើញថា សាលារៀនជាច្រើនមិនទាន់ធ្វើការកែលម្អ និងអភិវឌ្ឍន៍ឱ្យបានល្អប្រសើរ ស្របតាមស្តង់ដារសាលារៀនសតវត្សរ៍ទី២១នៅឡើយទេ ដោយសារកង្វះធនធានទាំងធនធានថវិកា សម្ភារៈ និងធនធានមនុស្ស ពិសេសកម្រិតយល់ដឹងទូលំទូលាយនៃការរៀបចំផែនការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ ដោយសង្កេតឃើញនូវបញ្ហានានាជាច្រើនទាក់ទងនឹងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ទើបមានការលើកយកប្រធានបទស្រាវជ្រាវមួយមកសិក្សាគឺ "**ស្ថានភាពនៃ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ**"

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដើម្បី៖

- សិក្សាពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- សិក្សាពីកម្រិតនៃការពេញចិត្តលើផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំ

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើសំណួរស្រាវជ្រាវចំនួន០២ ត្រូវបានលើកឡើង៖

- តើស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង មានលក្ខណៈយ៉ាងដូចម្តេច និងជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?
- តើកម្រិតនៃការពេញចិត្តលើផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំបានកម្រិតណា?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អាចឆ្លើយតបទៅនឹងកម្មវត្ថុដែលបានកំណត់ខាងលើ ព្រមទាំងអាចរួមចំណែកដល់ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់ផងដែរ សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តបន្ទាប់ទៅមុខទៀត ដែលពាក់ព័ន្ធ ទៅនឹងប្រធានបទខាងលើ ហើយមានការស៊ីសង្វាក់ទៅនឹងស្ថានភាពបច្ចុប្បន្ន។ លទ្ធផលស្រាវជ្រាវនឹងប្រាប់ផងដែរដល់អ្នកអប់រំដើម្បីពង្រឹង និងកែលម្អការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន**" ធ្វើឡើងផ្តោតលើសាលាវិទ្យាល័យនៅក្នុងខេត្តស្វាយរៀង ដោយជ្រើសរើសវិទ្យាល័យចំនួន៨ ក្នុងចំណោមវិទ្យាល័យសរុបទាំង១៩។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយជ្រើសរើសវិទ្យាល័យមួយក្នុង១ស្រុក និងក្រុងដែលខេត្តស្វាយរៀងទាំងមូលមាន០៦ស្រុកគឺ ស្រុកស្វាយជ្រំ ស្វាយទាប រមាសហែក កំពង់រោទិ៍ រំដួល និងចន្ទ្រា ហើយក្រុងមាន០២គឺក្រុងស្វាយរៀង និងក្រុងបាវិត។ ចំពោះសាលារៀនដែលបានធ្វើការជ្រើសរើសយកមកសិក្សាស្រាវជ្រាវ មានប្រភេទសាលានៅទីប្រជុំជន និងសាលានៅតំបន់ជនបទ ដើម្បីធ្វើការប្រៀបធៀបគ្នាលើ

ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ។ ដូច្នេះ មិនទាន់បានគ្របដណ្តប់នៅទូទាំងប្រទេសនោះទេ ដោយសារពេលវេលារបស់អ្នកស្រាវជ្រាវមានកំណត់ និងលទ្ធភាព។

# ជំពូកទី២
# រំឭកទ្រឹស្តី

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១. ពន្យល់ពាក្យគន្លឹះ

ផែនការគឺជា មធ្យោបាយដែលមានលក្ខណៈជាប្រព័ន្ធមួយដើម្បីដោះស្រាយបញ្ហានាពេលអនាគត។ មធ្យោបាយជាប្រព័ន្ធមានន័យថា ធ្វើជាជំហានៗ ដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពីធនធាន និងពេលវេលាដែលមាន។ ដោះស្រាយបញ្ហាគឺធ្វើឱ្យមានការប្រែប្រួល និងមានលក្ខណៈកាន់តែល្អប្រសើរឡើងៗ ឬអាចនិយាយបានថា ដើម្បីលុបបំបាត់ ឬកាត់បន្ថយគម្លាតរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលយើងចង់បាន (ស្ថានភាពនាពេលអនាគត)។ បញ្ហាគឺជា ឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើន (ក្រសួងអយក ការគ្រប់គ្រង រដ្ឋបាល-២០០៩)។ ផែនការអប់រំគឺជាការវិភាគប្រព័ន្ធនូវបញ្ហានៃមជ្ឈដ្ឋានអប់រំ (ដោយប្រើប្រាស់អាំងឌីកាទ័រអប់រំ) ការតាក់តែង និងជ្រើសរើសយុទ្ធវិធី ព្រមទាំងការអនុវត្តផែនការប្រតិបត្តិមួយដោយមានការពិនិត្យតាមដាន វាយតម្លៃ និងការរៀបចំថវិកាដើម្បីអនុវត្តផែនការឱ្យបានជោគជ័យ (ក្រសួងអយក ការគ្រប់គ្រង រដ្ឋបាល-២០០៩)។ ផែនការអភិវឌ្ឍន៍សាលារៀនជាគម្រោងមួយដែលមានសកម្មភាពជាក់លាក់សម្រាប់អនុវត្ត ដើម្បីធ្វើឱ្យអ្នកទទួលខុសត្រូវសម្រេចបាននូវលទ្ធផលអ្វីមួយ។ គម្រោងមានកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់។ គម្រោងខុសពីការងារធម្មតា ពីព្រោះការងារធម្មតាអនុវត្តស្រដៀងៗគ្នាជារៀងរាល់ថ្ងៃ ដោយគ្រាន់តែមានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ ចំណែកឯគម្រោងវិញ គឺត្រូវសម្រេចលទ្ធផលជាក់ស្តែងដែលអាចមើលឃើញ ឬផ្ទៀងផ្ទាត់បាន។ លទ្ធផលរបស់គម្រោងអាចឱ្យយើងយកទៅប្រើប្រាស់បាននៅក្នុងរយៈពេលមួយកំណត់ គឺក្នុងករណីនេះហើយដែលគម្រោងមិនអាចធ្វើឡើងដដែលៗនោះទេ។ មានន័យថា ក្រោយពីអនុវត្តគម្រោងមួយចប់ហើយ យើងត្រូវតែរៀបចំ និងដំណើរការគម្រោងមួយថ្មីទៀត។ ការអនុវត្តនានានៅក្នុងគម្រោងចាស់នឹងផ្តល់បទពិសោធន៍សម្រាប់គម្រោងថ្មី (ក្រសួងអយក ការគ្រប់គ្រង រដ្ឋបាល-២០០៩)។ ផែនការកែលម្អសាលារៀនគឺជាផ្លូវមួយដែលកំណត់ពីការផ្លាស់ប្តូរសាលារៀនដើម្បីធ្វើឱ្យប្រសើរឡើងនូវកម្រិតនៃលទ្ធផលសិក្សារបស់សិស្ស និងបង្ហាញពីរបៀប និងពេលវេលាដែលការផ្លាស់ប្តូរទាំងនោះនឹងត្រូវបានធ្វើឡើង (The Education Improvement Commission-April 2000)។

## ២.២. សមាសភាពសំខាន់ៗក្នុងការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

ការលើកគម្រោង ទាមទារឱ្យមានព័ត៌មានទាក់ទងជាច្រើនដូចជា ការព្រមព្រៀងពីអ្នកអនុវត្តគម្រោង ការព្រមព្រៀងពីអ្នកផ្តល់មូលនិធិសម្រាប់គម្រោង ហើយធ្វើយ៉ាងណាឱ្យប្រាកដថា មូលនិធិនឹងត្រូវបានយកមកប្រើប្រាស់។ អ្នកទទួលខុសត្រូវនានា គួររៀបចំធ្វើផែនការរួមគ្នា។ "ការធ្វើផែនការរួមគ្នា ឬធ្វើផែនការដោយមានការចូលរួម" គឺធ្វើឱ្យអ្នកជាប់ពាក់ព័ន្ធក្នុងការងារយល់ និងព្រមព្រៀងទាំងអស់គ្នាលើអ្វីដែលត្រូវធ្វើ។ តាមទម្លាប់ចាស់ មនុស្សម្នាក់ជាអ្នកធ្វើផែនការ ហើយក្រុមដទៃ ឬនាយកដ្ឋាននានា ជាអ្នកអនុវត្តផែនការ។ ការធ្វើរបៀបនេះ ចំណាយពេលវេលាច្រើន ធ្វើឱ្យមានការមិនយល់គ្នា បង្កើតឱ្យមានទំនាក់ទំនងមិនសូវល្អ ហើយលទ្ធផលទៀតសោត ស្ថិតក្នុងគុណភាពដែលមានកម្រិតស្តង់ដារទាប។ តាមរបៀបថ្មី ក្រុមអ្នកទទួលខុសត្រូវធ្វើផែនការរួមគ្នា ហើយអនុវត្តការងាររួមគ្នា។ គំនិតជាច្រើនត្រូវបានដាក់បញ្ចូលរួមគ្នា ក្នុងវត្ថុបំណងរួមមួយ។ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមួយប្រកបដោយប្រសិទ្ធភាព និងគុណភាពទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជា គណៈគ្រប់គ្រងសាលា (នាយក នាយិកា និងនាយករង នាយិការង) ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន (ក្រសួងអយក ការគ្រប់គ្រងរដ្ឋបាល-២០០៩)។

- **គណៈគ្រប់គ្រងសាលា:** នាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងការគ្រប់គ្រងដំណើរការរៀបចំផែនការ ព្រមទាំងផ្តល់ការពន្យល់ណែនាំច្បាស់លាស់ពីដំណើរការរៀបចំ និងជួយដល់ភាគីពាក់ព័ន្ធយល់ដឹងច្បាស់លាស់ពីតួនាទីក្នុងដំណើរការ។ គណៈគ្រប់គ្រងសាលាមានតួនាទីក្នុងការផ្តួចផ្តើមដំណើរការរៀបចំ បង្កើតបរិយាកាសអំណោយផលដល់កិច្ចសហការ លើកទឹកចិត្តបុគ្គលិកឱ្យមានការចូលរួមរៀបចំផែនការ និងធនធាន រៀបចំនីតិវិធីពិគ្រោះយោបល់ ទំនាក់ទំនង និងវាយតម្លៃផែនការ
- **ថ្នាក់ដឹកនាំក្រុមបច្ចេកទេស:** តំណាងឱ្យគ្រូបង្រៀនតាមមុខវិជ្ជា ដែលដើរតួនាទីសំខាន់ក្នុងការរៀបចំផែនការ និងជួយធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងរៀនតាមមុខវិជ្ជានីមួយៗ

- **គ្រូបង្រៀន:** ជាអ្នកផ្តល់នូវព័ត៌មានចាំបាច់ទាក់ទងនឹងដំណើរការបង្រៀន និងរៀន ចូលរួមយ៉ាងសំខាន់អំឡុងពេលរៀបចំផែនការអភិវឌ្ឍន៍សាលារៀនក្នុងការកំណត់កត្តាអាទិភាព គោលដៅ និងបង្កើតយុទ្ធសាស្ត្រអនុវត្តសម្រាប់ផែនការ។ ចូលរួមយ៉ាងសកម្មក្នុងការបំភ្លឺបេសកកម្ម ចក្ខុវិស័យ និងគោលបំណងរបស់សាលារៀននៅក្នុងការពិនិត្យឡើងវិញនូវស្ថានភាពបច្ចុប្បន្នរបស់សាលារៀន និងរៀបចំកត្តាអាទិភាពសម្រាប់អភិវឌ្ឍន៍ ព្រមទាំងចូលរួមក្នុងការពិភាក្សា និងធ្វើការសម្រេចចិត្ត។
- **មាតាបិតាសិស្ស:** ចែករំលែកទស្សនៈយល់ឃើញទាក់ទងនឹងតម្រូវការរបស់កុមារក្នុងការសិក្សា និងការលំបាកដែលពួកគេជួបប្រទះនៅក្នុងសាលារៀន បង្ហាញពីបំណងប្រាថ្នាចំពោះសាលារៀន និងកូនៗរបស់ពួកគេ ពីកង្វល់ផ្សេងៗ និងចូលរួមក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ និងកត្តាអាទិភាពសម្រាប់សាលារៀន។
- **សិស្សានុសិស្ស:** សិស្សជាអ្នកទទួលផលពីការផ្តល់សេវាអប់រំពីសំណាក់គ្រូបង្រៀន។ ដូច្នេះសិស្សដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមតាមរយៈការបង្ហាញពីផលលំបាក និងតម្រូវការរបស់ពួកគេក្នុងការរៀន ដើម្បីធ្វើយ៉ាងណាឱ្យសម្រេចបាននូវលទ្ធផលសិក្សា និងកែលម្អការផ្តល់សេវាអប់រំ។
- **សហគមន៍ និងអាជ្ញាធរមូលដ្ឋាន:** សហគមន៍ និងអាជ្ញាធរមូលដ្ឋានអាចចូលរួមក្នុងដំណើរការធ្វើផែនការតាមវិធីមួយចំនួន។ ដំណើរការពិនិត្យឡើងវិញរួមបញ្ចូលទាំងការពិចារណានៃកត្តាបរិបទក្នុងស្រុកដែលប៉ះពាល់ដល់សាលារៀន ហើយនេះអាចតម្រូវឱ្យមានការស្ទង់មតិមួយអំពីសហគមន៍មូលដ្ឋានដើម្បីបង្កើតទស្សនៈតម្រូវការ ឬឱកាស ។ សាលារៀនអាចទាញយកចំណេះដឹង និងធនធានរបស់សមាជិកពាក់ព័ន្ធរបស់សហគមន៍ និងអាជ្ញាធរក្នុងការរៀបចំផែនការដើម្បីដោះស្រាយបញ្ហាជាក់លាក់ណាមួយ។

## ២.៣. គោលបំណង និងសារៈសំខាន់នៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

ផែនការអភិវឌ្ឍន៍សាលារៀន គឺជួយដល់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានឱ្យមានៈ

១. ទស្សនៈ និងចំណេះដឹងទូលំទូលាយ ក្នុងការអនុវត្តការងារគ្រប់គ្រងសាលារៀន ដោយផ្អែកលើផលសម្រេច និងផ្តោតជាចម្បងលើគុណភាពលទ្ធផលសិក្សារបស់សិស្ស។

២. លទ្ធភាពបកស្រាយបញ្ញត្តិ និងគោលការណ៍របស់ឯកសារគោលនយោបាយ សេចក្តីណែនាំ និងលិខិតបទដ្ឋាននានា ដែលបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយដោយក្រសួងអប់រំ

យុវជន និងកីឡា និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងនៅតាមសាលារៀននីមួយៗ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនឱ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។

៣. បំណិនក្នុងការចលនា និងសម្របសម្រួលទាក់ទាញការចូលរួម ពីសំណាក់សិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានក្នុងការអនុវត្តសកម្មភាព៖

- ស្វ័យវាយតម្លៃសាលារៀន ដើម្បីឱ្យបានដឹងពីចំណុចជោគជ័យ និងចំណុចត្រូវកែលម្អ ដោយបានកំណត់មុខសញ្ញាទទួលខុសត្រូវ ក្នុងការអនុវត្តសកម្មភាពជាក់ស្តែងក្នុងដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀន ក្នុងសាលារៀន និងក្នុងសហគមន៍
- ធ្វើផែនការអភិវឌ្ឍន៍សាលារៀន ដោយផ្អែកលើចំណុចដែលត្រូវកែលម្អដែលបានមកពីលទ្ធផលស្វ័យវាយតម្លៃសាលារៀន លទ្ធផលនៃការងារអធិការកិច្ចផ្ទៃក្រៅ ដោយកំណត់មុខសញ្ញាទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាក់ស្តែង ទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដើម្បីឱ្យក្លាយទៅជាសកម្មភាពនៃដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀនក្នុងសាលារៀន និងក្នុងសហគមន៍
- តាមដាន និងវាយតម្លៃសាលារៀននៅដើមឆ្នាំសិក្សា នៅចុងឆ្នាំសិក្សា និងនៅក្នុងអំឡុងពេលអនុវត្តសកម្មភាពក្នុងឆ្នាំសិក្សា ដោយប្រើប្រាស់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធផលការងាររបស់សាលារៀន (ក្រសួងអយក ការរៀបចំផែនការអភិវឌ្ឍសាលារៀន-២០១៧)។

## ២.៤. ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

ការកសាងផែនការអភិវឌ្ឍន៍សាលារៀន នឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេលមួយឆ្នាំម្តង គឺនៅពេលចាប់ផ្តើមអនុវត្តនៅដើមឆ្នាំសិក្សានីមួយៗ ដែលមានសមាសភាពចូលរួមពីគណៈគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន គ្រូបង្រៀន តំណាងសិស្ស ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុស្តិ៍នគរបាល និងមណ្ឌលសុខភាពរួមជាមួយអ្នកពាក់ព័ន្ធមួយចំនួនទៀត។ នៅរៀងរាល់ដើមឆ្នាំសិក្សានីមួយៗ សាលារៀនចាំបាច់ត្រូវរៀបចំធ្វើផែនការអភិវឌ្ឍន៍សាលារៀនក្រោមការចាត់ចែងសម្របសម្រួលពីគណៈគ្រប់គ្រងសាលារៀន ដើម្បីដឹកនាំដំណើរការប្រជុំ

ពិភាក្សា ពីបញ្ហាដែលតែងតែកើតមានឡើងក្នុងសាលារៀន ដោយផ្អែកលើលទ្ធផលស្វ័យវាយតម្លៃសាលារៀន (ក្រសួងអយក ការរៀបចំផែនការអភិវឌ្ឍសាលារៀន-២០១៧)។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការជ្រើសរើសសំណាក

នៅក្នុងការស្រាវជ្រាវនេះ យើងបានជ្រើសរើសយកសំណាកចំនួន ៣១១ ដោយផ្អែកតាមរូបមន្តគណនាចំនួនសំណាក Slovin ដែលមានកម្រិតជាក់លាក់៩៥%។ សំណាកត្រូវបានជ្រើសរើសដោយចៃដន្យចេញពីវិទ្យាល័យចំនួន១២ ក្នុងចំណោមវិទ្យាល័យទាំង១៩នៅទូទាំងខេត្ត ដោយមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា៖ គណៈគ្រប់គ្រងសាលា (នាយក/នាយិកា និងនាយករង/នាយិការង)ចំនួន១៨នាក់ មន្ត្រីរដ្ឋបាល/គណនេយ្យចំនួន០៨នាក់ ប្រធាន/អនុប្រធានក្រុមបច្ចេកទេសចំនួន៥៦នាក់ និងលោកគ្រូ-អ្នកគ្រូចំនួន២២៩នាក់។ ចំនួនបុគ្គលិកអប់រំនៅវិទ្យាល័យទាំងអស់ (ប្រជាករ) រួមទាំងបុគ្គលិកការិយាល័យ និងបុគ្គលិកបង្រៀន មានចំនួន១៣៨១នាក់ ស្រី៤០៩នាក់ (មន្ទីរអយកខេត្តស្វាយរៀងស្ថិតិបុគ្គលិក-២០១៨)។ សម្រាប់ការស្រាវជ្រាវនេះ យើងមិនបានជ្រើសរើសសំណាកគម្រូពីអ្នកពាក់ព័ន្ធដទៃទៀតដែលនៅក្រៅសាលារៀន ដូចជា៖ មាតាបិតាសិស្ស ប្រជាពលរដ្ឋសហគមន៍ និងអាជ្ញាធរមូលដ្ឋានទេ។

ការគណនាចំនួនសំណាកតាមរូបមន្ត Slovin ដែលមានកម្រិតជាក់លាក់៩៥%

យោងតាមរូបមន្ត Slovinគឺ៖

$n=N / (1+N e^2)$

ចំនួនសំណាក=ចំនួនប្រជាករ ៖ (១+ចំនួនប្រជាករ x កម្រិតលម្អៀង$^{២}$)

ដោយកម្រិតលម្អៀង៥%=0.0៥

ចំនួនសំណាក=១៣៨១ ៖ (១ + ១៣៨១ x 0.0៥$^{២}$)

ដូច្នេះ ចំនួនសំណាក=<u>៣១០សំណាក</u>

ការជ្រើសរើសចំនួនសំណាកនៅតាមស្រុក/ក្រុងគោលដៅមិនដូចគ្នាទេគឺ អាស្រ័យទំហំស្រុក/ក្រុង ចំនួនវិទ្យាល័យ និងចំនួនបុគ្គលិកអប់រំនៅតាមស្រុក/ក្រុងនីមួយៗ និងចំនួនសំណាកដែលប្រមូលពីអ្នកឆ្លើយសំណួរមកវិញ។

*តារាងចំនួនវិទ្យាល័យ ចំនួនបុគ្គលិកអប់រំ ចំនួនសំណាកជ្រើសរើស*

| ល.រ | ឈ្មោះស្រុក/ក្រុង | ចំនួនវិទ្យាល័យ | ចំនួនគ្រូបង្រៀន | ភាគរយ | ចំនួនសំណាក | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រុងស្វាយរៀង | ២ | ២២៥ | ១៦.២៩% | ៥៩ | ១៩.០% |
| ២ | ស្រុកស្វាយជ្រំ | ៤ | ២៩៨ | ២១.៥៨% | ៥៨ | ១៨.៦% |
| ៣ | ស្រុកស្វាយទាប | ២ | ១៥២ | ១១.០១% | ៣១ | ១០% |
| ៤ | ស្រុករមាសហែក | ៣ | ២០១ | ១៤.៥៥% | ៣៤ | ១០.៩% |
| ៥ | ស្រុកកំពង់រោទិ៍ | ២ | ១៥១ | ១០.៩៣% | ៤០ | ១២.៩% |
| ៦ | ស្រុករំដួល | ៣ | ២០៧ | ១៤.៩៩% | ៣០ | ៩.៦% |
| ៧ | ស្រុកចន្ទ្រា | ១ | ២៩ | ២.១០% | ១៩ | ៦.១% |
| ៨ | ក្រុងបាវិត | ២ | ១១៨ | ៨.៥៤% | ៤០ | ១២.៩% |
| **សរុប** | | **១៩** | **១៣៨១** | **១០០%** | **៣១១** | **១០០%** |

## ៣.២. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវវិញ យើងខ្ញុំបានរៀបចំបង្កើតកម្រងសំណួរសម្រាប់ធ្វើការចុះសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលា និងសម្រាប់លោកគ្រូ-អ្នកគ្រូ ព្រមទាំងមន្ត្រីអប់រំផ្សេងៗទៀត ដើម្បីធ្វើការបំពេញដែលចំណាយពេលប្រមាណពី១៥នាទី ទៅ២០នាទី។ យើងខ្ញុំប្រើប្រាស់កម្រងសំណួរតែមួយប្រភេទសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។ វិធីសាស្ត្រដែលបានជ្រើសរើសនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺជាការស្ទង់មតិ និងសិក្សាពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្រងសំណួរត្រូវបានរៀបចំតែមួយប្រភេទប៉ុណ្ណោះសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ដោយប្រើប្រាស់កម្រងសំណួរចំនួន១៨

ច្បាប់ សម្រាប់គណៈគ្រប់គ្រងសាលា ០៨ច្បាប់សម្រាប់មន្ត្រីរដ្ឋបាល និងគណនេយ្យ ៥៦ច្បាប់ សម្រាប់ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និង ២២៩ច្បាប់ សម្រាប់លោកគ្រូ-អ្នកគ្រូ។

ក្នុងការបង្កើតកម្រងសំណួរទាំងនេះយើងខ្ញុំបានប្រើប្រាស់ឯកសារជំនួយខ្លះៗ ហើយ បានកែសម្រួលខ្លឹមសារមួយចំនួនដើម្បីឲ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។ ឯកសារជំនួយដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតកម្រងសំណួរនេះមានប្រភពផ្សេងៗគ្នាដូចជា៖

- ផែនការអភិវឌ្ឍន៍សាលារៀន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០០៩ សម្រាប់បំប៉ននាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សា
- ស្វ័យវាយតម្លៃសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា

## ៣.៣. កម្រងសំណួរ និងគោលបំណង

- **ផ្នែកទី១** ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន២សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពីតួនាទី និងទីតាំងវិទ្យាល័យរបស់អ្នកបំពេញកម្រងសំណួរកំពុងបម្រើការងារ
- **ផ្នែកទី២** ការយល់ដឹងពីទម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀន ដែលមាន ៥ សំណួរ។ អ្នកស្រាវជ្រាវចង់ស្វែងរកឲ្យឃើញនូវកម្រិតយល់ដឹងរបស់អ្នកបំពេញកម្រងសំណួរពីការរៀបចំផែនការផ្សេងៗនៅក្នុងសាលារៀន ពីការចូលរួមរបស់ពួកគេក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ពីកម្រិតយល់ដឹងពីខ្លឹមសារ និងសកម្មភាពដែលបានគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន និងអ្នកពាក់ព័ន្ធទាំងឡាយដែលត្រូវបានពិគ្រោះយោបល់ក្នុងការរៀបចំផែនការ។
- **ផ្នែកទី៣** ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។ ក្នុងផ្នែកនេះមាន១៤ សំណួរ។ គោលបំណងនៃសំណួរនៅក្នុងផ្នែកនេះគឺចង់ដឹងអំពីវិធីសាស្ត្រនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន បញ្ហាប្រឈមសំខាន់ៗដែលសាលាជួបប្រទះនាពេលបច្ចុប្បន្នដែលត្រូវដោះស្រាយជាអាទិភាព សកម្មភាពដែលគ្រោងជាក់ស្តែងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅឆ្នាំសិក្សាថ្មី កម្រិតនៃភាពពេញចិត្តចំពោះផែនការដែល

បានរៀបចំឡើង និងមូលហេតុនៃការជ្រើសរើសកម្រិតពេញចិត្តរបស់អ្នកបំពេញកម្រងសំណួរ។

- **ផ្នែកទី៤** ដំណាក់កាលក្រោយរៀបចំផែនការអភិវឌ្ឍន៍សាលារៀនៈ ក្នុងផ្នែកនេះមាន៧សំណួរ។ គោលបំណងនៃសំណួរទាំងនោះគឺ ចង់ដឹងអំពីកម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំ តាមរយៈបទពិសោធន៍ និងកម្រិតនៃភាពពេញចិត្តលើលទ្ធផលអនុវត្តផែនការក្នុងរយៈពេល៥ឆ្នាំកន្លងមក មូលហេតុនៃការជ្រើសរើសកម្រិតនៃភាពពេញចិត្តលើលទ្ធផលទាំងនោះ ការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនីមួយៗ កម្រិតថវិកាដែលទទួលបាន ថាតើឆ្លើយតបទៅនឹងតម្រូវជាក់ស្តែងរបស់សាលារៀននីមួយៗដែរឬទេ កម្រិតនៃការផ្សព្វផ្សាយខ្លឹមសារ និងសកម្មភាពដែលគ្រោងទៅអ្នកពាក់ព័ន្ធ និងសំណូមពរនានា។ ជំពូកនេះ យើងមិនបានធ្វើការសិក្សាបែបស៊ីជម្រៅទៅលើរបៀបអនុវត្តសកម្មភាព នីតិវិធីនៃការប្រើប្រាស់ថវិកា ឬធ្វើការសិក្សាប្រៀបធៀបពីលទ្ធផលសម្រេចបាន ដោយធៀបទៅនឹងផែនការដែលវិទ្យាល័យនីមួយៗបានគ្រោងឡើង ដើម្បីវាយតម្លៃពីកម្រិតជោគជ័យនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំឡើងនៅតាមវិទ្យាល័យនីមួយៗ ក៏ដូចជាកម្រិតខេត្តទាំងមូលនោះដែរ។

## ៣.៤. នីតិវិធី និងដំណើរការប្រមូលទិន្នន័យ

ក្រៅពីទ្រឹស្តី និងទិន្នន័យដែលមានស្រាប់ យើងក៏បានចុះទៅប្រមូលទិន្នន័យជាក់ស្តែងនៅតាមគោលដៅនានា ដើម្បីទទួលបានទិន្នន័យបឋមសម្រាប់យកមកវិភាគក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងការចុះប្រមូលទិន្នន័យនេះដែរ គឺយើងបានប្រើប្រាស់រយៈពេល២សប្តាហ៍ ពីថ្ងៃទី១ ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៨ ហើយនឹងចុះទៅវិទ្យាល័យគោលដៅចំនួន១២ នៅស្រុក/ក្រុងទាំង៨ ពោលគឺចុះសិក្សាស្រាវជ្រាវនៅគ្រប់ស្រុក/ក្រុងទាំងអស់នៃខេត្តស្វាយរៀង ក្នុងនោះ ក្រុងស្វាយរៀងមាន០២វិទ្យាល័យ ក្រុងបាវិតមាន០២វិទ្យាល័យ ស្រុករំដួលមាន០១វិទ្យាល័យ ស្រុករមាសហែកមាន០១វិទ្យាល័យ ស្រុកស្វាយជ្រំមាន០២វិទ្យាល័យ ស្រុកស្វាយទាបមាន០១វិទ្យាល័យ ស្រុកកំពង់រោទ៍មាន០២វិទ្យាល័យ និងស្រុកចន្ទ្រាមាន០១វិទ្យា

ល័យ។ ការជ្រើសរើសចំនួនវិទ្យាល័យមួយ ឬពីរ គឺអាស្រ័យលើទំហំស្រុក/ក្រុង និងចំនួនវិទ្យាល័យនៅតាមស្រុក/ក្រុងទាំងនោះ។

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងបានធ្វើ លិខិតស្នើសុំចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ។ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ និងដាក់ជូនសាលាខេត្តស្វាយរៀងដើម្បីជ្រាបជាព័ត៌មាន។ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវក៏បានយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោកប្រធានការិយាល័យអប់រំស្រុក/ក្រុងទាំង៨ ដើម្បីសាកសួរព័ត៌មានពីទីតាំងដែលត្រូវចុះប្រមូលទិន្នន័យ។ បន្ទាប់ពីបានទំនាក់ទំនងជាមួយមន្ត្រីអប់រំស្រុក/ក្រុងរួចមក យើងខ្ញុំបានជួបជាមួយនាយកនាយិកាសាលាដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវ ក្រមសីលធម៌នៃការស្រាវជ្រាវ និងប្រយោជន៍ដើម្បីទទួលបានការចូលរួម ព្រមទាំងសុំការអនុញ្ញាតដើម្បីឱ្យគាត់ជួយ ផ្តល់បទសម្ភាសន៍ ក៏ដូចជាសាកសួរព័ត៌មានអំពីមន្ត្រីរដ្ឋបាល/គណនេយ្យ និងលោកគ្រូ អ្នកគ្រូដែលត្រូវបំពេញកម្រងសំណួរ។ បន្ទាប់មកទៀតយើងខ្ញុំក៏បានផ្តល់កម្រងសំណួរចំនួន៣៤០ច្បាប់ដល់អ្នកចូលរួមទាំងអស់ តែប្រមូលបានមកវិញតែ៣១១ច្បាប់ប៉ុណ្ណោះ ដោយបាត់បង់អស់២៩ច្បាប់ ក្នុងនោះបានពីគណៈគ្រប់គ្រងសាលាចំនួន១៨ច្បាប់ ផ្តល់ជូនកម្រងសំណួរចំនួន០៨ច្បាប់ដល់មន្ត្រីរដ្ឋបាល/គណនេយ្យនៅការិយាល័យ កម្រងសំណួរ៥៦ច្បាប់ដល់ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងកម្រងសំណួរ២២៩ច្បាប់ដល់លោកគ្រូ អ្នកគ្រូ ដោយយើងខ្ញុំបានទុកពេលវេលាដល់ពួកគាត់ រយៈពេល១៥នាទី ទៅ២០នាទីដើម្បីបំពេញកម្រងសំណួរ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីមានសំណួរ ឬចម្ងល់។ យើងខ្ញុំយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងសហការជាមួយក្រុមគោលដៅទាំងអស់ ដើម្បីទទួលបានព័ត៌មានមួយអាចជឿទុកចិត្តបានសម្រាប់យកទៅវិភាគក្នុងការសិក្សាស្រាវជ្រាវ។ សម្រាប់អ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបំពេញកម្រងសំណួរក្រៅពីគណៈគ្រប់គ្រងសាលា យើងខ្ញុំក៏បានធ្វើការណែនាំ និងពន្យល់ពីគោលបំណងនៃសំណួរ និងរបៀបនៃការឆ្លើយបំពេញកម្រងសំណួរយ៉ាងច្បាស់លាស់ ដោយប្រើរយៈពេលប្រមាណ២០នាទី។ បន្ទាប់មក យើងបានទុកពេលវេលាមួយសមស្របសម្រាប់ការបំពេញចម្លើយបន្ថែមដែលអាចប្រើប្រាស់រយៈពេលប្រមាណពី១៥នាទី ទៅ

២០នាទី។ គណៈគ្រប់គ្រងសាលា ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងមន្ត្រីរដ្ឋបាល/គណនេយ្យ ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ បានផ្តល់កម្រងសំណួរត្រឡប់មកវិញគ្រប់ចំនួន ។

## ៣.៥. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធីSPSS ដើម្បីវិភាគតាមបែបបរិមាណវិស័យ និងកម្មវិធី Ms. Excel ដើម្បីបង្កើតក្រាហ្វិក។ ចំណែកឯសំណួរបើកវិញជាសំណួរបែបគុណវិស័យ យើងវិភាគដោយប្រើប្រាស់កម្មវិធី Word។ ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬ សំណួរបិត។ ចំពោះការវិភាគនេះអ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួន ដូចជាៈ កម្រិតនៃការយល់ដឹងពីខ្លឹមសារ និងសកម្មភាពនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ដំណើរការនៃការរៀបចំផែនការ កម្រិតនៃភាពពេញចិត្ត សិក្សាប្រៀបធៀបបញ្ហាប្រឈមសំខាន់ៗដែលវិទ្យាល័យនីមួយៗជួបប្រទះ និងសកម្មភាពជាក់ស្តែងដែលគ្រោងឡើងនៅក្នុងផែនការ ព្រមទាំងការលំបាកនានាក្នុងការរៀបចំផែនការនោះឡើង។ រាល់ចម្លើយនៅក្នុងកម្រងសំណួរនឹងត្រូវពិនិត្យថាតើវាមានលក្ខណៈសមស្រប និងយកជាការបានដែរឬអត់ ព្រមទាំងធ្វើការសម្អាតចម្លើយទាំងនោះ មុនពេលបញ្ចូលទៅក្នុងកុំព្យូទ័រជាមួយកម្មវិធីSPSS។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច នឹងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយ យើងនឹងទាញសេចក្តីសន្និដ្ឋាន ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនតែម្តង។ ជាចុងក្រោយបន្ទាប់ពីកំណត់បាននូវបញ្ហាប្រឈមក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន យើងនឹងផ្តល់អនុសាសន៍មួយចំនួនដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំនេះដើម្បីលើក

កម្ពស់ប្រសិទ្ធភាព និងគុណភាពនៃផែនការអភិវឌ្ឍន៍សាលារៀនដែលមានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន។

### ៣.៥.១ ឧបករណ៍វិភាគទិន្នន័យ

ដើម្បីវិភាគទិន្នន័យ យើងប្រើកម្មវិធីSPSS &Excel សម្រាប់ទិន្នន័យបែបបរិមាណវិស័យ។ កម្មវិធីSPSS ត្រូវបានប្រើប្រាស់សម្រាប់បញ្ចូលទិន្នន័យ និងវិភាគ។ ចំណែកឯ កម្មវិធី Ms. Excel ត្រូវបានប្រើប្រាស់ដើម្បីសង់ក្រាហ្វិក និងបកប្រែជាភាសាខ្មែរដោយយកទិន្នន័យពីកម្មវិធី SPSS ស្វែងរកកម្រិតនៃការយល់ដឹងពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ការចូលរួម កម្រិតនៃភាពពេញចិត្ត និងកម្រិតការផ្សព្វផ្សាយដែលគិតជាហ្វ្រេកង់ និងគិតជាភាគរយ។ ដោយឡែកកម្មវិធី Ms. Word ត្រូវបានប្រើប្រាស់ដើម្បី វិភាគលើសំណួរបែបគុណវិស័យ ដោយធ្វើការបកស្រាយពន្យល់លើសំណួរដែលពាក់ព័ន្ធនិង ទស្សនៈរបស់ភាគីពាក់ព័ន្ធ។

### ៣.៥.២ ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួរ និងសម្ភាសន៍ពីអ្នកចូលរួមនានា។ ការវិភាគកម្រងសំណួរមានគោលបំណងស្វែងរកឲ្យឃើញ ពីកម្រិតនៃការយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងផែនការទាំងឡាយដែលបានរៀបចំនៅក្នុងវិទ្យាល័យគោលដៅនីមួយៗ ការចូលរួមរបស់ពួកគេក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ខ្លឹមសារ និងសកម្មភាពដែលគ្រោងនៅក្នុងផែនការនោះ សមាសភាពអ្នកចូលរួមក្នុងការរៀបចំ វិធីសាស្រ្តក្នុងការរៀបចំ ការស្វែងយល់ និងសិក្សាប្រៀបធៀបរវាងបញ្ហាប្រឈមសំខាន់ៗរបស់សាលារៀន និងសកម្មភាពដែលគ្រោងនៅក្នុងផែនការដើម្បីអភិវឌ្ឍន៍សាលារៀន កម្រិតនៃភាពពេញចិត្តចំពោះផែនការដែលបង្កើតឡើង កម្រិតនៃការអនុវត្តផែនការដែលបានគ្រោងឡើង កម្រិតនៃភាពពេញចិត្តចំពោះលទ្ធផលអនុវត្តផែនការរយៈពេលប្រាំឆ្នាំចុងក្រោយ ការលំបាកក្នុងការរៀបចំផែនការ និងចង់ដឹងថាតើថវិកាដែលទទួលបានពីរដ្ឋឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀនដែរឬទេ ព្រមទាំងកម្រិតនៃការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍សាលារៀននោះទៅដល់អ្នកពាក់ព័ន្ធទាំងឡាយ។

### ៣.៥.៣ ការវិភាគទិន្នន័យ

ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធនានាដូចជា៖ គណៈគ្រប់គ្រងសាលា (មាននាយក/នាយិកា និងនាយករង/នាយិការង) មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស (មានប្រធានក្រុម និងអនុប្រធានក្រុមបច្ចេកទេស) និងលោកគ្រូ អ្នកគ្រូ ត្រូវបានវិភាគរួមគ្នាតែម្តង ហើយយើងក៏ធ្វើការបែងចែកការវិភាគផងដែរទៅតាមស្រុក/ក្រុងដែលវិទ្យាល័យនីមួយៗស្ថិតនៅ ដើម្បីឆ្លុះបញ្ចាំងលក្ខណៈដោយឡែករបស់តំបន់នីមួយៗលើចំណុចមួយចំនួន ព្រមទាំងធ្វើការវិភាគ និងវាយតម្លៃសម្រាប់កម្រិតខេត្តទាំងមូល។

### ៣.៥.៤ ការវិភាគទិន្នន័យលើកម្រងសំណួរជាព័ត៌មានផ្ទាល់ខ្លួន

ការសិក្សាស្រាវជ្រាវនេះ យើងមិនបានកំណត់ភេទ និងអាយុរបស់អ្នកចូលរួមឡើយ ដែលមានន័យថាអ្នកចូលរួមទាំងអស់ដែលជាក្រុមគោលដៅ ហើយត្រូវទៅតាមលក្ខខណ្ឌកំណត់នៅក្នុងគម្រូជ្រើសរើសដូចជា៖ ថ្នាក់ដឹកនាំសាលារៀន (នាយក/នាយិកា និងនាយករង/នាយិការង) ថ្នាក់ដឹកនាំក្រុមបច្ចេកទេស(ប្រធានក្រុម និងអនុប្រធានក្រុមបច្ចេកទេស) មន្ត្រីរដ្ឋបាល/គណនេយ្យ និងលោកគ្រូ-អ្នកគ្រូដែលបង្រៀននៅតាមវិទ្យាល័យគោលដៅទាំងអស់ នឹងត្រូវជ្រើសរើសជាគម្រូសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ ដូច្នេះភាគរយនៃផលធៀបភេទ និងអាយុរបស់អ្នកចូលរួមមិនត្រូវបានធ្វើការកំណត់ទុកឡើយ។ ជាលទ្ធផល យើងទទួលបានអ្នកចូលរួមសរុបចំនួន៣១១នាក់ដែលរួមមាន គណៈគ្រប់គ្រងសាលារៀនចំនួន១៨នាក់ ថ្នាក់ដឹកនាំក្រុមបច្ចេកទេសចំនួន ៥៦នាក់ មន្ត្រីរដ្ឋបាល/គណនេយ្យចំនួន៨នាក់ និងលោកគ្រូ-អ្នកគ្រូចំនួន២២៩នាក់។ កម្រងសំណួរទាំងអស់ដែលចែកជូនដល់អ្នកពាក់ព័ន្ធមានចំនួន៣៤០ច្បាប់ តែបានប្រគល់ត្រឡប់មកវិញចំនួនតែ៣១១ច្បាប់ប៉ុណ្ណោះ ដោយបាត់បង់អស់ចំនួន២៩ច្បាប់ ស្មើនឹង៨.៥% សម្រាប់វិទ្យាល័យចំនួន១២ក្នុងចំណោមវិទ្យាល័យគោលដៅទាំង១៩នៅទូទាំងខេត្តស្វាយរៀង។

បើពិនិត្យទៅលើអ្នកចូលរួមតាមស្រុក/ក្រុងគោលដៅក្នុងរូបទី៣.១ខាងក្រោម ឃើញថាអ្នកចូលរួមនៅក្រុងស្វាយរៀងមានចំនួន៥៩នាក់ ស្មើនឹង១៩% បើធៀបនឹងអ្នកចូលរួមទាំង

អស់ អ្នកចូលរួមនៅស្រុករំដួលមាន៣០នាក់ ស្មើនឹង៩.៦% អ្នកចូលរួមនៅស្រុករមាសហែក មាន៣៤នាក់ ស្មើនឹង ១០.៩% អ្នកចូលរួមនៅក្រុងបាវិតមាន៤០នាក់ ស្មើនឹង ១២.៩% អ្នកចូលរួមនៅស្រុកស្វាយជ្រំមាន៥៨នាក់ ស្មើនឹង១៨.៦% អ្នកចូលរួមនៅស្រុកកំពង់រោទិ៍មាន៤០នាក់ ស្មើនឹង ១២.៩% អ្នកចូលរួមនៅស្រុកស្វាយទាបមាន ៣១នាក់ ស្មើនឹង ១០% និងចុងក្រោយ អ្នកចូលរួមនៅស្រុកចន្ទ្រាមាន ១៩នាក់ ស្មើនឹង ៦.១%។ ដូច្នេះ អ្នកចូលរួមសរុបមាន៣១១នាក់ ស្មើនឹង ១០០%។

យើងបានប្រគល់សំណាកចំនួន ៣៤០ច្បាប់ សម្រាប់ស្រុក//ក្រុងគោលដៅទាំង០៨។ ក្នុងចំណោមកម្រងសំណួរទាំងអស់ យើងបានប្រគល់កម្រងសំណួរចំនួន៦០ច្បាប់សម្រាប់ស្រុក/ក្រុងណាដែលមានចំនួនវិទ្យាល័យ និងបុគ្គលិកអប់រំច្រើនដូចជា ក្រុងស្វាយរៀង និងស្រុកស្វាយជ្រំជាដើម។ យើងបានប្រគល់កម្រងសំណួរ ៦០ច្បាប់ឱ្យទៅវិទ្យាល័យចំនួន០២ នៅក្រុងស្វាយរៀង តែប្រគល់មកវិញបានត្រឹមតែ ៥៩ច្បាប់ប៉ុណ្ណោះ ដោយបាត់បង់អស់០១ច្បាប់ ហើយយើងក៏បានប្រគល់កម្រងសំណួរ ៦០ច្បាប់ដែរទៅដល់ទៅវិទ្យាល័យចំនួន០២នៅស្រុកស្វាយជ្រំ តែប្រគល់មកវិញបានតែ៥៨ច្បាប់ប៉ុណ្ណោះ ដោយបាត់បង់០២ច្បាប់។ ជាមួយគ្នានេះ យើងបានប្រគល់កម្រងសំណួរដល់ស្រុក/ក្រុងចំនួន០៥ផ្សេងទៀត ដោយក្នុងមួយស្រុក/ក្រុងយើង៤០ច្បាប់ លើកលែងតែស្រុកចន្ទ្រាមួយប៉ុណ្ណោះដែលយើងប្រគល់កម្រងសំណួរត្រឹមតែ២០ច្បាប់ ដោយសារស្រុកនេះមានវិទ្យាល័យតែមួយ ហើយមានបុគ្គលិកអប់រំតិច។ ក្រោយផ្តល់កម្រងសំណួរដល់វិទ្យាល័យគោលដៅទាំងនោះហើយ ពួកគាត់បានប្រគល់ត្រឡប់មកវិញគ្រប់ចំនួន (៤០ច្បាប់) តែពីរស្រុក/ក្រុងប៉ុណ្ណោះគឺ ស្រុកកំពង់រោទិ៍ និងក្រុងបាវិត ចំណែកឯស្រុករំដួលប្រគល់មកវិញត្រឹមតែ ៣០ច្បាប់ ដោយបាត់បង់អស់១០ច្បាប់ ស្រុករមាសហែកប្រគល់ត្រឡប់មកវិញបានតែ៣៤ច្បាប់ ដោយបាត់បង់អស់៦ច្បាប់ ហើយស្រុកស្វាយទាប បានប្រគល់ត្រឡប់មកវិញបាន ៣១ច្បាប់ ដោយបាត់បង់អស់៩ច្បាប់។ ចុងក្រោយស្រុកចន្ទ្រាបានប្រគល់ត្រឡប់មកវិញបាន ១៩ច្បាប់ ដោយបាត់បង់តែ០១ច្បាប់ប៉ុណ្ណោះ។ ជារួម ក្នុងចំណោម ៣៤០ច្បាប់ដែលយើងបានផ្តល់ជូនវិទ្យាល័យគោលដៅនៅតាមស្រុក/ក្រុងនីមួយៗ យើងបាត់បង់អស់២៩ច្បាប់។ ដូច្នេះ ចំនួនសំណាកតិច ឬច្រើននៅតាមស្រុក/ក្រុង

គោលដៅនីមួយៗដែលបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោមគឺ អាស្រ័យលើទំហំស្រុក/ក្រុង ចំនួនវិទ្យាល័យ និងចំនួនបុគ្គលិកអប់រំនៅតាមស្រុក/ក្រុងនីមួយៗ ព្រមទាំងផ្អែកតាមចំនួនសំណាកដែលអ្នកចូលរួមបានប្រគល់ត្រឡប់មកវិញ។

*រូបទី ៣.១ ចំនួនអ្នកចូលរួមតាមស្រុក/ក្រុងគោលដៅ*




សម្រាប់ការជ្រើសរើសសំណាកក្នុងការស្រាវជ្រាវនេះ យើងជ្រើសរើសយកតែបុគ្គលិកអប់រំដែលកំពុងបង្រៀន និងមិនបង្រៀននៅតាមវិទ្យាល័យគោលដៅដែលបានកំណត់នៅក្នុងស្រុក/ក្រុងទាំង៨តែប៉ុណ្ណោះ ដោយធ្វើការជ្រើសរើសក្នុងចំណោមថ្នាក់ដឹកនាំសាលារៀន បុគ្គលិកការិយាល័យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងលោកគ្រូ-អ្នកគ្រូ។ យើងមិនបានជ្រើសរើសសំណាកគម្រូពីអ្នកពាក់ព័ន្ធដទៃទៀតទេដូចជា៖ សិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាលសិស្ស ប្រជាពលរដ្ឋសហគមន៍ ក្រុមប្រឹក្សា/គណៈកម្មការនានា និងអាជ្ញាធរមូលដ្ឋាន ដោយសារយើងធ្វើការសិក្សាស្រាវជ្រាវតែជាមួយអ្នកពាក់ព័ន្ធដោយផ្ទាល់ក្នុងដំណើរការរៀបចំ ការអនុវត្ត និងតាមដានត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅនីមួយៗ។ សូមបញ្ជាក់ថា យើងជ្រើសរើសសំណាកគម្រូទាំងនេះ

ដោយចៃដន្យ ដោយប្រមូលទិន្នន័យពីធនធានខាងក្នុងដែលកំពុងបម្រើការនៅតាមវិទ្យាល័យគោលដៅ ហើយស្ថិតិទាំងនេះ យើងក៏យកទៅធ្វើការវិភាគផងដែរពីកម្រិតនៃការចូលរួម និងផលប៉ះពាល់ពីកត្តាខាងក្រៅក្នុងដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន។

បើយោងតាមរូបភាពទី ៣.២ខាងក្រោម យើងឃើញថា អ្នកចូលរួមដែលជាគណៈគ្រប់គ្រងសាលាជានាយក/នាយិកា និងនាយករង/នាយិការងមានចំនួន១៨នាក់ ស្មើនឹង ៥.៧៩% ធៀបនឹងអ្នកចូលរួមទាំងអស់ មន្ត្រីរដ្ឋបាល/គណនេយ្យដែលធ្វើការនៅការិយាល័យមានចំនួន ០៨នាក់ស្មើនឹង ២.៥៧% ថ្នាក់ដឹកនាំក្រុមបច្ចេកទេសដែលមានប្រធានក្រុម និងអនុប្រធានក្រុមបច្ចេកទេសមានចំនួន ៥៦នាក់ ស្មើនឹង ១៨% ហើយបុគ្គលិកដែលជាគ្រូបង្រៀនមានចំនួន ២២៩នាក់ ស្មើនឹង ៧៣.៦៣% ធៀបនឹងអ្នកចូលរួមទាំងអស់។

*រូបទី ៣.២ ចំនួនអ្នកចូលរួមសរុបបែងចែកតាមតួនាទី*




### ៣.៦. ក្រមសីលធម៌នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងបានកំណត់នូវក្រមសីលធម៌មួយច្បាស់លាស់។ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិតដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា និងផ្តល់ព័ត៌មានដល់សាលាខេត្តព្រមទាំងបានផ្តល់ដំណឹងបន្តទៅដល់មូលដ្ឋានក្នុងការសុំជួបសម្ភាសន៍ជាមួយ នាយក/នាយិកា នាយករង/នាយិការង និងសុំការបំពេញកម្រងសំណួរពីសំណាក់លោកគ្រូ អ្នកគ្រូទាំងអស់។ យើងក៏បានពន្យល់ និងបង្ហាញយ៉ាងច្បាស់លាស់ពីគោលបំណងនៃការសិក្សាស្រាវជ្រាវ ហើយនឹងអាចពន្យល់បន្ថែមពីរបៀបនៃការប្រើប្រាស់ចម្លើយរបស់ពួកគាត់ ប្រសិនបើមានការស្នើសុំ។ ជាមួយគ្នានេះ នៅគ្រប់ការជួបសម្ភាសន៍ និងការបំពេញកម្រងសំណួរ យើងតែងជម្រាបពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវដែលរក្សានូវការសម្ងាត់រាល់ចម្លើយរបស់ពួកគាត់ដែលមិនបានបង្ហាញពីឈ្មោះរបស់អ្នកឆ្លើយពិតប្រាកដ និងមិនបានបញ្ជាក់ឈ្មោះវិទ្យាល័យដែលជាកន្លែងធ្វើការរបស់ពួកគាត់នោះទេ ដើម្បីឱ្យអ្នកឆ្លើយសំណួរមានទំនុកចិត្តក្នុងការផ្តល់ចម្លើយពិតប្រាកដ។ រាល់ព័ត៌មានទាំងឡាយដែលបានឆ្លើយប្រាប់ និងបានកត់ត្រាទុកលើកម្រងសំណួរ នឹងមិនត្រូវបានយកទៅផ្សព្វផ្សាយក្នុងគោលបំណងណាផ្សេងនោះឡើយ ពោលគឺប្រើប្រាស់សម្រាប់តែសរសេរចូលក្នុងនិក្ខេបបទស្រាវជ្រាវស្តីពី **"ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន"** ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំឆ្នាំសិក្សា២០១៦-២០១៨ ហើយមិនត្រឹមតែប៉ុណ្ណោះ រាល់ព័ត៌មានទាំងអស់នឹងត្រូវរក្សាទុកជាការសម្ងាត់ទៀតផង។ កម្រងសំណួរ និងចម្លើយទាំងអស់ គឺបម្រើឱ្យការសរសេរនិក្ខេបបទតែម៉្យាងគត់ នៅពេលដែលការសរសេរត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរហើយនោះនឹងត្រូវបំផ្លាញកម្រងសំណួរនោះចោលភ្លាម។ អ្នកចូលរួមទាំងអស់មានសិទ្ធិគ្រប់គ្រាន់ក្នុងការមិនឆ្លើយនូវសំណួរណាមួយក៏បាន ឬសុំបញ្ឈប់ត្រឹមសំណួរណាមួយ ឬក៏បដិសេធមិនចូលរួមក្នុងការសម្ភាសន៍ ឬបំពេញកម្រងសំណួរក៏បាន ដោយមិនមានបញ្ហាអ្វីមួយ ឬជាមួយនរណាម្នាក់ឡើយ។ ម៉្យាងទៀតយើងក៏មិនមានថតរូបភាព ឬថតសម្លេង កត់ត្រាឈ្មោះ ឬទីកន្លែងណាមួយដែលអាចឱ្យអ្នកដទៃណាម្នាក់កំណត់បានពីអត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយនោះដែរ។

ការពន្យល់ពីអត្ថប្រយោជន៍នៃចម្លើយទាំងអស់ចំពោះការសិក្សាស្រាវជ្រាវរបស់យើងចំពោះសាលារៀនរបស់ពួកគាត់ និងពួកគាត់ផ្ទាល់ វាគឺជាអ្វីដែលពួកគាត់ចង់ដឹង ហើយផលប្រយោជន៍ទាំងនោះអាចជាផលប្រយោជន៍ផ្ទាល់ ឬប្រយោល។ ពួកគាត់នឹងទទួលបាន

ប្រយោជន៍ទាំងនេះនៅពេលខាងមុខ ព្រោះបើកាលណាសាលារៀនរៀបចំផែនការអភិវឌ្ឍន៍សាលារៀនបានល្អសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀននឹងធ្វើឱ្យសាលារៀនមានភាពរីកចម្រើន ព្រមទាំងផ្តល់សេវាកម្មកាន់តែមានប្រសិទ្ធភាព និងគុណភាព ហើយបុគ្គលិកអប់រំទាំងអស់នឹងកាន់តែមានភាពពេញចិត្តក្នុងការបំពេញការងារ និងពេញចិត្តចំពោះស្ថាប័នរបស់ខ្លួនកាន់តែខ្លាំងឡើង។

# ជំពូកទី៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ក្នុងជំពូកទី៤នេះ យើងនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសន៍លើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងលោកគ្រូ-អ្នកគ្រូ។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានលើកយកមកបកស្រាយ និងភាក្សា។

## ៤.១ ការយល់ដឹងពីទម្រង់ និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍សាលារៀន

### ក- ផែនការនានាដែលវិទ្យាល័យបានរៀបចំ

សម្រាប់ផ្នែកនេះ យើងធ្វើការសិក្សាស្រាវជ្រាវពីកម្រិតយល់ដឹងរបស់អ្នកចូលរួមឆ្លើយសំណួរទាំងអស់ពីផែនការនានាដែលវិទ្យាល័យគោលដៅនីមួយៗបានរៀបចំ និងបង្កើតឡើង ដូចជា៖ ផែនការអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រ ផែនការថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការដទៃទៀត ទោះបីការយល់ដឹងពីផែនការទាំងនោះ តាមរយៈការចូលរួមរៀបចំដោយផ្ទាល់ ដោយប្រយោល ឬយល់ដឹងតាមរយៈការប្រជុំផ្សព្វផ្សាយនៅតាមវិទ្យាល័យដែលខ្លួនកំពុងបំពេញការងារក៏ដោយ។

យោងតាម រូបទី៤.១ ខាងក្រោម ឃើញថា អ្នកចូលរួមទាំងអស់បានបង្ហាញពីការយល់ដឹងពីការរៀបចំផែនការនានានៅតាមវិទ្យាល័យដែលខ្លួនបាននិងកំពុងបំពេញការងារដូចខាងក្រោម។ ជាលទ្ធផល អ្នកចូលរួមចំនួន៣១១នាក់ ស្មើនឹង ១០០% បានដឹងថា វិទ្យាល័យរបស់ខ្លួនមានរៀបចំផែនការអភិវឌ្ឍន៍សាលារៀនជារៀងរាល់ឆ្នាំ អ្នកចូលរួម១០២នាក់ ស្មើនឹង ៣៣%បានដឹងពីការរៀបចំផែនការយុទ្ធសាស្ត្រ ហើយអ្នកចូលរួម១២៩នាក់ ស្មើនឹង ៤១.៥% បានដឹងពីការរៀបចំផែនការថវិកាក្នុងវិទ្យាល័យដែលខ្លួនបាននឹងកំពុងបំពេញការងារ និងចុងក្រោយ អ្នកចូលរួម ១៦៦នាក់ ស្មើនឹង៥៣.៤% បានដឹងពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។

ផ្អែកតាមស្ថិតិនេះ វាបង្ហាញថា អ្នកចូលរួមទាំងអស់មានការយល់ដឹងច្រើនជាងគេទាក់ទងនឹងផែនការអភិវឌ្ឍន៍សាលារៀន ដោយសារផែនការនេះត្រូវបានរៀបចំឡើង និងអនុវត្តជារៀងរាល់ឆ្នាំដោយប្រើប្រាស់ថវិការដ្ឋ និងថវិកាពីប្រភពម្ចាស់ជំនួយផ្សេងទៀតដូចជាៈ ថវិកា SIG និងថវិកាសប្បុរសជនផ្សេងៗជាដើមសម្រាប់យកមកប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ និងកែលម្អសាលារៀនឱ្យមានការរីកចម្រើន។ ជាមួយគ្នានេះ អ្នកចូលរួមទាំងអស់មានការយល់ដឹងគ្រប់ៗគ្នាថា រដ្ឋ និងម្ចាស់ជំនួយមួយចំនួនតែងតែទម្លាក់ថវិកាដល់វិទ្យាល័យទាំងអស់នៅទូទាំងប្រទេសជារៀងរាល់ឆ្នាំ សម្រាប់យកមកប្រើប្រាស់ដើម្បីធ្វើការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងគុណភាពស្ថាប័ន ក៏ដូចជាពង្រឹងការផ្តល់សេវាកម្មដែលកត្តាទាំងនេះជំរុញឱ្យបុគ្គលិកអប់រំទាំងអស់នោះមានការយល់ដឹង និងផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការរៀបចំ ការអនុវត្ត និងការតាមដានត្រួតនិពិត្យលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនជាងផែនការដទៃទៀត។ សម្រាប់ផែនការយុទ្ធសាស្ត្រ និងផែនការថវិកា ក្រាហ្វិកបានបង្ហាញថា អ្នកចូលរួមមានការយល់ដឹងតិចតួចនៅឡើយ ដោយសារមានអ្នកចូលរួមត្រឹមតែ ៣៣%ប៉ុណ្ណោះដែលដឹងថា វិទ្យាល័យនីមួយៗមានរៀបចំផែនការយុទ្ធសាស្ត្រ ហើយត្រឹមតែ ៤១.៥%ប៉ុណ្ណោះដែលមានការយល់ដឹងទាក់ទងនឹងការរៀបចំផែនការថវិកា ហើយភាគច្រើនដឹងតាមរយៈការប្រជុំផ្សព្វផ្សាយរបស់គណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះ ដោយមិនបានចូលរួមរៀបចំដោយផ្ទាល់នោះទេ។ ជាទូទៅ អ្នកចូលរួមភាគច្រើនបង្ហាញពីភាពមិនយល់ច្បាស់ពីផែនការយុទ្ធសាស្ត្ររបស់សាលារៀន ហើយមិនតែប៉ុណ្ណោះ ពួកគាត់មួយចំនួនធំគិតថាផែនការនេះ មិនត្រូវបានរៀបចំទេ សម្រាប់វិទ្យាល័យដែលពួកគាត់កំពុងបម្រើការងារ។ ចំណែកឯ ផែនការថវិកាភាគច្រើនត្រូវបានរៀបចំដោយគណៈគ្រប់គ្រងសាលា ពិសេសនាយក/នាយិកាសាលា និងមន្ត្រីគណនេយ្យ ដោយមិនមានការចូលរួមទូលំទូលាយប្រកបដោយតម្លាភាពពីអ្នកពាក់ព័ន្ធ ព្រមទាំងមិនបានធ្វើការប្រជុំផ្សព្វផ្សាយ និងចែករំលែកព័ត៌មានឱ្យបានច្បាស់លាស់នោះទេ ដែលទាំងនេះជាមូលហេតុចម្បងធ្វើឱ្យអ្នកចូលរួមមានការយល់ដឹងតិចតួច។ ជាទូទៅ យើងឃើញថា គណៈគ្រប់គ្រងសាលាភាគច្រើនមិនបានបង្ហាញឱ្យបានច្បាស់លាស់ពីគម្រោងផែនការថវិកាដល់អ្នកពាក់ព័ន្ធ ហើយភាគច្រើនបង្ហាញត្រឹមតែសកម្ម

ភាពដែលត្រូវអនុវត្តនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន និងតួលេខថវិកាធំៗមួយចំនួនតែប៉ុណ្ណោះ។ សម្រាប់ផែនការប្រតិបត្តិប្រចាំឆ្នាំ អ្នកចូលរួមចំនួន ៥៣.៤%បានបង្ហាញពីការយល់ដឹងលើការរៀបចំផែនការនេះជាប្រក្រតីរៀងរាល់ឆ្នាំសម្រាប់សកម្មភាពណាដែលអនុវត្តដដែលៗដូចជា៖ ការចុះឈ្មោះសិស្សថ្មី ការបែងចែកសិស្សតាមថ្នាក់ ការរៀបចំវេនសម្អាត ពលកម្មវេនយាម និងការធ្វើរបាយការណ៍...ជាដើម។

ជារួម ក្នុងចំណោមផែនការនានាដែលលើកឡើងខាងលើនេះ យើងខ្ញុំផ្តោតតែលើការសិក្សាពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន សម្រាប់ការសិក្សាស្រាវជ្រាវនេះដែលយើងខ្ញុំគិតថា វាជាផែនការដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀនពីមួយឆ្នាំទៅមួយឆ្នាំ ហើយអ្នកចូលរួមមានការយល់ដឹងច្រើនជាងគេ។

*រូបទី៤.១ ការយល់ដឹងពីការរៀបចំផែនការនានានៅតាមវិទ្យាល័យគោលដៅ*




### ខ-ការយល់ដឹងពីផែនការអភិវឌ្ឍន៍សាលារៀន

បន្ទាប់ពី យើងធ្វើការវិភាគទៅលើកម្រិតយល់ដឹងពីការរៀបចំផែនការនានានៅតាមវិទ្យាល័យនីមួយៗ យើងឃើញថាផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានអ្នកចូលរួមមានការយល់ដឹងច្រើនជាងគេ តាមរយៈការចូលរួមរៀបចំ និងការប្រជុំផ្សព្វផ្សាយរបស់គណៈគ្រប់គ្រងសាលា។ យោងតាមរូបទី៤.២ខាងក្រោមនេះ យើងនឹងបង្ហាញពីកម្រិតយល់ដឹងទាក់ទងនឹងខ្លឹមសារ និងសកម្មភាពនានាដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននីមួយៗ ទោះបីពួកគាត់ចូលរួមរៀបចំដោយផ្ទាល់ ដោយប្រយោល ឬយល់ដឹងតាមរយៈការប្រជុំផ្សព្វផ្សាយក៏ដោយ។ យើងបានដាក់បញ្ចូលនូវសំណួរសំខាន់មួយនៅក្នុងកម្រងសំណួរដោយផ្តល់ជម្រើសដល់អ្នកចូលរួមទាំងអស់ រួមមាន៖ គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងលោកគ្រូ-អ្នកគ្រូនៅតាមវិទ្យាល័យដែលស្ថិតនៅស្រុក/ក្រុងទាំង៨ក្នុងខេត្តស្វាយរៀង ធ្វើការជ្រើសរើសចម្លើយណាមួយក្នុងចំណោមលំដាប់ចម្លើយទាំងប្រាំលើកម្រិតយល់ដឹងទាក់ទងនឹងផែនការអភិវឌ្ឍន៍សាលារៀនពីកម្រិតមិនយល់ដឹងសោះ យល់ដឹងតិចតួច យល់ដឹងមធ្យម យល់ដឹងច្រើន និងយល់ដឹងច្រើនណាស់។ ជាមួយគ្នានេះ យើងបានកំណត់ពិន្ទុពីកម្រិតទាប ទៅកម្រិតខ្ពស់ ពោលគឺយើងបានកំណត់ពិន្ទុ១ សម្រាប់កម្រិតមិនយល់ដឹងសោះ ពិន្ទុ២សម្រាប់ការយល់ដឹងតិចតួច ពិន្ទុ៣ សម្រាប់ការយល់ដឹងកម្រិតមធ្យម ពិន្ទុ៤ សម្រាប់កម្រិតយល់ដឹងច្រើន និងចុងក្រោយកំណត់ពិន្ទុ៥ សម្រាប់កម្រិតយល់ដឹងច្រើនណាស់។ បន្ទាប់មក យើងធ្វើការគណនារកមធ្យមភាគកម្រិតយល់ដឹងទាក់ទងនឹងខ្លឹមសារ និងសកម្មភាពដែលមាននៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនទាំងនោះ។

យោងតាមក្រាហ្វិកនៅក្នុងរូបទី៤.២ វាបង្ហាញថា ក្រុងស្វាយរៀងទទួលបានពិន្ទុមធ្យមភាគ ៣.១៧ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុករំដួលទទួលបានពិន្ទុ ៣.២៧ ដែលជាមធ្យមភាគស្ថិតនៅកម្រិតមធ្យម ស្រុករមាសហែកទទួលបានពិន្ទុ ៣.២៤ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ក្រុងបាវិតទទួលបានពិន្ទុ ៣.៤៨ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុកស្វាយជ្រំទទួលបានពិន្ទុ ៣.០៥ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុកកំពង់រោទ៍ទទួលបានពិន្ទុ ៣.២៥ ជាពិន្ទុស្ថិតនៅក្នុងកម្រិតមធ្យម ស្រុកស្វាយទាបទទួលបានពិន្ទុ ៣.១៩ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម និងចុងក្រោយ ស្រុកចន្ទ្រាទទួលបានពិន្ទុ

២.៦៨ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតយល់ដឹងតិចតួច។ ជារួម ក្នុងចំណោមស្រុក/ក្រុងទាំង ០៨ មានស្រុក/ក្រុងចំនួន០៧ទទួលបានពិន្ទុមធ្យមភាគកម្រិតយល់ដឹងមធ្យម និងមានតែ០១ ស្រុកប៉ុណ្ណោះគឺ ស្រុកចន្ទ្រាដែលមានពិន្ទុមធ្យមភាគទាបជាងគេស្ថិតនៅក្នុងកម្រិតយល់ដឹង តិចតួច ហើយមធ្យមភាគសរុបសម្រាប់ខេត្តស្វាយរៀងទាំងមូលទទួលបានពិន្ទុត្រឹមតែ៣.១៩ ជាលំដាប់ពិន្ទុមធ្យមភាគស្ថិតនៅក្នុងកម្រិតយល់ដឹងមធ្យម។

យោងតាមស្ថិតិនេះ សបញ្ជាក់ឱ្យឃើញថា កម្រិតយល់ដឹងរបស់អ្នកចូលរួមទាំងអស់ពី ខ្លឹមសារ និងសកម្មភាពនានាដែលបានគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ស្ថិតនៅ ក្នុងកម្រិតមធ្យម ដោយសារអ្នកចូលរួមមួយចំនួនធំមិនបានចូលរួមក្នុងដំណើរការរៀបចំផែន ការនេះដោយផ្ទាល់ ហើយការផ្សព្វផ្សាយក៏នៅមិនទាន់អនុវត្តបានទូលំទូលាយ។ ម៉្យាងវិញ ទៀត ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅមួយចំនួនមិនបានផ្ត ល់ឱកាសពេញលេញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ពោលគឺរៀបចំឡើងដោយមនុស្ស មួយក្រុម ក្នុងនោះមានគណៈគ្រប់គ្រង និងមន្ត្រីរដ្ឋបាល/គណនេយ្យ ហើយនេះជាមូលហេតុ ចម្បង ដែលធ្វើឱ្យកម្រិតយល់ដឹងពីផែនការនេះនៅមិនទាន់បានល្អប្រសើរនៅឡើយ ព្រមទាំង មិនទាន់ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់វិទ្យាល័យនីមួយៗ។

*រូបទី៤.២ កម្រិតនៃការយល់ដឹងពីខ្លឹមសារ និងសកម្មភាពដែលគ្រោងនៅក្នុងផែនការ អភិវឌ្ឍន៍សាលារៀន*




បន្ទាប់ពីយើងធ្វើការសិក្សា និងវិភាគពីកម្រិតយល់ដឹងរបស់អ្នកចូលរួមទាំងអស់ពីខ្លឹមសារ និងសកម្មភាពនានាដែលបានគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន យើងក៏ធ្វើការសិក្សា និងវិភាគផងដែរពីកម្រិតយល់ដឹងរបស់អ្នកចូលរួមដោយធ្វើការបែងចែកទៅតាមប្រភេទតួនាទី។ ផ្នែកនេះ យើងចង់ដឹងថាតើ គណៈគ្រប់គ្រងសាលាមានការយល់ដឹងកម្រិតណា ហើយមន្ត្រីការិយាល័យរដ្ឋបាល និងគណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងគ្រូបង្រៀនមានការយល់ដឹងកម្រិតណា។ បន្ទាប់មកយើងធ្វើការសិក្សាប្រៀបធៀបពីកម្រិតយល់ដឹងរបស់អ្នកចូលរួមទាំងនោះតាមប្រភេទនីមួយៗ។ ជាមួយគ្នានេះដែរ យើងក៏ធ្វើការវិភាគទៅលើកម្រិតខុសៗគ្នារបស់អ្នកចូលរួម និងធ្វើការវិភាគទៅលើមូលហេតុចម្បងៗដែលធ្វើឱ្យកម្រិតយល់ដឹងរបស់ពួកគាត់ខុសគ្នា។

យោងតាមរូបទី៤.៣ យើងឃើញថា គណៈគ្រប់គ្រងសាលាដែលមាននាយក/នាយិកា និងនាយករង /នាយិការងមានការយល់ដឹងទាក់ទងនឹងខ្លឹមសារ និងសកម្មភាពនានាដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនទទួលបានពិន្ទុមធ្យមភាគចំនួន៣.៥០ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតល្អ ហើយមន្ត្រីរដ្ឋបាល/គណនេយ្យទទួលបានពិន្ទុមធ្យមភាគ ៤.០០

ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតល្អ។ ចំណែកឯ ថ្នាក់ដឹកនាំក្រុមបច្ចេកទេសទទួលបាន ពិន្ទុមធ្យមភាគ ៣.៣០ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម និងគ្រូបង្រៀនទទួលបាន ពិន្ទុមធ្យមភាគ ៣.១០ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម។

ក្នុងចំណោមអ្នកចូលរួមទាំងអស់ មន្ត្រីរដ្ឋបាល/គណនេយ្យមានកម្រិតយល់ដឹងខ្ពស់ ជាងគេទាក់ទងនឹងផែនការអភិវឌ្ឍន៍សាលារៀន ដោយសារមន្ត្រីទាំងនេះបានចូលរួមផ្ទាល់ក្នុង ដំណើរការរៀបចំផែនការ ដំណើរការអនុវត្តផែនការ ការរៀបចំជម្រះបញ្ជីស្នាមផ្សេងៗ និងការ រៀបចំប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា។ ចំណែកឯ គណៈគ្រប់គ្រងសាលារៀនដែល មាននាយក/នាយិកា និងនាយករង/នាយិការងមានកម្រិតយល់ដឹងលើមធ្យម ដោយខ្ពស់ជាង ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ក្នុងចំណោមអ្នកចូលរួមដែលមានតួនាទីជាគ ណៈគ្រប់គ្រងសាលា នាយក/នាយិកាបានបង្ហាញពីការយល់ដឹងពីខ្លឹមសារ និងសកម្មភាព ដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនបានល្អជាងអ្នកចូលរួមដែលមានតួនាទី ជានាយករង/នាយិការង។ នាយករង/នាយិការងមួយចំនួនបានបង្ហាញពីការយល់ដឹងត្រឹម កម្រិតមធ្យម ដោយសារអ្នកខ្លះមិនបានចូលរួមក្នុងដំណើរការរៀបចំ ការអនុវត្ត និងការតាម ដានត្រួតពិនិត្យការអនុវត្តផែនការនោះទេ។ មួយវិញទៀត ក្នុងចំណោមអ្នកចូលរួមទាំងអស់ គ្រូបង្រៀនមានពិន្ទុមធ្យមភាគតិចជាងគេ ដោយសារគ្រូបង្រៀនមួយចំនួនធំមិនបានចូលរួម ក្នុងដំណើរការរៀបចំ និងអនុវត្តនោះទេ ហើយភាគច្រើនមានការយល់ដឹងតាមរយៈការប្រជុំ ផ្សព្វផ្សាយតែប៉ុណ្ណោះ។ ជារួម យោងតាមស្ថិតិខាងលើនេះ វាបង្ហាញថា ការយល់ដឹងពីខ្លឹមសារ និងសកម្មភាពនានាដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នកចូលរួមទាំងអស់ មានកម្រិតមិនស្មើគ្នាទេ អាស្រ័យដោយកម្រិតនៃការចូលរួមក្នុងដំណើរការរៀបចំ អនុវត្ត និង ការតាមដានត្រួតពិនិត្យ វាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការទាំងនោះ ព្រមទាំងកម្រិត នៃការប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា។

*រូបទី៤.៣ កម្រិតយល់ដឹងទាក់នឹងនឹងផែនការអភិវឌ្ឍន៍សាលារៀនបែងចែកតាមតួនាទី អ្នកចូលរួម*




## គ-អ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

ដើម្បីរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមួយប្រកបដោយប្រសិទ្ធភាព និងគុណភាពគឺទាមទារឱ្យមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយ ពីអ្នកពាក់ព័ន្ធនានាដូចជាៈ គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស គ្រូបង្រៀន សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស អាណាព្យាបាល សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់បែបនេះ ផ្តល់អត្ថប្រយោជន៍ច្រើនក្នុងការរៀបចំផែនការដែលអាចប្រមូលបានព័ត៌មានគ្រប់ជ្រុងជ្រោយ កំណត់បានបញ្ហាប្រឈមជាអាទិភាព និងរួមគ្នាស្វែងរកដំណោះស្រាយសមស្របដែលឆ្លើយតបនឹងតម្រូវការ និងធនធានជាក់ស្តែង។ មួយវិញទៀត ផែនការអភិវឌ្ឍន៍សាលារៀនដែលរៀបចំឡើង ដោយមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយបែបនេះនឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធទាំងនោះដែលជាកត្តាសំខាន់ក្នុងការធ្វើឱ្យការអនុវត្តទទួលបានជោគជ័យ។ ជាមួយគ្នានេះ វាក៏ចូលរួមចំណែកចម្បងផងដែរក្នុងការកសាងទំនាក់ទំនងល្អ និងកិច្ចសហការធ្វើការរួមគ្នាដើម្បីឱ្យស្ថាប័នមានការរីកចម្រើន ជាពិសេសឆ្លើយតបទៅនឹងបរិបទអប់រំបែបបរិយាប័ន្ននា

ពេលបច្ចុប្បន្នក៏ដូចជាទៅអនាគតដែលក្រសួងបាននឹងកំពុងយកចិត្តទុកដាក់តាមរយៈការជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ។ សម្រាប់ផ្នែកនេះ យើងនឹងសិក្សា និងវិភាគពីកម្រិតនៃការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។

យោងតាមរូបទី៤.៤ យើងឃើញថា នាយក/នាយិកាបានចូលរួមពេញលេញក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ក្នុងនោះអ្នកចូលរួមឆ្លើយសំណួរចំនួន ៣១១នាក់ ស្មើនឹង១០០%បានបង្ហាញពីកម្រិតនៃការចូលរួមរបស់នាយក/នាយិកាសាលា ហើយអ្នកចូលរួមចំនួន២៤២នាក់ ស្មើនឹង៧៧.៨%បានផ្តល់ចម្លើយវិជ្ជមានពីការចូលរួមរបស់នាយករង/នាយិការងក្នុងការរៀបចំផែនការនេះដែរដែលនេះបញ្ជាក់ថា មាននាយករង/នាយិការងមួយចំនួនក៏មិនត្រូវបានគេផ្តល់ឱកាសឱ្យចូលរួមក្នុងដំណើរការរៀបចំ ការអនុវត្ត និងការតាមដានត្រួតពិនិត្យ វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការនោះទេ។ ជាមួយគ្នានេះ អ្នកចូលរួមចំនួន១៥១នាក់ ស្មើនឹង ៤៥.៣%បានបង្ហាញពីការចូលរួមរបស់មន្ត្រីរដ្ឋបាល/គណនេយ្យក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ហើយអ្នកចូលរួមចំនួន២០០នាក់ ស្មើនឹង៦៤.៣%បានផ្តល់ចម្លើយពីការចូលរួមរបស់ប្រធានក្រុម/អនុប្រធានក្រុមបច្ចេកទេសក្នុងដំណើរការរៀបចំផែនការខាងលើ ព្រមទាំងអ្នកចូលរួមត្រឹមតែ១០៥នាក់ប៉ុណ្ណោះ ស្មើនឹង៣៣.៨%ដែលបង្ហាញពីការចូលរួមរបស់គ្រូបង្រៀនក្នុងដំណើរការរៀបចំ។ នេះបញ្ជាក់ថាការចូលរួមរបស់គ្រូបង្រៀននៅតិចតួចនៅឡើយ។ មួយវិញទៀត យើងក៏រកឃើញផងដែរថា អ្នកចូលរួមឆ្លើយសំណួរមានចំនួនតិចតួចប៉ុណ្ណោះដែលបានផ្តល់ចម្លើយពីការចូលរួមរបស់សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស ប្រជាពលរដ្ឋសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្នុងនោះអ្នកចូលរួមមានតែ២៧នាក់ ស្មើនឹង៨.៧%ដែលបង្ហាញពីការចូលរួមរបស់សិស្សានុសិស្សក្នុងការរៀបចំ ហើយអ្នកចូលរួមចំនួន៧៥នាក់ ស្មើនឹង២៤.១%បានបង្ហាញពីការចូលរួមរបស់ក្រុមប្រឹក្សា/គណៈកម្មការនានា ព្រមទាំងអ្នកចូលរួមឆ្លើយសំណួរត្រឹមតែចំនួន៣០នាក់ប៉ុណ្ណោះ ស្មើនឹង៩.៦%ដែលបង្ហាញពីការចូលរួមរបស់មាតាបិតាសិស្ស។ សម្រាប់ស្ថិតិចុងក្រោយ អ្នកចូលរួមឆ្លើយសំណួរចំនួន៣៣នាក់ ស្មើនឹង១០.៦% បានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋសហគមន៍ ហើយ

អ្នកចូលរួមចំនួន៣៧នាក់ ស្មើនឹង១១.៩% បង្ហាញពីការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងដំណើរការរៀបចំផែនការនេះ។

យោងតាមស្ថិតិនេះ បង្ហាញឱ្យឃើញថា មានតែនាយក/នាយិកាវិទ្យាល័យតែប៉ុណ្ណោះដែលបានចូលរួមបានពេញលេញ ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ហើយនាយករង/នាយិការង និងថ្នាក់ដឹកនាំក្រុមបច្ចេកទេសមានការចូលរួមពិគ្រោះយោបល់បានច្រើនគួរសមពោលគឺច្រើនជាងពាក់កណ្តាលនូវចម្លើយរបស់អ្នកចូលរួមទាំងអស់។ ចំណែកឯអ្នកពាក់ព័ន្ធដទៃទៀតដូចជា៖ មន្ត្រីរដ្ឋបាល/គណនេយ្យ គ្រូបង្រៀន សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានមានការចូលរួមតិចតួចនៅឡើយ។ ជាទូទៅ វិទ្យាល័យនីមួយៗផ្តល់ឱកាសតិចតួចបំផុតដល់សិស្សានុសិស្សក្នុងការពិគ្រោះយោបល់ចូលរួមចំណែកអភិវឌ្ឍន៍សាលារៀន។ ការមិនផ្តល់ឱកាសដល់សិស្សានុសិស្សបង្ហាញពីបញ្ហាប្រឈម និងតម្រូវការចាំបាច់របស់ពួកគាត់ អាចនាំឱ្យការវាយតម្លៃលើគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាកម្មអប់រំមិនមានសុក្រឹតភាពល្អព្រមទាំងមិនអាចធ្វើឱ្យសាលារៀនមានការកែលម្អ និងដោះស្រាយបញ្ហាប្រឈមឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អ្នកទទួលសេវាកម្ម។ យោងតាមការបកស្រាយខាងលើ បញ្ជាក់យ៉ាងច្បាស់ថា ការចូលរួមពិគ្រោះយោបល់ក្នុងចំណោមអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន នៅមិនទាន់ទូលំទូលាយនៅឡើយ ជាពិសេសមាតាបិតាសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា សហគមន៍ និងអាជ្ញាធរមូលដ្ឋានមានការចូលរួមតិចតួចបំផុត ដែលករណីនេះ បង្ហាញឱ្យឃើញថា ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍នៅមានកម្រិតដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមសម្រាប់វិទ្យាល័យទាំងអស់នៅក្នុងខេត្តស្វាយរៀង។ ជាលទ្ធផល យើងអាចវាយតម្លៃបានថា ផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំឡើង មិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែង និងតម្រូវការរបស់អ្នកពាក់ព័ន្ធទាំងអស់នោះទេ។

*រូបទី៤.៤ ភាគរយអ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន*




## ៤.២ ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

### ក-របៀបនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

សម្រាប់ផ្នែកនេះ យើងធ្វើការសិក្សាស្រាវជ្រាវពីរបៀបនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅនីមួយៗ ថាតើវាសមស្របទៅនឹងនីតិវិធីដែលក្រសួងបានកំណត់ដែរឬអត់។ យើងធ្វើការរាប់ចម្លើយរបស់អ្នកចូលរួមទាំងអស់ រួចធ្វើការគណនាជាភាគរយចំពោះនីតិវិធីដែលវិទ្យាល័យនីមួយៗបានអនុវត្តសម្រាប់ការរៀបចំផែនការ ហើយចុងក្រោយយើងធ្វើការវិភាគទៅលើចម្លើយទាំងអស់នោះ។ ជាមួយគ្នានេះ យើងបានផ្តល់ជម្រើសចម្លើយជាច្រើនសម្រាប់អ្នកចូលរួមធ្វើការជ្រើសរើសលើនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍

សាលារៀន ដែលជម្រើសទាំងអស់នោះមាន (១) នាយកជាអ្នករៀបចំផែនការទាំងស្រុង នាយករងជាអ្នករៀបចំទាំងស្រុង (២) រដ្ឋបាល/គណនេយ្យជាអ្នករៀបចំទាំងស្រុង (៣) គណៈគ្រប់គ្រងសាលា (នាយក/នាយិកា-នាយករង/នាយិការង) ជាអ្នករៀបចំ រួចធ្វើការប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀនដទៃទៀត (៤) រៀបចំដោយគណៈគ្រប់គ្រងសាលា ព្រមទាំងមានការចូលរួមពីគ្រូបង្រៀនមួយចំនួន (៥) ប្រជុំពិភាក្សាគ្នារវាងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនទាំងអស់ (៦) រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ មានដូចជា៖គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន និងសិស្សានុសិស្ស...ជាដើម)

យោងតាមរូបទី៤.៥ យើងឃើញថា ផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានរៀបចំទៅតាមបែបផែនផ្សេងៗ ក្នុងនោះអ្នកចូលរួមចំនួន៣៨នាក់ ស្មើនឹង ១២%បានឆ្លើយថា នាយកសាលាជាអ្នករៀបចំផែនការនេះទាំងស្រុង ហើយអ្នកចូលរួមចំនួន១២២នាក់ ស្មើនឹង៣៩% បានឆ្លើយថា គណៈគ្រប់គ្រងសាលាជាអ្នករៀបចំ រួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀនជាក្រោយ និងអ្នកចូលរួមចំនួន៧០នាក់ ស្មើនឹង២៣%បានឆ្លើយថា ដំណើរការរៀបចំផែនការមានការចូលរួមពិគ្រោះយោបល់ពីសំណាក់គ្រូបង្រៀនមួយចំនួនតែប៉ុណ្ណោះ។ មួយវិញទៀត អ្នកចូលរួមចំនួន៤៩នាក់ ស្មើនឹង១៦% បានឆ្លើយថា ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយពីគ្រូបង្រៀនទាំងអស់ ហើយអ្នកចូលរួមចំនួន៣២នាក់ ស្មើនឹង១០% ឆ្លើយថា ដំណើរការរៀបចំមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ក្នុងនោះមាន គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស ប្រជាពលរដ្ឋសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

យោងតាមស្ថិតិនេះ បង្ហាញឱ្យឃើញថា ផែនការអភិវឌ្ឍន៍សាលារៀនភាគច្រើនត្រូវបានរៀបចំដោយគណៈគ្រប់គ្រងសាលា ដោយមានការពិគ្រោះយោបល់តិចតួចជាមួយអ្នកពាក់ព័ន្ធដទៃទៀត។ អ្វីដែលគួរឱ្យកត់សម្គាល់ តាមរយៈការសម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលា ផែនការអភិវឌ្ឍន៍សាលារៀនដែលត្រូវអភិវឌ្ឍឡើងនោះគឺចម្លងតាមគម្រូដែលមន្ទីរ

អប់រំ យុវជន និងកីឡាខេត្តបានបណ្តុះបណ្តាល និងផ្តល់គម្រូដើម្បីរៀបចំនៅតាមវិទ្យាល័យទូទៅនៅក្នុងខេត្ត ហើយមានលក្ខណៈប្រហាក់ប្រហែលគ្នាពីវិទ្យាល័យមួយទៅវិទ្យាល័យមួយពិសេសទាក់ទងទៅនឹងចំណុចមួយចំនួនដូចជា ដើមឈើបញ្ហា ដើមឈើវត្ថុបំណង និងតារាងម៉ាទ្រិកផែនការគម្រោងជាដើម។ សម្រាប់ចម្លើយរបស់អ្នកចូលរួមដែលបានឆ្លើយថា ផែនការអភិវឌ្ឍន៍ត្រូវបានរៀបចំដោយមានការចូលរួមពីគ្រូបង្រៀនទាំងអស់ គឺអនុវត្តមិនត្រឹមត្រូវតាមនីតិវិធីទេ ហើយវាមានលក្ខណៈប្រហាក់ប្រហែលនឹងការរៀបចំដោយគណៈគ្រប់គ្រងសាលារួចផ្សព្វផ្សាយដល់គ្រូបង្រៀនដែរ ព្រោះសកម្មភាពជាច្រើនត្រូវបានស្នើឡើងដោយគណៈគ្រប់គ្រងសាលា រួចទើបយកសកម្មភាពទាំងនោះទៅឆ្លងអង្គប្រជុំដើម្បីពិភាក្សា និងសម្រេចជាក្រោយដែលវាមានលក្ខណៈជាការកំណត់ជម្រើសសកម្មភាពទុកជាមុន ហើយការប្រជុំទាំងនោះគ្រាន់តែពិភាក្សាលើរបៀបវារៈដែលមានស្រាប់តែប៉ុណ្ណោះ។ នីតិវិធីនៃការរៀបចំបែបនេះមានលក្ខណៈល្អជាងផែនការដែលបានរៀបចំឡើងហើយ ទើបផ្សព្វផ្សាយជាក្រោយ ព្រោះវាមានការពិភាក្សាពិគ្រោះយោបល់ខ្លះៗ ហើយគ្រូបង្រៀនទាំងអស់បានទទួលព័ត៌មាន និងពិភាក្សាពីសកម្មភាពទាំងនោះ ព្រមទាំងបានធ្វើការសម្រេចចិត្តរួមគ្នាដែលជាចំណុចស្នូលនៃការឯកភាពផ្ទៃក្នុង។ សម្រាប់ស្ថិតិចុងក្រោយ អ្នកចូលរួមបានផ្តល់ចម្លើយបញ្ជាក់ពីនីតិវិធីរៀបចំផែនការអភិវឌ្ឍន៍សាលារៀន មានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ត្រឹមតែ១០% ប៉ុណ្ណោះ ដែលជាភាគរយតិចតួចបំផុត និងឆ្លុះបញ្ចាំងពីបញ្ហាប្រឈមទាក់ទងទៅនឹងការអនុវត្តនីតិវិធីរៀបចំផែនការដែលត្រូវធ្វើការកែលម្អឱ្យបានល្អប្រសើរដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗ។ សម្រាប់នីតិវិធីនៃការរៀបចំផែនការបែបនេះ វាត្រូវអនុវត្តតាមរយៈការប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធទាំងអស់ ធ្វើការរួមគ្នាក្នុងការកំណត់បញ្ហាប្រឈមជាអាទិភាព និងសហការគ្នាស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

ជារួម ផ្អែកតាមស្ថិតិ និងអំណះអំណាងខាងលើនេះ វាបង្ហាញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍន៍និងកែលម្អសាលារៀន ដោយសារការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនមានការចូលរួមទូលំទូលាយប្រកបដោយតម្លាភាព ដែលនាំឱ្យកង្វះការគាំទ្រ និងការកើនឡើងនូវភាពមិនពេញចិត្ត ព្រមទាំងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែង

របស់អ្នកពាក់ព័ន្ធដទៃទៀត។ មួយវិញទៀត ការរៀបចំផែនការបែបនេះ នាំឱ្យមានភាពមិនទុកចិត្ត និងជឿជាក់គ្នាក្នុងចំណោមបុគ្គលិកអប់រំទាំងអស់ដែលជាកត្តាចម្បងនាំឱ្យមានការបែកបាក់ផ្ទៃក្នុង និងធ្វើឱ្យការអនុវត្តផែនការនោះមិនទទួលបានជោគជ័យល្អ។ ជាទូទៅ យើងអាចវាយតម្លៃបានថា ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យទាំងឡាយនៅក្នុងខេត្តស្វាយរៀងដោយប្រើប្រាស់នីតិវិធីសមស្រប តាមរយៈការប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធទាំងអស់ទាក់ទងទៅនឹងការសិក្សាពីបញ្ហាប្រឈមនានា ផលប៉ះពាល់ បន្ទាប់មកកំណត់អាទិភាពបញ្ហា ប្រឈមទាំងនោះ រួចពិភាក្សារួមគ្នាក្នុងការស្វែងរកដំណោះស្រាយសមស្រប តាមរយៈការប្រជុំឆ្លុះបញ្ចាំង និងប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយប្រកបដោយតម្លាភាពមិនត្រូវបានអនុវត្តនោះទេ។

*រូបទី៤.៥ របៀបនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន*



### ខ-បញ្ហាប្រឈមសំខាន់ៗដែលវិទ្យាល័យជួបប្រទះ

សម្រាប់ការសិក្សាស្រាវជ្រាវផ្នែកនេះ យើងតម្រូវឱ្យអ្នកចូលរួមនីមួយៗធ្វើការជ្រើសរើសនូវបញ្ហាប្រឈមចំនួនបី ក្នុងចំណោមបញ្ហាដែលលើកឡើងចំនួនប្រាំបីនៅក្នុងកម្រងសំណួរ ដែលពួកគាត់គិតថាជាបញ្ហាប្រឈមជាអាទិភាពបំផុតសម្រាប់វិទ្យាល័យរបស់ពួកគាត់ផ្ទាល់។ បន្ទាប់មក យើងនឹងកំណត់ជ្រើសរើសយកបញ្ហាប្រឈមសំខាន់ៗចំនួនពាក់កណ្តាលដែលមានប្រេកង់ខ្ពស់ទៅតាមលំដាប់លំដោយ ពោលគឺបញ្ហាអាទិភាពចំនួន៤ក្នុងចំណោម៨ដែលមានភាគរយខ្ពស់ជាងគេ សម្រាប់យកមកធ្វើការវិភាគ។

យោងតាមរូបទី៤.៦ យើងឃើញថា អ្នកចូលរួមចំនួន១០៧នាក់ ស្មើនឹង៣៤.៤%បានកំណត់ថា បញ្ហាបរិស្ថានសាលារៀនជាបញ្ហាប្រឈមសំខាន់របស់សាលារៀន ហើយអ្នកចូលរួមចំនួន១៥៧នាក់ ស្មើនឹង៥០.៥% បានកំណត់ថា ការសាងសង់ ឬជុសជុលសម្ភារៈ និងគ្រឿងបរិក្ខារខ្នាតតូចជាបញ្ហាប្រឈមចាំបាច់ដែលត្រូវដោះស្រាយបន្ទាន់។ មួយវិញទៀត អ្នកចូលរួមចំនួន១១០នាក់ ស្មើនឹង៣៥.៤%បានកំណត់ថា សមត្ថភាពគ្រូបង្រៀននៅមានកម្រិតលើជំនាញមួយចំនួនដែលត្រូវការបណ្តុះបណ្តាល និងបំប៉នសមត្ថភាពបន្ថែមជាចាំបាច់ដើម្បីអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈឱ្យកាន់តែប្រសើរឡើង ហើយអ្នកចូលរួមចំនួន៤៩នាក់ ស្មើនឹង១៥.៨% បានកំណត់ថា កង្វះសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងការិយាល័យជាបញ្ហាប្រឈមជាអាទិភាពសំខាន់។ ជម្រើសមួយទៀត អ្នកចូលរួមចំនួន១៤៥នាក់ ស្មើនឹង៤៦.៦%បានកំណត់ថា បញ្ហាកង្វះសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀនជាបញ្ហាប្រឈមសំខាន់បំផុតដែលត្រូវដាក់បញ្ចូលជាចាំបាច់នៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ហើយអ្នកចូលរួមចំនួន៧២នាក់ ស្មើនឹង២៣.២% បានជ្រើសរើសថា បញ្ហាកង្វះបង្គន់អនាម័យ និងទឹកស្អាតជារឿងសំខាន់។ សម្រាប់ចំណុចចុងក្រោយ អ្នកចូលរួមចំនួន១៥៥នាក់ ស្មើនឹង៤៩.៨% បានឯកភាពជ្រើសរើសយកបញ្ហាសិស្សមិនសូវយកចិត្តទុកដាក់រៀនជាបញ្ហាប្រឈមសំខាន់ជាងគេ ដែលទាមទារដំណោះស្រាយ និងដាក់បញ្ចូលវិធានការនានានៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ហើយ

អ្នកចូលរួមចំនួន៦៣នាក់ ស្មើនឹង២០.៣% បានកំណត់ថា បញ្ហាសិស្សបោះបង់ការសិក្សា និងរៀនត្រួតថ្នាក់ជាបញ្ហាអាទិភាពរបស់វិទ្យាល័យ។

យោងតាមស្ថិតិនេះ យើងឃើញថា បញ្ហាប្រឈមអាទិភាពបំផុតដែលអ្នកចូលរួមទាំងអស់បានជ្រើសរើសតាមលំដាប់លំដោយសំខាន់បួននោះគឺ (១) ការសាងសង់ និងជុសជុលខ្វាតតូចនៅក្នុងសាលារៀន (២) សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រ (៣) កង្វះសម្ភារឧបទេសសម្រាប់បង្រៀន និងរៀន និង (៤) សមត្ថភាពគ្រូបង្រៀននៅមានកម្រិតដែលទាមទារយកចិត្តទុកដាក់ពង្រឹងបន្ថែម។ សម្រាប់ចម្លើយបួនផ្សេងទៀត មានភាគរយគាំទ្រតិចតួចប៉ុណ្ណោះដែលយើងគិតថា វាមិនមែនជាបញ្ហាប្រឈមជាអាទិភាពសំខាន់នោះទេ។

អ្នកចូលរួមភាគច្រើនបានបង្ហាញពីកង្វល់ខ្លាំងលើការខូចខាតសម្ភារៈ និងគ្រឿងបរិក្ខារនៅក្នុងសាលារៀន ដែលផ្តល់ការលំបាកដល់ដំណើរការបង្រៀន និងរៀន ក្នុងនោះមានដូចជាការជុសជុល តុ កៅអី ក្តារខៀន បង្អួច ទ្វារ បង្គន់...ជាដើម។ ការជុសជុលខ្វាតតូចជាតម្រូវការចាំបាច់បំផុតដែលវិទ្យាល័យនីមួយៗត្រូវយកចិត្តទុកដាក់ និងដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន។ សម្រាប់បញ្ហាប្រឈមជាអាទិភាពទីពីរគឺ សិស្សមិនសូវយកចិត្តទុករៀនសូត្រ ហើយពិតណាស់បញ្ហាប្រឈមនេះ វាជាប់ទាក់ទងនឹងបញ្ហាប្រឈមជាអាទិភាពលំដាប់ទីបីដែលលើកឡើងពីបញ្ហាកង្វះសម្ភារឧបទេសសម្រាប់បង្រៀន និងរៀន និងលំដាប់ទីបួនដែលបង្ហាញពីសមត្ថភាពគ្រូបង្រៀននៅមានកម្រិត។ សម្ភារឧបទេសសម្រាប់បង្រៀន និងរៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញលើកទឹកចិត្តសិស្សឱ្យយកចិត្តទុកដាក់ និងចូលចិត្តសិក្សារៀនសូត្រ ព្រោះការបង្រៀនដែលប្រើប្រាស់សម្ភារឧបទេសធ្វើឱ្យសិស្សងាយយល់មេរៀន ដោយសារមានលក្ខណៈរូបី និងការអនុវត្តដោយផ្ទាល់។ កង្វះសម្ភារឧបទេស ធ្វើឱ្យការបង្រៀនមិនមានភាពទាក់ទាញដល់សិស្សឱ្យមានចិត្តចង់រៀនសូត្រ និងធ្វើឱ្យសិស្សមានការលំបាកក្នុងការសម្រេចលទ្ធផលសិក្សា។ មួយវិញទៀត សិស្សមិនសូវយកចិត្តទុករៀនសូត្រកើតឡើងដោយសារភាពធូរលុងនៃការអនុវត្តវិន័យនៅតាមសាលារៀនមួយចំនួន កង្វះការគាំទ្រពីមាតាបិតា និងអាណាព្យាបាលសិស្ស កង្វះទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ កត្តាឥទ្ធិពលវប្បធម៌ពាលាអាវ៉ាសែបែបបរទេស និងភាពងុបងល់នឹងការប្រើប្រាស់បណ្តាញ

សង្គម ដូចជា Facebook ជាដើម ព្រមទាំងកត្តាផ្សេងៗទៀតជាច្រើន។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍ចុងក្រោយគឺ គ្រូបង្រៀនដែលចូលរួមឆ្លើយសំណួរភាគច្រើនបានទទួលស្គាល់ខ្លួនឯងថា សមត្ថភាពរបស់ពួកគាត់នៅមានកម្រិត ដែលវាក៏ជាផ្នែកមួយយ៉ាងសំខាន់ដែលធ្វើឱ្យសិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រ និងទទួលជោគជ័យលើការសិក្សា។ វាត្រូវបានគេទទួលស្គាល់ជាទូទៅថា គ្រូបង្រៀនដែលមិនមានសមត្ថភាពគ្រប់គ្រាន់ ពួកគាត់នឹងមិនមានវិធីសាស្ត្របង្រៀនល្អៗ ព្រមទាំងប្រើប្រាស់វាបានសមស្របក្នុងការផ្ទេរចំណេះដឹងដល់សិស្សដើម្បីឱ្យពួកគាត់សម្រេចលទ្ធផលសិក្សា។ ជាមួយគ្នានេះ គ្រូបង្រៀនដែលមិនមានចំណេះដឹងផ្នែកគរុកោសល្យក៏មិនមានសមត្ថភាពក្នុងការទាក់ទាញសិស្សឱ្យចូលចិត្ត និងចូលរួមសកម្មក្នុងការសិក្សារៀនសូត្រផងដែរ។ ផ្អែកតាមបញ្ហាប្រឈមដែលលើកឡើងខាងលើនេះ ការពង្រឹងសមត្ថភាពគ្រូបង្រៀនជាតម្រូវការចាំបាច់ដែលវិទ្យាល័យនីមួយៗត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍សាលារៀន។

ជារួមយើងកត់សម្គាល់ឃើញថា អ្នកចូលរួមឆ្លើយសំណួរទាំងអស់បានលើកឡើងពីបញ្ហាប្រឈមទាក់ទងសិស្សមិនសូវយកចិត្តទុកដាក់សិក្សាសូត្រជាអាទិភាពបំផុតទីពីរដែលកើតឡើងនៅតាមវិទ្យាល័យគោលដៅនីមួយៗ តែដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនបានផ្តល់ឱកាសដល់សិស្សានុសិស្ស ឬតំណាងក្រុមប្រឹក្សាយុវជននៅតាមវិទ្យាល័យនីមួយៗចូលរួមពិគ្រោះយោបល់ និងលើកឡើងពីបញ្ហាប្រឈម ព្រមទាំងតម្រូវការចាំបាច់របស់ពួកគាត់នោះទេ។ កត្តានេះនាំឱ្យការរៀបចំផែនការមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាអាទិភាពរបស់សាលារៀនដែលកំពុងជួបប្រទះ។ ជាចុងក្រោយ យើងអាចវាយតម្លៃបានថា សម្លេងរបស់សិស្សានុសិស្សក្នុងការចូលរួមចំណែកក្នុងការកែលម្អ និងអភិវឌ្ឍន៍សាលារៀនមិនត្រូវបានគេរាប់បញ្ចូល និងឱ្យតម្លៃនោះទេ។ កត្តាទាំងនេះវាឆ្លុះបញ្ចាំងពីការអនុវត្តនីតិវិធីមិនបានត្រឹមត្រូវក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់ដោះស្រាយបញ្ហា។

*រូបទី៤.៦ បញ្ហាប្រឈមសំខាន់ៗរបស់សាលារៀន*




## គ-សកម្មភាពសំខាន់ៗដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន

សម្រាប់ផ្នែកនេះ យើងផ្តល់ជម្រើសចម្លើយបែបពហុជ្រើសរើសដល់អ្នកចូលរួមទាំងអស់ពីសកម្មភាពសំខាន់ៗដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅនីមួយៗដើម្បីឱ្យអ្នកចូលរួមធ្វើការជ្រើសរើសចម្លើយ។ អ្នកចូលរួមអាចជ្រើសរើសចម្លើយបានច្រើនទៅតាមភាពជាក់ស្តែងដែលមាននៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនរបស់ពួកគាត់។ យើងចង់ដឹងចម្លើយដែលបញ្ជាក់ពីសកម្មភាពជាក់ស្តែងនានាដែលគ្រោងឡើងនៅក្នុងផែនការ ថាតើវាផ្តោតទៅលើសកម្មភាពសំខាន់ៗអ្វីខ្លះ រួចយើងនឹងធ្វើការសិក្សាប្រៀបធៀបជាមួយនឹងបញ្ហាប្រឈមជាអាទិភាពដែលបានលើកឡើងនៅក្នុងរូបទី៤.៦ខាងលើ ដើម្បីចង់ដឹងថាតើវាឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដែរឬទេ ព្រមទាំងចង់សិក្សាស្វែងយល់ពីកម្រិតឆ្លើយតប និងមានភាពស៊ីគ្នារវាងផ្នែកទាំងពីរនេះ។ អ្នកចូលរួមតម្រូវឱ្យជ្រើសរើសឆ្លើយសំណួរដែលបានគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនកន្លងមក បន្ទាប់មកយើងនឹងកំណត់យកសកម្មភាពដែលមានប្រេកង់ខ្ពស់ជាងគេចំនួន០៤ ក្នុងចំណោមសកម្មភាពដែល

បានស្នើឡើងចំនួន០៨ ដើម្បីធ្វើការវិភាគ និងប្រៀបធៀបជាមួយនឹងបញ្ហាប្រឈមជាអាទិភាពបំផុតដែលបានបកស្រាយនៅក្នុងចំណុច "ខ" ខាងលើ ។

យោងតាមរូបទី៤.៧ខាងក្រោម យើងឃើញថា អ្នកចូលរួមចំនួន២៥២នាក់ ស្មើនឹង៨១% បានលើកឡើងថា ផែនការអភិវឌ្ឍន៍សាលារៀនរបស់វិទ្យាល័យពួកគាត់បានផ្តោតលើការកែលម្អបរិស្ថានសាលារៀន ហើយអ្នកចូលរួមចំនួន១៩១នាក់ ស្មើនឹង៦១.៤% បានជ្រើសរើសការផ្តោតលើការសាងសង់ និងជុសជុលសម្ភារៈគ្រឿងបរិក្ខារខ្នាតតូច។ មួយវិញទៀត អ្នកចូលរួមចំនួន១៥៩នាក់ ស្មើនឹង៥១.១% បានបញ្ជាក់ថា ផែនការទាំងនោះផ្តោតជាសំខាន់ទៅលើសកម្មភាពគាំទ្រ និងអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ដូចជា គាំទ្រសកម្មភាពប្រជុំក្រុមបច្ចេកទេស ប្រជុំគរុកោសល្យ...ហើយអ្នកចូលរួមចំនួន១០៤នាក់ ស្មើនឹង៣៣.៤% បានលើកឡើងថា សកម្មភាពដែលបានគ្រោងនៅក្នុងផែនការគឺ បានផ្តោតសំខាន់ទៅលើការទិញសម្ភារៈ និងគ្រឿងបរិក្ខារសម្រាប់ប្រើប្រាស់នៅការិយល័យ។ សម្រាប់ចម្លើយពីរផ្សេងទៀត អ្នកចូលរួមចំនួន១៣៥នាក់ ស្មើនឹង៤៣.៤% បានលើកឡើងថា ផែនការអភិវឌ្ឍន៍សាលារៀនផ្តោតជាចម្បងទៅលើការទិញសម្ភារឧបទេសសម្រាប់បម្រើដល់ការបង្រៀន និងរៀន ហើយអ្នកចូលរួមចំនួន៦៦នាក់ ស្មើនឹង២១.២%បានជ្រើសរើសចម្លើយដែលឆ្លើយថា ផែនការគឺផ្តោតទៅលើសកម្មភាពណាដែលនាយកបានស្នើឡើង។ សម្រាប់ចម្លើយពីរចុងក្រោយ អ្នកចូលរួមចំនួន១១០នាក់ ស្មើនឹង៣៤.៥% បានលើកឡើងថា ផែនការត្រូវបានរៀបចំដោយផ្តោតចម្បងទៅលើសកម្មភាពទាំងឡាយណាដែលគ្រូបង្រៀនបានស្នើឡើង ហើយអ្នកចូលរួមចំនួនតែ៤៥នាក់ប៉ុណ្ណោះ ស្មើនឹង១៤.៥%ដែលជ្រើសរើសចម្លើយឆ្លើយថាផែនការត្រូវបានរៀបចំឡើងដោយផ្តោតលើសកម្មភាពទាំងឡាយណាដែលសិស្សានុសិស្សបានស្នើឡើង។

យោងតាមស្ថិតិបង្ហាញខាងលើ យើងឃើញថា សកម្មភាពចម្បងៗគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលអ្នកចូលរួមទាំងអស់បានជ្រើសរើសញឹកញាប់ជាងគេទៅតាមលំដាប់លំដោយសំខាន់បួននោះគឺ (១) ផ្តោតលើការកែលម្អបរិស្ថានសាលារៀន (២) ការសាងសង់ និងជុសជុលខ្នាតតូចនៅក្នុងសាលារៀន (៣) ការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន និង (៤) ទិញសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន។

សកម្មភាពសំខាន់ៗបំផុតដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលអ្នកចូលរួមចំនួន៨១% បានឆ្លើយគឺ ការកែលម្អបរិស្ថានសាលារៀន ដែលចំណុចនេះខុសស្រឡះពីស្ថិតិបញ្ហាប្រឈមជាអាទិភាពបំផុតនៅក្នុងចំណុច"ខ"ខាងលើ ដោយបង្ហាញថាបញ្ហាប្រឈមទាក់ទងនឹងបញ្ហាបរិស្ថានសាលារៀនមិនត្រូវបានគេចាត់ទុកថាជាបញ្ហាប្រឈមអាទិភាពបំផុតនោះទេ ហើយការដាក់បញ្ចូលសកម្មភាពនេះ គឺធ្វើឡើងដោយគណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះ។ នេះបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នារវាងបញ្ហាប្រឈមជាអាទិភាពបំផុត និងដំណោះស្រាយចាំបាច់ជាងគេក្នុងការអភិវឌ្ឍន៍សាលារៀន។ យោងតាមស្ថិតិនេះ យើងអាចវិភាគបានថា ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដោយដាក់បញ្ចូលសកម្មភាពដែលគ្រោងឡើងសំខាន់បំផុតដើម្បីដោះស្រាយបញ្ហាគឺ មិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាអាទិភាពបំផុតជាក់ស្តែងដែលអ្នកចូលរួមបានកំណត់នោះទេ ពោលគឺរៀបចំសកម្មភាពនេះឡើងដោយគណៈគ្រប់គ្រងសាលា និងមន្ត្រីមួយចំនួនតែប៉ុណ្ណោះ។ ជាមួយគ្នានេះ យើងក៏កត់សម្គាល់ឃើញផងដែរថា អ្នកចូលរួមទាំងអស់បានបង្ហាញថាឱកាសនៃការចូលរួមរបស់សិស្សានុសិស្សក្នុងការពិគ្រោះយោបល់ពីបញ្ហាប្រឈម និងតម្រូវការរបស់ពួកគាត់ ព្រមទាំងការលើកស្នើសកម្មភាពនានាដើម្បីដាក់ចូលក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅមានកម្រិតតិចតួចបំផុត គឺត្រឹមតែ១៤.៥%ប៉ុណ្ណោះ។ ដូច្នេះ ការប្រមូលព័ត៌មានពីបញ្ហាប្រឈមទាក់ទងនឹងបញ្ហាសិស្សមិនសូវយកចិត្តទុកដាក់សិក្សារៀនសូត្រ ដែលជាបញ្ហាជាអាទិភាពបំផុតទីពីរដែលបានលើកឡើងនៅក្នុងចំណុច "ខ" ខាងលើ មិនត្រូវបានពិគ្រោះយោបល់ជាមួយសិស្សទេ នាំឱ្យការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ពិសេសអ្នកទទួលសេវាកម្មអប់រំ ពិសេសគឺសិស្សានុសិស្សនេះជាដើម។ សម្រាប់សកម្មភាពដែលគ្រោងឡើងសំខាន់ៗទីពីរ ទីបី និងទី បួនពិតជាបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗ ព្រោះអ្នកចូលរួមភាគច្រើនបានលើកឡើងពីបញ្ហាប្រឈមទាក់ទងនឹង បញ្ហាការខូចខាតសម្ភារៈ និងគ្រឿងបរិក្ខារសាលារៀន កង្វះសម្ភារឧបទេសបង្រៀន និងរៀន ព្រមទាំងសមត្ថភាពគ្រូបង្រៀននៅមានកម្រិត។ ជាទូទៅសកម្មភាពលើកកម្ពស់សមត្ថភាពគ្រូបង្រៀនដែល

គ្រោងឡើងនៅតាមវិទ្យាល័យគោលដៅនីមួយៗគឺផ្តោតទៅលើការគាំទ្រសកម្មភាពប្រជុំបច្ចេកទេសតែមួយប៉ុណ្ណោះ ដោយមិនមានសកម្មភាពគ្រោងឡើងសម្រាប់ការគាំទ្រទៅលើការផ្តល់វគ្គបណ្តុះបណ្តាល ឬឧបត្ថម្ភដល់គ្រូបង្រៀនសម្រាប់ការសិក្សារៀនសូត្របន្តនោះទេ ព្រោះថវិកាមានកំណត់ មិនបានប្រមូលព័ត៌មានជាក់លាក់ និងពិភាក្សាស៊ីជម្រៅជាមួយគ្រូបង្រៀនទាំងអស់។

*រូបទី៤.៧ ផែនការអភិវឌ្ឍន៍សាលារៀនផ្តោតទៅលើសកម្មភាពចម្បងៗ*




## ឃ-កម្រិតនៃភាពពេញចិត្តចំពោះផែនការអភិវឌ្ឍន៍សាលារៀន

យើងបានសិក្សារួចមកហើយពីកម្រិតនៃការយល់ដឹងខ្លឹមសារ និងសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន។ អ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំនីតិវិធីក្នុងការរៀបចំ បញ្ហាប្រឈមជាអាទិភាពដែលវិទ្យាល័យនីមួយៗបាននឹងកំពុងជួបប្រទះ និងសកម្មភាពចាំបាច់ដែលគ្រោងឡើងនៅក្នុងផែនការ ហើយសម្រាប់ផ្នែកនេះ យើងបន្តសិក្សាពីកម្រិតនៃភាពពេញចិត្តចំពោះផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើតឡើងនៅតាមវិទ្យាល័យគោលដៅនីមួយៗ។ ផ្អែកតាមការបកស្រាយជាបន្តបន្ទាប់ខាងលើ យើងឃើញថា អ្នកចូលរួមទាំងអស់បង្ហាញពីការយល់ដឹងពីផែនការកម្រិតមធ្យម ហើយមានតែគណៈគ្រប់គ្រងសាលា និងមន្ត្រីរដ្ឋបាល/គណនេយ្យដែលបានចូលរួមរៀបចំបានពេញលេញជាងគេ។ សម្រាប់ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងគ្រូបង្រៀន ពួកគាត់មានការចូលរួមក្នុងដំណើរការរៀបចំកម្រិតមធ្យមប៉ុណ្ណោះ។ ចំណែកឯអ្នកពាក់ព័ន្ធដទៃទៀតត្រូវបានគេផ្តល់ឱកាសឱ្យចូលរួមបានតិចតួចបំផុត។ ជាមួយគ្នានេះ នីតិវិធីក្នុងការរៀបចំផែនការភាគច្រើនត្រូវបានអនុវត្តដោយមិនមានការចូលរួមទូលំទូលាយប្រកបដោយតម្លាភាពនោះទេ ហើយជាទូទៅ ផែនការនេះត្រូវបានបង្កើតឡើងដោយគណៈគ្រប់គ្រងសាលា ពិសេសនាយក/នាយិកាសាលារៀន និងមន្ត្រីរដ្ឋបាល/គណនេយ្យតែប៉ុណ្ណោះ។ សម្រាប់ផ្នែកចុងក្រោយ យើងឃើញថា ការសិក្សាពីបញ្ហាប្រឈមជាអាទិភាព និងសកម្មភាពចាំបាច់មិនមានសង្គតភាពជាមួយគ្នានោះទេ ដោយសារសកម្មភាពដែលបានគ្រោងឡើងសំខាន់ជាងគេគឺ ការកែលម្អបរិស្ថាន ហើយការសិក្សាពីបញ្ហាប្រឈមមិនបានកំណត់ថា បញ្ហាបរិស្ថានសាលារៀនជាបញ្ហាអាទិភាពនោះទេ។ ស្ថិតនៅស្ថានភាពបែបនេះ យើងនឹងសិក្សាពីកម្រិតនៃភាពពេញចិត្តរបស់អ្នកចូលរួមលើផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើតឡើងនោះ។

យោងតាមរូបទី៤.៨ វាបង្ហាញពីកម្រិតមធ្យមភាគនៃភាពពេញចិត្តរបស់អ្នកចូលរួមឆ្លើយសំណួរទាំងអស់ចំពោះផែនការដែលបានរៀបចំឡើង។ យើងបានផ្តល់ជម្រើសដល់អ្នកចូលរួមក្នុងការជ្រើសរើសចម្លើយសមស្របសម្រាប់ពួកគាត់ និងកំណត់ពិន្ទុទៅតាមចម្លើយនីមួយៗដោយកំណត់ពិន្ទុមួយសម្រាប់ការជ្រើសរើសចម្លើយកម្រិតមិនពេញចិត្តសោះ ពិន្ទុពីរសម្រាប់កម្រិតពេញចិត្តតិចតួច ពិន្ទុបីសម្រាប់កម្រិតពេញចិត្តមធ្យម ពិន្ទុបួនសម្រាប់កម្រិត

ពេញចិត្តខ្លាំង និងពិន្ទុប្រាំសម្រាប់កម្រិតពេញចិត្តខ្លាំងណាស់។ បន្ទាប់មកធ្វើការបូកសរុបពិន្ទុទៅតាមចម្លើយអ្នកចូលរួមបានជ្រើសរើស និងធ្វើប្រមាណវិធីរកមធ្យមភាគទៅតាមស្រុក/ក្រុងនីមួយៗ និងសម្រាប់ខេត្តទាំងមូលដូចការបកស្រាយខាងក្រោម៖

ផ្អែកលើក្រាហ្វិកខាងក្រោម យើងឃើញថា អ្នកចូលរួមឆ្លើយសំណួរនៅក្រុងស្វាយរៀងបង្ហាញពីភាពពេញចិត្តចំពោះផែនការអភិវឌ្ឍន៍សាលារៀន ដែលបានបង្កើតឡើងក្នុងពិន្ទុមធ្យមភាគសរុប៣.៤៦ ដែលពិន្ទុនេះស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម ស្រុករំដួលមានពិន្ទុមធ្យមភាគ៣.៦០ដែលពិន្ទុនេះស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង ស្រុករមាសហែកមានពិន្ទុ៣.៤៧ ដែលពិន្ទុនេះស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម ក្រុងបាវិតមានពិន្ទុ ៣.៩០ដែលជាពិន្ទុបញ្ជាក់ពីភាពពេញចិត្តខ្លាំង ស្រុកស្វាយជ្រំមានពិន្ទុ៣.៦៦ ដែលស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង ស្រុកកំពង់រោទ៍មានពិន្ទុ៣.៧៥ដែលជាពិន្ទុស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង ស្រុកស្វាយទាបមានពិន្ទុ៣.៣៩ ដែលជាពិន្ទុស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម និងស្រុកចន្ទ្រាមានពិន្ទុ៣.៣២ដែលជាពិន្ទុស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម។ ជារួមសម្រាប់ខេត្តស្វាយរៀងទាំងមូលទទួលបានពិន្ទុមធ្យមភាគគឺ៣.៥៩ ដែលជាពិន្ទុស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង។

អ្នកចូលរួមនៅតាមស្រុក/ក្រុង ដែលទទួលបានពិន្ទុមធ្យមភាគកម្រិតពេញចិត្តមធ្យម ដោយសារដំណើរការរៀបចំមិនមានការចូលរួមទូលំទូលាយពីអ្នកពាក់ព័ន្ធ ដើម្បីបង្កើតផែនការមួយឱ្យឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ក៏ដូចជាអ្នកពាក់ព័ន្ធ។ ជាមួយគ្នានេះពួកគាត់ក៏បានបង្ហាញពីកង្វល់ផងដែរពីតម្លាភាពនៃការរៀបចំ និងការចែករំលែកព័ត៌មានទាក់ទងទៅនឹងសកម្មភាព និងថវិកាដែលបានគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ដោយសារកង្វះភាពសហការ កង្វះការគាំទ្រ និងកង្វះការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកចូលរួមមួយចំនួនទៀត បង្ហាញពីភាពពេញចិត្តខ្លាំងពីការរៀបចំផែនការនេះឡើង ដោយសារវាមានសារៈសំខាន់ក្នុងការធ្វើឱ្យសាលារៀនមានការអភិវឌ្ឍន៍ និងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ តាមរយៈ ផែនការអភិវឌ្ឍន៍ និងការអនុវត្តផែនការទាំងនេះធ្វើឱ្យសាលារៀនមានការផ្លាស់ប្តូររីកចម្រើនទាំងផ្នែក បរិស្ថានលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន ព្រមទាំងលទ្ធផលសិក្សារបស់សិស្ស។ មួយវិញទៀត

ពួកគាត់បានលើកឡើងថា ការរៀបចំឱ្យមានផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនីមួយៗមានភាពប្រសើរជាងមិនមានផែនការ ទោះបីផែនការនោះរៀបចំឡើងដោយមិនមានការចូលរួមទូលំទូលាយក៏ដោយ ក៏វាដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យស្ថាប័នមានភាពល្អប្រសើរឡើងនិងដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលសាលារៀនបាននឹងកំពុងជួបប្រទះផងដែរ ហើយទាំងនេះជាមូលហេតុចម្បងដែលពួកគាត់បង្ហាញពីភាពពេញចិត្តខ្លាំងលើផែនការដែលបានរៀបចំកន្លងមក។

*រូបទី៤.៨ កម្រិតនៃការពេញចិត្តនឹងផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើត*




## ៤.៣ ដំណាក់កាលក្រោយរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

បន្ទាប់ពីយើងធ្វើការសិក្សាពីដំណាក់កាលរៀបចំផែនការអភិវឌ្ឍន៍សាលារៀន សម្រាប់ផ្នែកនេះ យើងនឹងធ្វើការសិក្សាពីចំណុចមួយចំនួននៅដំណាក់កាលក្រោយការរៀបចំផែនការ

អភិវឌ្ឍន៍សាលារៀន។ ការសិក្សាពីដំណាក់កាលនេះមានគោលបំណងធ្វើការសិក្សាស្រាវជ្រាវពីកម្រិតនៃការអនុវត្តសកម្មភាពដែលបានគ្រោងនៅផែនការអភិវឌ្ឍន៍សាលារៀន កម្រិតនៃភាពពេញចិត្តទៅលើការអភិវឌ្ឍសាលារៀនក្នុងអំឡុងពេល៥ឆ្នាំកន្លងមក គំនិតច្នៃប្រឌិតរបស់សាលារៀនក្នុងការដោះស្រាយបញ្ហាសម្រាប់ករណីថវិការដ្ឋទម្លាក់ឱ្យមិនបានគ្រប់តាមតម្រូវការ កម្រិតនៃការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តសកម្មភាពដល់អ្នកពាក់ព័ន្ធ និងសំណូមពរផ្សេងៗរបស់អ្នកចូលរួម ដោយយើងមិនបានធ្វើការសិក្សាស៊ីជម្រៅទៅលើរបៀបអនុវត្តសកម្មភាព នីតិវិធីនៃការប្រើប្រាស់ថវិកា ឬធ្វើការសិក្សាប្រៀបធៀបពីលទ្ធផលសម្រេចបាន ដោយធៀបទៅនឹងផែនការដែលវិទ្យាល័យនីមួយៗបានគ្រោងឡើង ដើម្បីវាយតម្លៃពីកម្រិតជោគជ័យនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំឡើងនោះទេ។ ការសិក្សាផ្នែកនេះ នឹងធ្វើការបកស្រាយជាបន្តបន្ទាប់ដូចខាងក្រោម៖

### ក-កម្រិតនៃអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន

ដើម្បីវាស់កម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន យើងបានផ្តល់ជម្រើសចម្លើយដល់អ្នកចូលរួមធ្វើការជ្រើសរើសទៅតាមភាពជាក់ស្តែង។ យើងបានកំណត់កម្រិតជាក់លាក់ និងផ្តល់ពិន្ទុនៃការអនុវត្តជាប្រាំប្រភេទខុសៗគ្នាទៅតាមលំដាប់លំដោយ ពោលគឺយើងផ្តល់ពិន្ទុមួយសម្រាប់កម្រិតមិនបានអនុវត្តសោះ ពិន្ទុពីរ សម្រាប់ការអនុវត្តបានតិចតួច ពិន្ទុបីសម្រាប់ការអនុវត្តបានមធ្យម ពិន្ទុបួនសម្រាប់ការអនុវត្តបានច្រើន និងពិន្ទុប្រាំសម្រាប់ការអនុវត្តបានច្រើនណាស់។ បន្ទាប់មក យើងនឹងធ្វើការគណនារកមធ្យមភាគនៃចម្លើយរបស់អ្នកចូលរួមទាំងអស់ និងធ្វើការវិភាគទៅលើលទ្ធផលនោះ។ យោងតាមរូបទី៤.៩ ខាងក្រោម បានបង្ហាញឱ្យឃើញពីកម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនបន្ទាប់ពីបានរៀបចំរួចមក។ បន្ទាប់មក យើងធ្វើប្រមាណវិធីរកមធ្យមភាគសម្រាប់ស្រុក/ក្រុងនីមួយៗ និងសម្រាប់ខេត្តទាំងមូល។ ផ្អែកតាមក្រាហ្វិកខាងលើ យើងឃើញថា អ្នកចូលរួមឆ្លើយសំណួរនៅក្រុងស្វាយរៀងបានផ្តល់ពិន្ទុមធ្យមភាគសរុប៣.៣៩ ស្មើនឹង៦៧.៨% ដែលស្ថិតនៅកម្រិតនៃការអនុវត្តបានមធ្យម ស្រុករំដួលទទួលបានពិន្ទុ៣.៤៣ ស្មើនឹង៦៨.៦% ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុករមាសហែកទទួលបានពិន្ទុ៣.២៤ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម

និងក្រុងបារិតទទួលបានពិន្ទុ៣.៦០ ស្មើនឹង៧២% ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតអនុវត្តបានល្អ។ ចំណែកឯ ស្រុកស្វាយជ្រំទទួលបានពិន្ទុ៣.៤៥ ស្មើនឹង៦៩% ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតអនុវត្តបានមធ្យម ស្រុកកំពង់រោទិ៍ទទួលបានពិន្ទុ៣.៤៨ ស្មើនឹង៦៩.៦%ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុកស្វាយទាបទទួលពិន្ទុ៣.៣២ ស្មើនឹង៦៦.៤% ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម និងចុងក្រោយ ស្រុកចន្ទ្រាទទួលបានពិន្ទុ៣.០៥ ស្មើនឹង៦១% ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យមផងដែរ។ ជារួម ពិន្ទុមធ្យមភាគនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន ដែលបានគ្រោងកន្លងមកក្នុងខេត្តស្វាយរៀងទាំងមូលទទួលបាន៣.៤០ ជាមធ្យមភាគស្ថិតនៅក្នុងកម្រិតនៃការអនុវត្តបានមធ្យម ពោលគឺផែនការដែលបានគ្រោងឡើងហើយយកទៅអនុវត្តបានប្រមាណតែ៦៨%នៃសកម្មភាពដែលបានស្នើឡើងទាំងអស់តែប៉ុណ្ណោះ។

ក្នុងចំណោមស្រុក/ក្រុងទាំង៨ មានតែក្រុងបារិតមួយប៉ុណ្ណោះដែលមានពិន្ទុមធ្យមភាគនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនបានល្អ ហើយពិន្ទុមធ្យមភាគនេះពិតជាស៊ីសង្វាក់គ្នាជាមួយនឹងពិន្ទុមធ្យមភាគនៃកម្រិតយល់ដឹងពីខ្លឹមសារ និងសកម្មភាពនានាដែលបានគ្រោងឡើង ព្រមទាំងពិន្ទុមធ្យមភាគនៃភាពពេញចិត្តចំពោះផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំឡើងហើយទទួលបានពិន្ទុខ្ពស់ដូចគ្នា។ ជារួម ស្ថិតិទាំងបីផ្នែកដូចបានបង្ហាញខាងលើនេះ ក្រុងបារិតទទួលបានខ្ពស់ជាងគេបង្អស់។ លទ្ធផលនេះ គឺដោយសារផែនការអភិវឌ្ឍន៍សាលារៀននៅក្នុងក្រុងនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន រួមទាំងគ្រូបង្រៀនទាំងអស់ ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានជាដើម និងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយពីលទ្ធផលនៃការអនុវត្តប្រកបដោយតម្លាភាពដែលនេះ កើតឡើងដោយសារ អ្នកចូលរួមភាគច្រើនបានផ្តល់ចម្លើយលើការអនុវត្តបានល្អ។ អ្នកចូលរួមភាគច្រើនបានផ្តល់ចម្លើយវិជ្ជមានលើការអនុវត្តផែនការ ដែលវាឆ្លើយតបបានច្រើនទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ចំណែកឯស្រុក/ក្រុងចំនួន៧ទៀត បានទទួលពិន្ទុមធ្យមភាគនៃការអនុវត្តបានកម្រិតមធ្យម ដោយសារ កង្វះការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ការចូលរួមក្នុងដំណើរការអនុវត្ត និងតាម

ដានត្រួតពិនិត្យ វាយតម្លៃពីសំណាក់អ្នកពាក់ព័ន្ធនានា ព្រមទាំងកង្វះការផ្សព្វផ្សាយឱ្យបានទូលំទូលាយប្រកបដោយតម្លាភាព ដែលជាហេតុធ្វើឱ្យកង្វះការគាំទ្រ និងភាពជឿទុកចិត្តលើការអនុវត្ត និងទៅលើលទ្ធផលនៃការអនុវត្តផែនការទាំងនោះ។ ភាគច្រើននៃអ្នកចូលរួមនៅស្រុក/ក្រុងទាំងនេះ បានផ្តល់ចម្លើយចំពោះលទ្ធផលនៃការអនុវត្តផែនការបានត្រឹមកម្រិតមធ្យមតែប៉ុណ្ណោះ ដោយវាយតម្លៃទៅលើការអនុវត្តមិនបានពេញលេញទៅតាមផែនការកំណត់ និងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម ព្រមទាំងតម្រូវការជាក់ស្តែងរបស់សាលារៀន។ មួយវិញទៀត អ្នកចូលរួមដែលជាគណៈគ្រប់គ្រងសាលា និងមន្ត្រីរដ្ឋបាល/គណនេយ្យ ព្រមទាំងលោកគ្រូ-អ្នកគ្រូមួយចំនួនបានទម្លាក់កំហុសទៅលើការទម្លាក់ថវិកាយឺតយ៉ាវ ដែលនាំឱ្យសកម្មភាពមួយចំនួនមិនត្រូវបានអនុវត្តទាន់ពេលវេលា និងអនុវត្តបានគ្រប់ចំនួនដូចដែលបានគ្រោងឡើងនៅក្នុងផែនការនោះឡើយ។ ជាមួយគ្នានេះ អ្នកចូលរួមមួយចំនួនទៀត ក៏បានបង្ហាញកង្វល់ពីអំពើពុករលួយផងដែរក្នុងដំណើរការអនុវត្តផែនការទាំងនោះ ដោយពួកគាត់បានលើកឡើងថា បើទោះបីថវិកាទម្លាក់មកបានគ្រប់ចំនួនក៏ដោយ ក៏សកម្មភាពមួយចំនួនមិនត្រូវបានគេអនុវត្តឡើយ ហើយករណីខ្លះគណៈគ្រប់គ្រងសាលា និងមន្ត្រីគណនេយ្យធ្វើការជម្រះបញ្ជីយកតែម្តង។ សម្រាប់បញ្ហាប្រឈមនេះ ការទម្លាក់ថវិកាយឺតក៏ចូលរួមចំណែកផងដែរដល់ការប្រើប្រាស់ថវិកាមិនមានប្រសិទ្ធភាពក្នុងការអនុវត្តសកម្មភាព ហើយវាផ្តល់ការលំបាកច្រើនដល់សាលារៀនក្នុងការអនុវត្តសកម្មភាពឱ្យបានទាន់ពេលវេលា ហើយករណីខ្លះដើម្បីដោះស្រាយស្ថានភាពនេះ ថ្នាក់ដឹកនាំសាលារៀនមួយចំនួនធ្វើការជម្រះបញ្ជីជាមុន រួចទើបអនុវត្តសកម្មភាពជាក្រោយ ឬធ្វើការជម្រះបញ្ជីដោយមិនអនុវត្តសកម្មភាពតែម្តង។

*រូបទី៤.៩ កម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនបន្ទាប់ពីរៀបចំ*




## ខ-កម្រិតនៃភាពពេញចិត្តទៅលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ

បន្ទាប់ពីយើងធ្វើការសិក្សាស្វែងយល់ និងវិភាគពីកម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនមក យើងក៏ធ្វើការសិក្សា និងវិភាគផងដែរពីកម្រិតនៃភាពពេញចិត្តរបស់អ្នកចូលរួមទាំងអស់នៅតាមស្រុក/ក្រុងនីមួយៗទៅលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ដោយប្រើប្រាស់មូលដ្ឋាននៃការវាយតម្លៃផ្អែកលើលទ្ធផល។ យើងបានកំណត់កម្រិត និងផ្តល់ពិន្ទុនៃភាពពេញចិត្តជាប្រាំប្រភេទគឺ ពិន្ទុមួយសម្រាប់កម្រិតមិនពេញចិត្តសោះ ពិន្ទុពីរ សម្រាប់ភាពពេញចិត្តតិចតួច ពិន្ទុបី សម្រាប់ភាពពេញចិត្តកម្រិតមធ្យម ពិន្ទុបួន សម្រាប់ភាពពេញចិត្តខ្លាំង និងពិន្ទុប្រាំ សម្រាប់ភាពពេញចិត្តខ្លាំងណាស់

។ បន្ទាប់មក យើងនឹងធ្វើការគណនារកមធ្យមភាគនៃចម្លើយរបស់អ្នកចូលរួមទាំងអស់ និងការធ្វើការវិភាគទៅលើលទ្ធផលនោះ។

យោងតាមរូបទី៤.១០ខាងក្រោម បង្ហាញពីកម្រិតនៃភាពពេញចិត្តទៅលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ដោយអ្នកចូលរួមទាំងអស់បានធ្វើការជ្រើសរើសចម្លើយសមស្របតាមការយល់ឃើញរបស់ពួកគាត់ផ្ទាល់ពីកម្រិតទាប ដល់កម្រិតខ្ពស់បំផុត។ ផ្អែកតាមក្រាហ្វិកខាងលើ យើងឃើញថា ក្រុងស្វាយរៀងទទួលបានពិន្ទុមធ្យមភាគ៣.៣៦ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម ស្រុករំដួលទទួលបានពិន្ទុ៣.៤០ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ស្រុករមាសហែកទទួលបានពិន្ទុ៣.១៨ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម ក្រុងបាវិតទទួលបានពិន្ទុ៣.៥០ ដែលជាមធ្យមពិន្ទុស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង ស្រុកស្វាយជ្រំទទួលបានពិន្ទុ៣.៤០ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម ស្រុកកំពង់រោទ៍ទទួលបានពិន្ទុ៤.២០ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តខ្លាំង ស្រុកស្វាយទាបទទួលបានពិន្ទុ៣.១៦ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម និងស្រុកចន្ទ្រាទទួលបានពិន្ទុ២.៨៩ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តតិចតួច។ ជារួម ក្នុងចំណោមស្រុក/ក្រុងទាំង៨ មានតែក្រុងបាវិត និងស្រុកកំពង់រោទ៍ប៉ុណ្ណោះដែលអ្នកចូលរួមបានបង្ហាញពីភាពពេញចិត្តខ្លាំងលើលទ្ធផលអនុវត្ត៥ឆ្នាំកន្លងមក ហើយស្រុក/ក្រុង៥ទៀតមានក្រុងស្វាយរៀង ស្រុករំដួល ស្រុករមាសហែក ស្រុកស្វាយទាប និងអ្នកចូលរួមនៅក្នុងស្រុកស្វាយជ្រំបានបង្ហាញពីភាពពេញចិត្តកម្រិតមធ្យម។ សម្រាប់ធម្យមភាគនៅក្នុងខេត្តទាំងមូលទទួលបានពិន្ទុ៣.៤៣ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យម។

ក្នុងចំណោមស្រុក/ក្រុងទាំង៨មានតែស្រុកចន្ទ្រាមួយប៉ុណ្ណោះដែលអ្នកចូលរួមបង្ហាញពីភាពពេញចិត្តតិចតួចលើលទ្ធផលនៃការអនុវត្តសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន៥កន្លងមក ដោយសារស្រុកនេះនៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដូចជាកង្វះគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតឧត្តម និងកង្វះធនធានរូបវន្តដូចជាអគារសិក្សា បង្គន់អនាម័យ និងទឹកស្អាត...ជាដើម ព្រមទាំងបរិស្ថានសាលារៀនមិនទាន់ល្អ

ប្រសើរនៅឡើយ និងមានបញ្ហាប្រឈមធ្ងន់ធ្ងរនៃអំពើពុករលួយក្នុងការអនុវត្តសកម្មភាព និងប្រើប្រាស់ថវិកា ដោយសកម្មភាពមួយចំនួនមិនបានអនុវត្តតាមផែនការគ្រោងទុកទេ។ អ្នកចូលរួមនៅក្នុងស្រុក/ក្រុងចំនួន៥ទៀតដែលទទួលបានពិន្ទុមធ្យមភាគកម្រិតពេញចិត្តមធ្យម បានលើកឡើងថា ដោយសារលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការមិនបានសម្រេចពេញលេញដូចការគ្រោងទុក ព្រោះការអនុវត្តជាក់ស្តែងបានប្រមាណតែជាង៦០%ប៉ុណ្ណោះ។ ពួកគាត់មិនបានបង្ហាញពីការពេញចិត្តខ្លាំងលើលទ្ធផលទាំងនោះទេ បើទោះជាសម្រេចជោគជ័យបានមួយចំនួនក៏ដោយ។

ផ្អែកតាមស្ថិតិ វាបង្ហាញថា លទ្ធផលមួយចំនួនមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ដោយវាគ្រាន់តែអនុវត្តតាមអ្វីដែលចង់បានរបស់បុគ្គលមួយចំនួនតែប៉ុណ្ណោះ ពិសេសគណៈគ្រប់គ្រងសាលា និងមន្ត្រីរដ្ឋបាល/គណនេយ្យ។ មួយវិញទៀត ពួកគាត់បានបង្ហាញពីបញ្ហាប្រឈមទាក់ទងនឹងកិច្ចសហការរបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្តផែនការ ពិសេសក្នុងចំណោមថ្នាក់ដឹកនាំសាលារៀន។ អ្នកចូលរួមមួយចំនួនបានត្អូញត្អែរពីការអនុវត្តសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនទាំងការប្រើប្រាស់ថវិការបស់រដ្ឋ ថវិកាម្ចាស់ជំនួយ និងសម្បុរសជនគឺមិនសូវតម្លាភាព និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដើម្បីចែករំលែកព័ត៌មានដល់អ្នកពាក់ព័ន្ធនានា ហើយករណីខ្លះសូម្បីតែនៅក្នុងជួរគណៈគ្រប់គ្រងសាលា ដូចជានាយករង/នាយិការង ឬថ្នាក់ដឹកនាំក្រុមបច្ចេកទេសជាដើមក៏មិនបានដឹងច្បាស់លាស់ពីថវិកាចំណូល និងចំណាយរបស់សាលារៀនដែរ ព្រមទាំងមិនបានដឹងពីសកម្មភាពដែលបានអនុវត្ត ថវិកាដែលបានប្រើប្រាស់ និងលទ្ធផលដែលសម្រេចបាននោះទេ។ ជាមួយគ្នានេះ ពួកគាត់ក៏បានបង្ហាញពីកង្វល់ផងដែរទាក់ទងនឹងការបែកបាក់សាមគ្គីភាពផ្ទៃក្នុងនៅក្នុងស្ថាប័ន ដោយសារការអនុវត្តសកម្មភាព និងប្រើប្រាស់ថវិកាមិនបានត្រឹមត្រូវដែលបង្កឱ្យមានទំនាស់ផ្ទៃក្នុង ភាពច្រណែននិន្ទាគ្នា និងភាពមិនទុកចិត្តគ្នាលើការទទួលបានផលប្រយោជន៍នានា ដែលជាឧបសគ្គចម្បងរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ស្ថាប័ន លើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងគុណភាពអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកចូលរួមនៅក្រុងបាវិត និងស្រុក

កំពង់រោទិ៍ បង្ហាញពីភាពពេញចិត្តខ្លាំងលើលទ្ធផលនៃការអនុវត្តផែនការកន្លងមក ដោយសារវាផ្តល់លទ្ធផលផ្លែផ្កាជាច្រើនដែលធ្វើឱ្យសាលារៀនមានការអភិវឌ្ឍន៍ និងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ តាមរយៈ ការអនុវត្តផែនការទាំងនេះ ធ្វើឱ្យសាលារៀនមានការផ្លាស់ប្តូររីកចម្រើនទាំងផ្នែកបរិស្ថាន និងធនធានរូបវន្តមួយចំនួនមានដូចជាអគារសិក្សា បង្គន់អនាម័យ... និងលទ្ធផលសិក្សារបស់សិស្សក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ដែលជាមូលហេតុចម្បងធ្វើឱ្យពួកគាត់បង្ហាញពីភាពពេញចិត្តខ្លាំងលើលទ្ធផលសម្រេចបានទាំងនេះ ។

*រូបទី៤.១០ កម្រិតនៃភាពពេញចិត្តទៅលើលទ្ធផលនៃការអនុវត្តផែនការក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ*




## គ-ការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

យោងតាមរូបទី៤.១១ បង្ហាញពីការលំបាកនានាក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនកន្លងមក។ ក្រាហ្វិកខាងក្រោម វាបានបង្ហាញថា អ្នកចូលរួមចំនួន៥៦នាក់ ស្មើនឹង១៨%

បានលើកឡើងពីសកម្មភាពមួយចំនួនដែលសាលារៀនបានស្នើសុំ តែមិនទទួលបានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយអ្នកចូលរួមចំនួន២០៧នាក់ ស្មើនឹង៦៦.៦% បានលើកឡើងពីការចូលរួមមិនទាន់ទូលំទូលាយពីអ្នកពាក់ព័ន្ធនានាក្នុងនោះមាន សិស្សានុសិស្ស មាតាបិតាសិស្ស ប្រជាពលរដ្ឋ សហគមន៍ ក្រុមប្រឹក្សា/គណៈកម្មការនានា និងអាជ្ញាធរមូលដ្ឋាន។ សម្រាប់ការលំបាកមួយចំនួនទៀត អ្នកចូលរួមចំនួន១៨៦នាក់ ស្មើនឹង៥៩.៨% បានបង្ហាញពីការលំបាកដោយសារថវិកាដែលរដ្ឋទម្លាក់មកសាលារៀននៅមានចំនួនតិចតួចនៅឡើយ អ្នកចូលរួមចំនួន៦៣នាក់ ស្មើនឹង២០.៣% បានលើកឡើងពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដោយដាក់បញ្ចូលតែសកម្មភាពដដែលៗដូចឆ្នាំចាស់កន្លងមក ពោលគឺមិនមានដាក់បញ្ចូលសកម្មភាពថ្មីៗដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមបច្ចុប្បន្នរបស់សាលារៀន ហើយអ្នកចូលរួមចំនួន១៨១នាក់ ស្មើនឹង៥៨.៣% ក៏បានបង្ហាញផងដែរថា សកម្មភាពដែលគ្រោងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនមិនបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន។ មួយវិញទៀត អ្នកចូលរួមចំនួន៣២នាក់ ស្មើនឹង១០.៣% បានលើកឡើងពីលក្ខណៈស្មុគស្មាញនៃទម្រង់ផែនការអភិវឌ្ឍន៍សាលារៀនដែលផ្តល់ការលំបាកដល់ការបំពេញសម្រាប់វិទ្យាល័យគោលដៅនីមួយៗ ហើយអ្នកចូលរួមចំនួន៨៥នាក់ ស្មើនឹង២៧.៣% បានផ្តល់ចម្លើយពីការលំបាកក្នុងការរៀបចំផែនការទាក់ទងនឹងកង្វះធនធានមនុស្សដែលមានសមត្ថភាពក្នុងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ជាមួយគ្នានេះ អ្នកចូលរួមចំនួន២១២នាក់ ស្មើនឹង៦៨.២%បានបង្ហាញថា ការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធពីផែនការអភិវឌ្ឍន៍សាលារៀននៅមិនទាន់ទូលំទូលាយនៅឡើយ។

អ្នកចូលរួមបានលើកឡើងពីការលំបាក ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដែលមានប្រេកង់ញឹកញាប់ជាងគេលើសពី៥០%ដោយបែងចែកទៅតាមលំដាប់លំដោយមានបួនគឺ (១)ការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានាពីផែនការអភិវឌ្ឍន៍សាលារៀន និងលទ្ធផលសម្រេចបានមិនទាន់បានទូលំទូលាយដល់អ្នកពាក់ព័ន្ធនានា (២)ការរៀបចំមិនទាន់មានការចូលរួមទូលំទូលាយពីអ្នកពាក់ព័ន្ធ (៣)ថវិកាដែលរដ្ឋទម្លាក់នៅមានចំនួនតិចតួចនៅឡើយ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍន៍សាលារៀនដែលទាមទារឱ្យរដ្ឋបង្កើន

កញ្ចប់ថវិកាឱ្យដល់វិទ្យាល័យបន្ថែមទៀត និង(៥)សកម្មភាពដែលគ្រោងឡើងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ផ្អែកតាមស្ថិតិ បានបង្ហាញឱ្យឃើញថា ការផ្សព្វផ្សាយនៅមិនទាន់ទូលំទូលាយ ហើយការចូលរួមក្នុងការរៀបចំផែនការពីសំណាក់អ្នកពាក់ព័ន្ធនានានៅមានកម្រិត ធ្វើឱ្យការរៀបចំផែនការមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ករណីមួយចំនួនទៀតគឺ ការមិនបើកចំហឱ្យអ្នកពាក់ព័ន្ធទាំងអស់ទទួលបានព័ត៌មានទាក់ទងទៅនឹងដំណើរការរៀបចំ ការអនុវត្ត និងការតាមដានត្រួតពិនិត្យលើការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន គឺជាចេតនារបស់គណៈគ្រប់គ្រងសាលារៀនមួយចំនួន ពិសេសនាយក/នាយិកាក្នុងការទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនពីការប្រើប្រាស់ថវិកានានាដែលជាចំណូលរបស់សាលា តាមរយៈការទាញយកផលប្រយោជន៍ជាលក្ខណៈបុគ្គល លើការអនុវត្តសកម្មភាពទាំងនោះ។ នេះជាបញ្ហាប្រឈមដែលវិទ្យាល័យនីមួយៗត្រូវយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមួយមានលក្ខណៈល្អប្រសើរប្រកបដោយតម្លាភាព និងអាចទទួលយកបានពីភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានេះ យោងតាមការសិក្សាប្រៀបធៀបរវាងបញ្ហាប្រឈម និងសកម្មភាពដែលគ្រោងឡើង ក៏បានបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាផងដែរ ដោយសកម្មភាពគ្រោងឡើងភាគច្រើនក្នុងរយៈពេល៥ឆ្នាំកន្លងមក ឬក្នុងរយៈពេលច្រើនជាងនេះ គឺផ្តោតអាទិភាពសំខាន់ជាងគេតែទៅលើការកែលម្អបរិស្ថានសាលារៀនតែប៉ុណ្ណោះដែលសកម្មភាពនេះផ្តល់ភាពងាយស្រួលក្នុងការទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ។ មួយវិញទៀត អ្នកចូលរួមក៏បានលើកឡើងផងដែរទាក់ទងនឹងចំនួនថវិកាដែលរដ្ឋទម្លាក់ឱ្យមកសាលារៀននៅមានចំនួនតិចតួចនៅឡើយដែលចំនួននេះនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមវិទ្យាល័យនីមួយៗក្នុងការដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា និងទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព ។

អ្នកចូលរួមមិនបានបង្ហាញពីការលំបាកលើបញ្ហាមួយចំនួនដូចជា៖ សកម្មភាពដែលសាលារៀនស្នើឡើងហើយ តែមន្ទីរមិនគាំទ្រ ទម្រង់ផែនការអភិវឌ្ឍន៍សាលារៀនមានលក្ខណៈស្មុគស្មាញ ការរៀបចំផែនការដោយគ្រោងសកម្មភាពដដែលៗដូចផែនការឆ្នាំចាស់ និង

បញ្ហាកង្វះធនធានមនុស្សក្នុងការរៀបចំ។ យោងតាមស្ថិតិនេះ បានបង្ហាញឱ្យឃើញថា ទម្រង់ផែនការអភិវឌ្ឍន៍សាលារៀននេះមិនមានលក្ខណៈលំបាកស្មុគស្មាញនោះទេ ដោយសារវិទ្យាល័យនីមួយៗនៅទូទាំងខេត្តបានយកគំរូដែលមានស្រាប់ពីមន្ទីរមកចម្លងតាម ដោយគ្រាន់តែដាក់បញ្ចូលផ្នែកមួយចំនួនដែលជាលក្ខណៈដោយឡែករបស់វិទ្យាល័យនីមួយៗ ដូចជា សារតាសាលារៀន និងបញ្ហាប្រឈមជាដើម ហើយការរៀបចំនេះទៀតសោតគឺធ្វើឡើងដោយគណៈគ្រប់គ្រងសាលាដែលពួកគាត់សុទ្ធតែទទួលបានការបណ្តុះបណ្តាលទាំងអស់។ តាមរយៈវគ្គបណ្តុះបណ្តាល និងការផ្តល់គំរូសម្រាប់ចម្លងតាមបែបនេះ ធ្វើឱ្យការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនសូវមានបញ្ហាចោទប៉ុន្មានទេ។ នេះជាការយល់ឃើញរបស់អ្នកចូលរួមទាំងអស់ដែលបញ្ជាក់ថា ទម្រង់ផែនការអភិវឌ្ឍន៍សាលារៀនមិនមានលក្ខណៈស្មុគស្មាញ និងងាយស្រួលក្នុងការបំពេញ ដោយសារតែត្រូវបានរៀបចំឡើងដោយមនុស្សមួយក្រុមដែលទទួលបានការបំប៉នសមត្ថភាព និងមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងធ្វើ ព្រមទាំងអនុវត្តតាមបែបចម្លងតាមគំរូដែលមានស្រាប់ ដោយមិនបានធ្វើការពិភាក្សាស៊ីជម្រៅ និងអនុវត្តតាមនីតិវិធីត្រឹមត្រូវដូចដែលក្រសួងបានកំណត់នោះទេ។

*រូបទី៤.១១ ការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន*




## ឃ-ថវិការអភិវឌ្ឍន៍ តម្រូវការជាក់ស្ដែង និងដំណោះស្រាយ

ផ្នែកនេះ យើងចង់ដឹងចម្លើយពីអ្នកចូលរួមទាំងអស់ទាក់ទងនឹងថវិកាដែលសាលារៀននីមួយៗទទួលបានពីរដ្ឋថាតើឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់សាលារៀនដែរឬទេ។ ក្នុងចំណោមអ្នកចូលរួមឆ្លើយសំណួរទាំង៣១១នាក់ មានអ្នកចូលរួមចំនួន៥៧នាក់ ស្មើនឹង១៨%ដែលបានផ្ដល់ចម្លើយថា ថវិកាដែលសាលារៀនទទួលបានគឺឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន ហើយអ្នកចូលរួមចំនួន២១៩នាក់ ស្មើនឹង៧០% បានឆ្លើយថា ថវិកាដែលទទួលបាននោះ មិនឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀនទេ ដោយសារសាលារៀនជួបប្រទះនូវបញ្ហាប្រឈមច្រើនដែលត្រូវដោះស្រាយ និងទាមទារប្រើប្រាស់ថវិកាច្រើនជាង។ ចំណែកឯ អ្នកចូលរួមចំនួន៣៦នាក់ ស្មើនឹង១២% បានឆ្លើយថា ពួកគាត់មិនបានដឹងថា សាលារៀនទទួលបានថវិកាប៉ុន្មាននោះទេ ហើយក៏មិនដឹងថា វាឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀនឬអត់ ព្រោះព័ត៌មានមិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

*រូបទី៤.១២ ភាពឆ្លើយតបរវាងថវិកាដែលសាលារៀនទទួលបានពីរដ្ឋ និងតម្រូវការជាក់ស្តែងរបស់សាលារៀន*




ផ្អែកតាមស្ថិតិ អ្នកចូលរួម៧០%ឆ្លើយថាថវិការដ្ឋទម្លាក់ឱ្យមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង យើងនឹងធ្វើការសិក្សាពីដំណោះស្រាយនានាដែលវិទ្យាល័យគោលដៅនីមួយៗប្រើប្រាស់ដើម្បីដោះស្រាយចំពោះបញ្ហាប្រឈមដែលបាននឹងកំពុងកើតឡើងចំពោះមុខ។ យើងក៏ធ្វើការវិភាគផងដែរពីភាពច្នៃប្រឌិតរបស់សាលារៀនក្នុងការស្វែងរកវិធីដោះស្រាយបញ្ហាដែលកើតមានឡើង។

រូបទី៤.១៣ខាងក្រោម បង្ហាញពីដំណោះស្រាយនានាដែលអ្នកចូលរួមចំនួន២១៩នាក់មកពីវិទ្យាល័យទាំងអស់ក្នុងចំណោមអ្នកចូលរួមទាំង៣១១នាក់បានលើកឡើងថា ថវិកាដែលសាលារៀនទទួលបានពីរដ្ឋមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀននោះទេ។ ក្នុងចំណោមអ្នកចូលរួមទាំង២១៩នាក់ អ្នកចូលរួមចំនួន១១៨នាក់ ស្មើនឹង៥៣.៩% បានបញ្ជាក់ថា នៅពេលសាលារៀនទទួលបានថវិកាដែលទម្លាក់ពីរដ្ឋមិនគ្រប់គ្រាន់ សាលារៀនបានទុកសកម្មភាពមួយចំនួន សម្រាប់ដាក់ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅឆ្នាំ

ក្រោយៗទៀត ហើយអ្នកចូលរួមចំនួន១៦០នាក់ ស្មើនឹង៧៣.១% បានលើកឡើងពីការកំណត់សកម្មភាពជាអាទិភាពសម្រាប់អនុវត្តបន្ទាន់ ដោយកាត់ចោលសកម្មភាពបន្ទាប់បន្សំដែលមិនសូវចាំបាច់ចេញ។ មួយវិញទៀត អ្នកចូលរួមចំនួន១២៨នាក់ ស្មើនឹង៥៨.៤% បានលើកឡើងថា នៅពេលសាលារៀនទទួលបានថវិកាតិចជាងតម្រូវការ សាលារៀនបានព្យាយាមកៀរគថវិកាពីប្រភពផ្សេងៗទៀត ដើម្បីដោះស្រាយជាបន្ទាន់ ហើយចំណុចចុងក្រោយ អ្នកចូលរួមចំនួន៧២នាក់ ស្មើនឹង ៣២.៩% បានបញ្ជាក់ថា សាលារៀននឹងកាត់តម្រឹមថវិកាតាមសកម្មភាពនីមួយៗឱ្យឆ្លើយតបទៅនឹងចំនួនថវិកាដែលរដ្ឋទម្លាក់ឱ្យ។

ផ្អែកតាមស្ថិតនេះ បង្ហាញថា វិទ្យាល័យគោលដៅនីមួយៗមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ ពិសេសការកំណត់អាទិភាពលើបញ្ហាប្រឈមដែលចាំបាច់ត្រូវដោះស្រាយបន្ទាន់ និងបញ្ហាប្រឈមបន្ទាប់បន្សំដែលទុកដោះស្រាយនៅពេលក្រោយ ព្រមទាំងធ្វើការកៀរគថវិកាពីប្រភពផ្សេងៗទៀតដើម្បីបំពេញថវិកាដែលខ្វះខាត និងតម្រូវការចាំបាច់។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏មានអ្នកចូលរួមចំនួនជាងពាក់កណ្ដាលផងដែរ ដែលមិនបានបង្ហាញពីដំណោះស្រាយសមស្របក្នុងការដោះស្រាយបញ្ហាចំពោះមុខ ពោលគឺទុកបញ្ហាទាំងនោះចោល ដោយរង់ចាំថវិកាទម្លាក់ឆ្នាំក្រោយៗទៀតដែលនេះបង្ហាញពីកង្វះគំនិតច្នៃប្រឌិតរបស់ថ្នាក់ដឹកនាំសាលារៀនក្នុងការស្វែងរកដំណោះស្រាយចាំបាច់នានាក្នុងការដោះស្រាយបញ្ហាប្រឈមជាអាទិភាព និងត្រូវដោះស្រាយបន្ទាន់។

*រូបទី៤.១៣ ដោះស្រាយរបស់សាលារៀនពេលថវិកាទទួលបានពីរដ្ឋមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង*




## ខ-កម្រិតនៃការប្រជុំផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនដែលរៀបចំរួច ដល់អ្នកពាក់ព័ន្ធ

សម្រាប់ផ្នែកនេះ យើងនឹងធ្វើការសិក្សាស្វែងយល់ និងវិភាគពីកម្រិតនៃការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំហើយនៅតាមវិទ្យាល័យគោលដៅក្នុងស្រុក/ក្រុងនីមួយៗ។ យើងបានកំណត់កម្រិត និងផ្តល់ពិន្ទុនៃការប្រជុំផ្សព្វផ្សាយជាប្រាំប្រភេទគឺ ពិន្ទុមួយសម្រាប់កម្រិតមិនបានផ្សព្វផ្សាយសោះ ពិន្ទុពីរសម្រាប់ការផ្សព្វផ្សាយបានតិចតួច ពិន្ទុបីសម្រាប់ការប្រជុំផ្សព្វផ្សាយបានមធ្យម ពិន្ទុបួនសម្រាប់ការប្រជុំផ្សព្វផ្សាយបានច្រើន និងពិន្ទុប្រាំសម្រាប់ការប្រជុំផ្សព្វផ្សាយបានច្រើនណាស់។ បន្ទាប់មកយើងនឹងធ្វើការគណនារកមធ្យមភាគនៃចម្លើយរបស់អ្នកចូលរួមទាំងអស់ និងធ្វើការវិភាគទៅលើលទ្ធផលនោះ។

យោងតាមរូបទី៤.១៩ វាបង្ហាញពីកម្រិតនៃការប្រជុំផ្សព្វផ្សាយពីខ្លឹមសារ និងសកម្មភាពនានាដែលបានគ្រោងក្នុងផែនការអភិវឌ្ឍន៍សាលារៀនទៅអ្នកពាក់ព័ន្ធទាំងអស់រួមមានក្រុម

ប្រឹក្សា/គណកម្មការនានា លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស ប្រជាពលរដ្ឋសហគមន៍ និងអាជ្ញាធរមូលដ្ឋាន និងធ្វើប្រមាណវិធីរកមធ្យមភាគទៅតាមស្រុក/ក្រុងនីមួយៗ និងសម្រាប់ខេត្តទាំងមូល។ យើងបានកំណត់ឱ្យអ្នកចូលរួមធ្វើការជ្រើសរើសចម្លើយមួយក្នុងចំណោមប្រាំចាប់ពីកម្រិតមិនបានផ្សព្វផ្សាយសោះ ផ្សព្វផ្សាយបានតិចតួច ផ្សព្វផ្សាយមធ្យម ផ្សព្វផ្សាយបានច្រើន និងផ្សព្វផ្សាយបានច្រើនណាស់។ ជាមួយគ្នានេះ យើងក៏កំណត់ពិន្ទុសម្រាប់ចម្លើយជ្រើសរើសទាំងនោះដែរ គឺកំណត់ពិន្ទុ១សម្រាប់ចម្លើយដែលជ្រើសរើសថា មិនបានផ្សព្វផ្សាយសោះ ពិន្ទុ២សម្រាប់ជម្រើសចម្លើយផ្សព្វផ្សាយបានតិចតួច ពិន្ទុ៣សម្រាប់ជម្រើសចម្លើយផ្សព្វផ្សាយបានមធ្យម ពិន្ទុ៤សម្រាប់ការផ្សព្វផ្សាយបានច្រើន និងចុងក្រោយពិន្ទុ៥សម្រាប់កម្រិតផ្សព្វផ្សាយបានច្រើនណាស់។ ផ្អែកតាមក្រាហ្វិកខាងក្រោមយើងឃើញថាអ្នកចូលរួមឆ្លើយសំណួរនៅក្រុងស្វាយរៀង បានបង្ហាញពីកម្រិតនៃការផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនក្នុងពិន្ទុមធ្យមភាគសរុប៣.០៥ ដែលមធ្យមភាគនេះស្ថិតនៅក្នុងកម្រិតផ្សព្វផ្សាយបានមធ្យម ស្រុករំដួលមានពិន្ទុមធ្យមភាគ៣.០៧ដែលពិន្ទុនេះស្ថិតនៅក្នុងកម្រិតមធ្យមដូចគ្នា ស្រុករមាសហែកមានពិន្ទុមធ្យមភាគ ២.៨៥ ដែលពិន្ទុមធ្យមភាគនេះស្ថិតនៅក្នុងកម្រិតផ្សព្វផ្សាយបានតិចតួច ក្រុងបាវិតមានពិន្ទុមធ្យមភាគ ៣.៣៥ ដែលជាពិន្ទុបញ្ជាក់ពីការផ្សព្វផ្សាយបានមធ្យម ស្រុកស្វាយជ្រំមានពិន្ទុមធ្យមភាគ ២.៩៧ ដែលស្ថិតនៅក្នុងកម្រិតផ្សព្វផ្សាយបានតិចតួច ស្រុកកំពង់រោទ៍មានពិន្ទុមធ្យមភាគ ៣.៣៣ដែលជាពិន្ទុស្ថិតនៅក្នុងផ្សព្វផ្សាយបានមធ្យម ស្រុកស្វាយទាបមានពិន្ទុមធ្យមភាគ ៣.៤២ ដែលជាពិន្ទុមធ្យមភាគស្ថិតនៅក្នុងកម្រិតមធ្យម និងស្រុកចន្ទ្រាមានពិន្ទុមធ្យមភាគ ២.៧៩ដែលជាពិន្ទុមធ្យមភាគស្ថិតនៅក្នុងកម្រិតផ្សព្វផ្សាយបានតិចតួច។ ជារួមសម្រាប់ខេត្តស្វាយរៀងទាំងមូល ទទួលបានពិន្ទុមធ្យមភាគគឺ៣.១១ ដែលជាពិន្ទុស្ថិតនៅក្នុងកម្រិតមធ្យមនៃការផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធ ។

ក្នុងចំណោមស្រុក/ក្រុងទាំង០៨ មានស្រុកចំនួន០៣គឺស្រុករមាសហែក ស្រុកស្វាយជ្រំ និងស្រុកចន្ទ្រាមានពិន្ទុមធ្យមភាគនៃការផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំរួចបានកម្រិតតិចតួចប៉ុណ្ណោះ ព្រោះអ្នកចូលរួមជាច្រើនបានបង្ហាញពីកង្វល់នៃការ

រៀបចំផែនការដែលមិនមានលក្ខណៈតម្លាភាព ការបើកចំហ និងការចែករំលែកព័ត៌មាន ព្រមទាំងមានការប្រព្រឹត្តអំពើពុករលួយនៅក្នុងសាលារៀនទៀតផង។ ចំណែកឯ ស្រុក/ក្រុងចំនួន៥ទៀត បានទទួលពិន្ទុមធ្យមភាគនៃការផ្សព្វផ្សាយបានកម្រិតមធ្យម ដោយសារការផ្សព្វផ្សាយមិនទាន់បានទូលំទូលាយពេញលេញនៅឡើយ ដែលជាហេតុធ្វើឱ្យកង្វះការគាំទ្រ ភាពទុកចិត្ត និងភាពជឿជាក់ខ្លាំងលើការអនុវត្ត ពិសេសលទ្ធផលនៃការអនុវត្តផែនការទាំងនោះ។ ជារួមយើងអាចវាយតម្លៃបានថា កម្រិតនៃការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងខេត្តស្វាយរៀងទាំងមូល មិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីពង្រឹងទំនុកចិត្ត ការទទួលបានព័ត៌មានពេញលេញពង្រឹងសាមគ្គីភាពផ្ទៃក្នុង ការគាំទ្រ និងកិច្ចសហការអភិវឌ្ឍន៍ឱ្យមានការរីកចម្រើនទៅមុខ។

*រូបទី ៤.១៤ កម្រិតនៃការប្រជុំផ្សព្វផ្សាយបង្ហាញខ្លឹមសារ និងសកម្មភាពដែលគ្រោងអនុវត្តនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធ*



## ៤.៤ សំយោគនិន្នន័យកម្រងសំណួរ

### ការសំយោគនិន្នន័យកម្រងសំណួរត្រូវបានបែងចែកជាបីផ្នែកធំៗ៖

#### ក. ការយល់ដឹងពីទម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀន

ក្នុងចំណោមផែនការនានាដែលលើកឡើងនៅក្នុងកម្រងសំណួរ អ្នកចូលរួមមានការយល់ដឹងពីផែនការអភិវឌ្ឍន៍សាលារៀនច្រើនជាងគេ ទោះបីការយល់ដឹងនោះតាមរយៈការចូលរួមរៀបចំដោយផ្ទាល់ ឬប្រយោល និងតាមរយៈការប្រជុំផ្សព្វផ្សាយក៏ដោយ។ អ្នកចូលរួមចំនួន៣១១នាក់ ស្មើនឹង១០០% បានដឹងថា វិទ្យាល័យរបស់ខ្លួនមានរៀបចំផែនការអភិវឌ្ឍន៍សាលារៀនជារៀងរាល់ឆ្នាំ។ អ្នកចូលរួម១០២នាក់ ស្មើនឹង៣៣%បានដឹងពីការរៀបចំផែនការយុទ្ធសាស្ត្រ ហើយអ្នកចូលរួម១២៩នាក់ ស្មើនឹង៤១.៥% បានដឹងពីការរៀបចំផែនការថវិកាក្នុងវិទ្យាល័យដែលខ្លួនបាននឹងកំពុងបំពេញការងារ។ ចុងក្រោយ អ្នកចូលរួម ១៦៦នាក់ ស្មើនឹង ៥៣.៤% បានដឹងពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។ សម្រាប់ការសិក្សាពីកម្រិតយល់ដឹងពីខ្លឹមសារ និងសកម្មភាពនានាដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង អ្នកចូលរួមទាំងអស់បានផ្តល់ចម្លើយសរុបជាមធ្យមភាគ ៣.១៩ ដែលជាការយល់ដឹងស្ថិតនៅក្នុងកម្រិតមធ្យមប៉ុណ្ណោះ ដោយសារអ្នកចូលរួមមួយចំនួនធំមិនបានចូលរួមក្នុងដំណើរការរៀបចំផែនការនេះផ្ទាល់ ហើយការផ្សព្វផ្សាយក៏នៅមិនទាន់អនុវត្តបានទូលំទូលាយនៅឡើយ។ មួយវិញទៀត ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅជាច្រើនមិនបានផ្តល់ឱកាសពេញលេញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធដទៃទៀតដូចជា សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ពោលគឺ រៀបចំឡើងដោយភាគីមួយចំនួនប៉ុណ្ណោះ ក្នុងនោះមានគណៈគ្រប់គ្រងសាលារៀន និងមន្ត្រីរដ្ឋបាល/គណនេយ្យ។ នេះជាមូលហេតុចម្បងដែលធ្វើឱ្យកម្រិតយល់ដឹងរបស់អ្នកពាក់ព័ន្ធទាំងអស់មិនស្មើគ្នា និងនៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ព្រមទាំងមិនទាន់ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់វិទ្យាល័យនីមួយៗ។ បើយោងតាមស្ថិតិសិក្សាពីកម្រិតយល់ដឹងរបស់អ្នកពាក់ព័ន្ធនីមួយៗគឺ មានតែនាយក/នាយិកាវិទ្យាល័យតែប៉ុណ្ណោះដែលចូលរួមបានពេញលេញស្មើនឹង១០០%ក្នុងដំណើរ

ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ហើយនាយករង/នាយិការង និងថ្នាក់ដឹកនាំក្រុមបច្ចេកទេសមានការចូលរួមពិគ្រោះយោបល់បានច្រើនជាងកម្រិតមធ្យម លើសពី៥០%ឡើង។ ចំណែកឯ អ្នកពាក់ព័ន្ធដទៃទៀតដូចជាៈ មន្ត្រីរដ្ឋបាល/គណនេយ្យ គ្រូបង្រៀន សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានមានការចូលរួមតិចតួចនៅឡើយ។ ជាទូទៅវិទ្យាល័យនីមួយៗផ្តល់ឱកាសតិចតួចបំផុតត្រឹមតែ៨.៧% ប៉ុណ្ណោះដល់សិស្សានុសិស្សក្នុងការពិគ្រោះយោបល់ចូលរួមចំណែកអភិវឌ្ឍន៍សាលារៀន ហើយត្រូវនឹងគោលដៅសំខាន់របស់វិទ្យាល័យនីមួយៗដែលចង់ឱ្យសិស្សសម្រេចបាននូវលទ្ធផលនៃការសិក្សា។ ជារួមយើងអាចវាយតម្លៃបានថា ផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំឡើងមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែង និងតម្រូវការរបស់អ្នកពាក់ព័ន្ធទាំងអស់នោះទេ។

## ខ. ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

ផែនការអភិវឌ្ឍន៍សាលារៀនត្រូវបានរៀបចំទៅតាមបែបផែនផ្សេងៗ ក្នុងនោះអ្នកចូលរួមចំនួន៣៨នាក់ ស្មើនឹង ១២%បានឆ្លើយថា នាយកសាលាជាអ្នករៀបចំផែនការនេះទាំងស្រុង ហើយអ្នកចូលរួមចំនួន១២២នាក់ ស្មើនឹង៣៩%បានឆ្លើយថា គណៈគ្រប់គ្រងសាលាជាអ្នករៀបចំ រួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀនជាក្រោយ។ អ្នកចូលរួមចំនួន៧០នាក់ ស្មើនឹង២៣%បានឆ្លើយថា ដំណើរការរៀបចំផែនការមានការចូលរួមពិគ្រោះយោបល់ពីសំណាក់គ្រូបង្រៀនមួយចំនួនតែប៉ុណ្ណោះ។ មួយវិញទៀត អ្នកចូលរួមចំនួន៤៩នាក់ ស្មើនឹង១៦% បានឆ្លើយថា ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយពីគ្រូបង្រៀនទាំងអស់ ហើយអ្នកចូលរួមចំនួន៣២នាក់ ស្មើនឹង១០% ឆ្លើយថា ដំណើរការរៀបចំមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ក្នុងនោះមាន គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស គ្រូបង្រៀន ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស ប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ យោងតាមស្ថិតិខាងលើនេះ បង្ហាញឱ្យឃើញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍន៍និងកែលម្អសាលារៀន ដោយសារការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនមានការចូលរួមទូលំទូលាយប្រកប

ដោយតម្លាភាព ដែលនាំឱ្យកង្វះការគាំទ្រ និងការកើនឡើងនូវភាពមិនពេញចិត្ត ព្រមទាំងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់អ្នកពាក់ព័ន្ធដទៃទៀត។ មួយវិញទៀតការរៀបចំផែនការបែបនេះ នាំឱ្យមានភាពមិនទុកចិត្ត និងជឿជាក់គ្នាក្នុងចំណោមបុគ្គលិកអប់រំទាំងអស់ដែលជាកត្តាចម្បងនាំឱ្យមានការបែកបាក់ផ្ទៃក្នុង និងធ្វើឱ្យការអនុវត្តផែនការនោះមិនទទួលបានជោគជ័យល្អ។ ជាទូទៅយើងអាចវាយតម្លៃបានថា ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានា នៅក្នុងខេត្តស្វាយរៀងគឺបានប្រើប្រាស់នីតិវិធីសមស្រប តាមរយៈការប្រមូលព័ត៌មានអ្នកពាក់ព័ន្ធទាំងអស់ទាក់ទងទៅនឹងការសិក្សាពីបញ្ហាប្រឈមនានា ផលប៉ះពាល់ បន្ទាប់មកកំណត់អាទិភាពបញ្ហាប្រឈមទាំងនោះ ការពិភាក្សារួមគ្នាក្នុងការស្វែងរកដំណោះស្រាយសមស្រប ការប្រជុំឆ្លុះបញ្ចាំង និងប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយប្រកបដោយតម្លាភាពមិនត្រូវបានអនុវត្តនោះទេ។

ជាមួយគ្នានេះ អ្នកចូលរួមបានលើកឡើងពីបញ្ហាប្រឈមអាទិភាពបំផុតតាមលំដាប់លំដោយសំខាន់ចំនួនបួននោះគឺ (១) ការសាងសង់ និងជុសជុលខ្នាតតូចនៅក្នុងសាលារៀន (២) សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រ (៣) កង្វះសម្ភារឧបទេសសម្រាប់បង្រៀន និងរៀន និង(៤)សមត្ថភាពគ្រូបង្រៀននៅមានកម្រិតដែលទាមទារឱ្យមានការយកចិត្តទុកពង្រឹងបន្ថែម។ ចំណែកឯ សកម្មភាពចម្បងៗគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលអ្នកចូលរួមទាំងអស់បានជ្រើសរើសញឹកញាប់ជាងគេទៅតាមលំដាប់លំដោយសំខាន់ទាំងបួននោះគឺ (១) ផ្តោតលើការកែលម្អបរិស្ថានសាលារៀន (២) ការសាងសង់ និងជុសជុលខ្នាតតូចនៅក្នុងសាលារៀន (៣) ការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន និង (៤) ទិញសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន។ ចំពោះសកម្មភាពសំខាន់ៗបំផុតដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលអ្នកចូលរួមចំនួន៨១%បានឆ្លើយគឺ ការកែលម្អបរិស្ថានសាលារៀន ដែលចំណុចនេះខុសស្រឡះពីស្ថិតិបញ្ហាប្រឈមជាអាទិភាពបំផុតនៅក្នុងចំណុចបញ្ហាប្រឈមដែលបង្ហាញថា បញ្ហាប្រឈមទាក់ទងនឹងបញ្ហាបរិស្ថានសាលារៀនមិនត្រូវបានគេចាត់ទុកថាជាបញ្ហាប្រឈមជាអាទិភាពបំផុតនោះទេ ហើយការដាក់បញ្ចូលសកម្មភាពនេះគឺធ្វើឡើងដោយគណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះ។ នេះបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នារវាង

បញ្ហាប្រឈមជាអាទិភាពបំផុត និងដំណោះស្រាយចាំបាច់ជាងគេក្នុងការអភិវឌ្ឍន៍សាលារៀន ។ យោងតាមស្ថិតិនេះ យើងអាចវិភាគបានថា ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដោយដាក់បញ្ចូលសកម្មភាពដែលគ្រោងឡើងសំខាន់បំផុតដើម្បីដោះស្រាយបញ្ហាគឺ មិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាអាទិភាពបំផុតជាក់ស្តែង ដែលអ្នកចូលរួមបានកំណត់នោះទេ ពោលគឺរៀបចំសកម្មភាពនេះឡើងដោយគណៈគ្រប់គ្រងសាលា និងមន្ត្រីមួយចំនួនដែលទទួលផលប្រយោជន៍ពីការកិបកេងក្លែងបន្លំពីសកម្មភាពនេះតែប៉ុណ្ណោះ។ ជាមួយគ្នានេះ យើងក៏កត់សម្គាល់ឃើញផងដែរថា អ្នកចូលរួមទាំងអស់បានបង្ហាញថាឱកាសនៃការចូលរួមរបស់សិស្សានុសិស្សក្នុងការពិគ្រោះយោបល់ពីបញ្ហាប្រឈម និងតម្រូវការរបស់ពួកគាត់ ព្រមទាំងការលើកស្នើសកម្មភាពនានាដើម្បីដាក់ចូលក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅមានកម្រិតតិចតួចបំផុត គឺត្រឹមតែ១៤.៥%ប៉ុណ្ណោះ ពោលគឺសម្លេងសិស្សានុសិស្សមិនត្រូវបានគេឱ្យតម្លៃ និងរាប់បញ្ចូលទេ។ ដូច្នេះ ការប្រមូលព័ត៌មានពីបញ្ហាប្រឈមទាក់ទងនឹងបញ្ហាសិស្សមិនសូវយកចិត្តទុកដាក់សិក្សារៀនសូត្រ ដែលបញ្ហាជាអាទិភាពបំផុតទីពីរដែលបានលើកឡើងនៅក្នុងចំណុចប្រឈម មិនត្រូវបានពិគ្រោះយោបល់ជាមួយសិស្សទេ ដែលនេះជាមូលហេតុចម្បងដែលធ្វើឱ្យការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ពិសេសអ្នកទទួលសេវាអប់រំ ដូចជាសិស្សានុសិស្សជាដើម។ សម្រាប់សកម្មភាពដែលគ្រោងឡើងសំខាន់ៗ ទីបី និងទី បួនពិតជាបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀននីមួយៗ ព្រោះអ្នកចូលរួមភាគច្រើនបានលើកឡើងពីបញ្ហាប្រឈមទាក់ទងនឹងបញ្ហាខូចខាតសម្ភារៈ និងគ្រឿងបរិក្ខារសាលារៀន កង្វះសម្ភារឧបទេសបង្រៀន និងរៀន ព្រមទាំងសមត្ថភាពគ្រូបង្រៀននៅមានកម្រិត។ ជាទូទៅសកម្មភាពលើកកម្ពស់សមត្ថភាពគ្រូបង្រៀនដែលគ្រោងឡើងនៅតាមវិទ្យាល័យគោលដៅនីមួយៗភាគច្រើនគឺ ផ្តោតទៅលើការគាំទ្រសកម្មភាពប្រជុំ បច្ចេកទេសតែមួយប៉ុណ្ណោះ ដោយមិនមានសកម្មភាពដែលគ្រោងឡើងសម្រាប់ការគាំទ្រទៅលើការផ្តល់វគ្គបណ្តុះបណ្តាល ឬឧបត្ថម្ភដល់គ្រូបង្រៀនសម្រាប់ការសិក្សារៀនសូត្របន្តនោះទេ ដោយសារថវិកាមានកំណត់ មិនបានប្រមូលព័ត៌មានជាក់លាក់ និងពិភាក្សាស៊ីជម្រៅជាមួយគ្រូបង្រៀន។

ទោះបីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅជួបប្រទះបញ្ហាប្រឈមច្រើនក៏ដោយ ក៏អ្នកចូលរួមភាគច្រើនបានបង្ហាញពីការពេញចិត្តខ្លាំងចំពោះផែនការនេះដែរដោយទទួលបានពិន្ទុមធ្យមភាគគឺ៣.៥៩ ដោយសារពួកគាត់យល់ថា វាមានសារៈសំខាន់ក្នុងការធ្វើឱ្យសាលារៀនមានការអភិវឌ្ឍន៍ និងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ តាមរយៈផែនការអភិវឌ្ឍន៍ និងការអនុវត្តផែនការទាំងនេះធ្វើឱ្យសាលារៀនមានការផ្លាស់ប្ដូររីកចម្រើនទាំងផ្នែកបរិស្ថាន ការលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន ព្រមទាំងលទ្ធផលសិក្សារបស់សិស្ស។ មួយវិញទៀតពួកគាត់បានលើកឡើងថា ការរៀបចំឱ្យមានផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនីមួយៗមានភាពប្រសើរជាងមិនមានផែនការ ទោះបីផែនការនោះរៀបចំឡើងដោយមិនមានការចូលរួមទូលំទូលាយក៏ដោយ ក៏វាដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យស្ថាប័នមានភាពល្អប្រសើរឡើងនិងដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលសាលារៀនបាននឹងកំពុងកើតឡើងផងដែរ ហើយទាំងនេះជាមូលហេតុចម្បងដែលពួកគាត់បង្ហាញពីភាពពេញចិត្តខ្លាំងលើផែនការដែលបានរៀបចំឡើងកន្លងមក។

### គ. ដំណើរការក្រោយការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

បន្ទាប់ពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន សម្រាប់ផ្នែកចុងក្រោយ យើងធ្វើការសិក្សាពីដំណាក់កាលអនុវត្តផែនការទាំងនេះ។ ជាលទ្ធផល យើងឃើញថា អ្នកចូលរួមទាំងអស់បានផ្ដល់ពិន្ទុមធ្យមភាគ៣.៤០នៃការអនុវត្តសកម្មភាពបានគ្រោងឡើងកន្លងមកនៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតនៃការអនុវត្តបានមធ្យម ពោលគឺផែនការដែលបានគ្រោងឡើងហើយ យកទៅអនុវត្តបានប្រមាណតែ៦៨%នៃសកម្មភាពដែលបានស្នើឡើងទាំងអស់តែប៉ុណ្ណោះ។ យោងតាមស្ថិតិនេះ យើងអាចវាយតម្លៃបានថា ការអនុវត្តនេះ មិនបានពេញលេញទៅតាមផែនការកំណត់ និងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម ព្រមទាំងតម្រូវការជាក់ស្ដែងរបស់សាលារៀននោះទេ។ ជាមួយគ្នានេះអ្នកចូលរួមទាំងអស់បានផ្ដល់ពិន្ទុមធ្យមភាគត្រឹម ៣.៤៣ ដែលជាមធ្យមភាគស្ថិតនៅក្នុងកម្រិតពេញចិត្តមធ្យមទៅលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំកន្លងមក ដោយសារលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការ

មិនបានសម្រេចពេញលេញដូចការគ្រោងទុក ដោយអនុវត្តជាក់ស្តែងបានប្រមាណតែជាង ៦០%ប៉ុណ្ណោះ។ មួយវិញទៀត ផ្អែកតាមស្ថិតិ វាបង្ហាញថា លទ្ធផលមួយចំនួនមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ដោយវាគ្រាន់តែអនុវត្តតាមអ្វីដែលចង់បានរបស់ភាគីមួយចំនួនប៉ុណ្ណោះ ពិសេសគណៈគ្រប់គ្រងសាលា និងមន្ត្រីរដ្ឋបាល/គណនេយ្យ។ លើសពីនេះទៅទៀត អ្នកចូលរួមមួយចំនួនបានត្អូញត្អែរពីការអនុវត្តសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនទាំងការប្រើប្រាស់កញ្ចប់ថវិការបស់រដ្ឋ ថវិកាម្ចាស់ជំនួយ និងសម្បុរសជនដោយមិនមានតម្លាភាព គណនេយ្យភាពនិងមិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយដើម្បីចែករំលែកព័ត៌មានដល់អ្នកពាក់ព័ន្ធនានា ហើយករណីខ្លះសូម្បីតែនៅក្នុងជួរគណៈគ្រប់គ្រងសាលារៀនដូចគ្នា តួយ៉ាងដូចជា នាយករង/នាយិការង ឬថ្នាក់ដឹកនាំក្រុមបច្ចេកទេសជាដើមក៏មិនបានដឹងច្បាស់លាស់ពីថវិកាចំណូល និងចំណាយរបស់សាលារៀនដែរ ព្រមទាំងមិនបានដឹងពីសកម្មភាពដែលបានអនុវត្ត ថវិកាដែលបានប្រើប្រាស់ និងលទ្ធផលដែលសម្រេចបានជាក់លាក់នោះទេ។ ជាមួយគ្នានេះ ពួកគាត់ក៏បានបង្ហាញពីកង្វល់ផងដែរទាក់ទងនឹងការបែកបាក់សាមគ្គីភាពផ្ទៃក្នុងនៅក្នុងស្ថាប័នដោយសារការអនុវត្តសកម្មភាព និងការប្រើប្រាស់ថវិកាមិនបានត្រឹមត្រូវហើយបង្កឱ្យមានទំនាស់ផ្ទៃក្នុង ភាពច្រណែននិន្ទាគ្នា និងភាពមិនទុកចិត្តគ្នាលើការទទួលបានផលប្រយោជន៍នានាដែលជាឧបសគ្គចម្បងរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ស្ថាប័ន លើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងគុណភាពអប់រំ។

អ្នកចូលរួមបានលើកឡើងពីការលំបាកនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដែលមានប្រេកង់ញឹកញាប់ជាងគេលើសពី៥០%ដោយបែងចែកទៅតាមលំដាប់លំដោយមានបួនគឺ (១)ការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានាពីផែនការអភិវឌ្ឍន៍សាលារៀន និងលទ្ធផលសម្រេចបានមិនទាន់ទូលំទូលាយដល់អ្នកពាក់ព័ន្ធនានា (២)ការរៀបចំមិនទាន់មានការចូលរួមទូលំទូលាយពីអ្នកពាក់ព័ន្ធ (៣)ថវិកាដែលរដ្ឋទម្លាក់នៅមានចំនួនតិចតួចហើយ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍន៍សាលារៀនដែលទាមទារឱ្យរដ្ឋបង្កើនកញ្ចប់ថវិកាដល់វិទ្យាល័យបន្ថែមទៀត និង(៤)សកម្មភាពដែលគ្រោងឡើងមិនឆ្លើយតបទៅនឹងបញ្ហា

ប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ផ្អែកតាមស្ថិតិ បានបង្ហាញថា ការផ្សព្វផ្សាយនៅមិនទាន់ទូលំទូលាយ ហើយការចូលរួមក្នុងការរៀបចំផែនការពីសំណាក់អ្នកពាក់ព័ន្ធនានានៅមានកម្រិតនៅឡើយធ្វើឱ្យការរៀបចំផែនការឡើងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ការមិនបើកចំហឱ្យអ្នកពាក់ព័ន្ធទាំងអស់ទទួលបានព័ត៌មានពេញលេញទាក់ទងនឹងដំណើរការរៀបចំ ការអនុវត្ត និងការតាមដានត្រួតពិនិត្យលើការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនគឺ ជាចំណុចខ្វះចន្លោះរបស់គណៈគ្រប់គ្រងសាលារៀនមួយចំនួន ពិសេសនាយក/នាយិកា។ នេះជាបញ្ហាប្រឈម ដែលវិទ្យាល័យនីមួយៗត្រូវយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមួយមានលក្ខណៈល្អប្រសើរឡើងប្រកបដោយតម្លាភាព និងអាចទទួលយកបានពីភាគីពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានេះ យោងតាមការសិក្សាប្រៀបធៀបរវាងបញ្ហាប្រឈម និងសកម្មភាពដែលបានគ្រោងឡើង វាក៏បានបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាផងដែរ ដោយសកម្មភាពគ្រោងឡើងភាគច្រើនក្នុងរយៈពេល៥ឆ្នាំកន្លងមក ឬក្នុងរយៈពេលច្រើនជាងនេះ គឺផ្តោតអាទិភាពសំខាន់ជាងគេតែទៅលើការកែលម្អបរិស្ថានសាលារៀន ដែលសកម្មភាពនេះផ្តល់ភាពងាយស្រួលក្នុងការអនុវត្តរបស់មន្ត្រីមួយចំនួនតូចដែលអាចទាញយកប្រយោជន៍ជាលក្ខណៈបុគ្គលបានរយៈការធ្វើសកម្មភាពទាំងនេះ។ មួយវិញទៀត អ្នកចូលរួមក៏បានលើកឡើងផងដែរទាក់ទងនឹងចំនួនថវិកាដែលរដ្ឋទម្លាក់ឱ្យមកសាលារៀននៅមានចំនួនតិចតួចនៅឡើយ ដែលចំនួននេះនៅមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមវិទ្យាល័យនីមួយៗក្នុងការដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា និងទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព។

សម្រាប់ចំណុចចុងក្រោយ អ្នកចូលរួមចំនួន២១៩នាក់ ក្នុងចំណោម៣១១នាក់បានឆ្លើយថា ថវិកាដែលរដ្ឋទម្លាក់ឱ្យវិទ្យាល័យនីមួយៗមិនបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនោះទេ។ ទាក់ទងនឹងបញ្ហាកង្វះថវិកានេះ យើងធ្វើការសិក្សាពីដំណោះស្រាយនានាដែលអ្នកចូលរួមបានលើកឡើងដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងធ្វើការវាយតម្លៃពីភាពច្នៃប្រឌិតរបស់ថ្នាក់ដឹកនាំសាលារៀនក្នុងការស្វែងរកដំណោះស្រាយនានា។ ក្នុងចំណោមអ្នកចូលរួមទាំង២១៩នាក់ អ្នកចូលរួមចំនួន១១៨នាក់ ស្មើនឹង៥៣.៩% បានបញ្ជាក់ថា នៅពេល

សាលារៀនទទួលបានថវិកាដែលទម្លាក់ពីរដ្ឋមិនគ្រប់គ្រាន់ និងទាន់ពេលវេលា សាលារៀនបានទុកសកម្មភាពមួយចំនួន សម្រាប់ដាក់ចូលទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននៅឆ្នាំក្រោយៗទៀត ហើយអ្នកចូលរួមចំនួន១៦០នាក់ ស្មើនឹង៧៣.១% បានលើកឡើងពីការកំណត់សកម្មភាពជាអាទិភាពសម្រាប់អនុវត្តបន្ទាន់ ដោយកាត់ចោលសកម្មភាពបន្ទាប់បន្សំដែលមិនសូវចាំបាច់ចោល។ មួយវិញទៀត អ្នកចូលរួមចំនួន១២៨នាក់ ស្មើនឹង៥៨.៤% បានលើកឡើងថា នៅពេលសាលារៀនទទួលបានថវិកាតិចជាងតម្រូវការ សាលារៀនបានព្យាយាមកៀរគថវិកាពីប្រភពផ្សេងៗទៀត ដើម្បីដោះស្រាយជាបន្ទាន់ ហើយចំណុចចុងក្រោយ អ្នកចូលរួមចំនួន៧២នាក់ ស្មើនឹង ៣២.៩% បានបញ្ជាក់ថា សាលារៀននឹងកាត់តម្រឹមថវិកាតាមសកម្មភាពនីមួយៗឱ្យឆ្លើយតបទៅនឹងចំនួនថវិកាដែលរដ្ឋទម្លាក់ឱ្យ។ ផ្អែកតាមស្ថិតនេះ វាបង្ហាញថា វិទ្យាល័យគោលដៅនីមួយៗមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ ពិសេសការកំណត់អាទិភាពលើបញ្ហាប្រឈមដែលចាំបាច់ត្រូវដោះស្រាយបន្ទាន់ និងបញ្ហាប្រឈមបន្ទាប់បន្សំដែលទុកដោះស្រាយនៅពេលក្រោយ ព្រមទាំងធ្វើការកៀរគថវិកាពីប្រភពផ្សេងៗទៀតដើម្បីបំពេញថវិកាដែលខ្វះខាត និងតម្រូវការចាំបាច់។ តែទោះបីជាយ៉ាងក៏ដោយ ក៏មានអ្នកចូលរួមចំនួនជាងពាក់កណ្តាលផងដែរ ដែលមិនបានបង្ហាញពីដំណោះស្រាយសមស្របក្នុងការដោះស្រាយបញ្ហាចំពោះមុខ ពោលគឺទុកបញ្ហាទាំងនោះចោល ដោយរង់ចាំថវិកាទម្លាក់ឆ្នាំក្រោយៗទៀតដែលនេះបង្ហាញពី កង្វះគំនិតច្នៃប្រឌិតរបស់ថ្នាក់ដឹកនាំសាលារៀនក្នុងការស្វែងរកដំណោះស្រាយចាំបាច់នានាក្នុងការដោះស្រាយបញ្ហាប្រឈមជាអាទិភាព និងត្រូវដោះស្រាយបន្ទាន់។ ជារួម យើងអាចវាយតម្លៃបានថា កម្រិតនៃការផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនដល់អ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងខេត្តស្វាយរៀងទាំងមូល មិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីពង្រឹងទំនុកចិត្តលើការទទួលបានព័ត៌មានពេញលេញ សាមគ្គីភាពផ្ទៃក្នុងការគាំទ្រ និងកិច្ចសហការក្នុងការអភិវឌ្ឍន៍ឱ្យមានការរីកចម្រើនទៅមុខ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និង សំណូមពរ

ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសាលារៀនពីមួយឆ្នាំទៅមួយឆ្នាំ។ ដើម្បីរៀបចំផែនការមួយឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ទាមទារឱ្យមានការចូលរួមរៀបចំយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធទាំងអស់ ដោយប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ ផលប៉ះពាល់ កំណត់បញ្ហាប្រឈមជាអាទិភាព និងធ្វើការរួមគ្នាក្នុងការស្វែងរកដំណោះស្រាយសមស្រប។ ការធ្វើការរួមគ្នាក្នុងការរៀបចំ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីផែនការអភិវឌ្ឍន៍សាលារៀន ការអនុវត្តសកម្មភាព និងលទ្ធផលសម្រេចបាន ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងទំនុកចិត្ត សាមគ្គីភាពផ្ទៃក្នុង កិច្ចសហការ និងស្វែងរកការគាំទ្រពីអ្នកពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យមានការរីកចម្រើនទៅមុខជាលំដាប់។ ហេតុដូច្នេះហើយ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវបានកំណត់យកប្រធានបទមួយស្តីពី " **ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ**" មកធ្វើការស្រាវជ្រាវក្នុងគោលបំណង៖ (១) រកឱ្យឃើញពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និង (២)បង្ហាញពីកម្រិតពេញចិត្តលើផែនការអភិវឌ្ឍន៍សាលារៀន។

ឆ្លើយតបទៅនឹងសំណួរដែលទាក់ទងនឹង ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅក្នុងខេត្តស្វាយរៀង អ្នកចូលរួមទាំងអស់បង្ហាញពីកម្រិតយល់ដឹងពីទម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀនត្រឹមមធ្យមភាគ ៣.១៩ ដែលជាពិន្ទុមធ្យមភាគកម្រិតមធ្យមប៉ុណ្ណោះ ដោយពួកគាត់បានលើកឡើងថា ដំណើរការរៀបចំត្រូវបានចូលរួមពីភាគីពាក់ព័ន្ធមួយចំនួន ដូចជា គណៈគ្រប់គ្រងសាលា មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួនប៉ុណ្ណោះ។ ចំណែកឯអ្នកពាក់ព័ន្ធដទៃទៀតដូចជា សិស្សានុសិស្ស ក្រុមប្រឹក្សា/គណៈកម្មការនានា មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវបានគេផ្តល់ឱកាសឱ្យចូលរួមរៀបចំតិចតួចបំផុត ដែលអាចនិយាយបានថា សម្លេងរបស់ពួកគាត់មិនត្រូវបានគេឱ្យតម្លៃ និងរាប់បញ្ចូលក្នុងដំណើរការរៀបចំទេ។ ជា

ទូទៅ ផែនការអភិវឌ្ឍន៍សាលារៀន៩០% ត្រូវបានរៀបចំដោយគណៈគ្រប់គ្រងសាលា ឬកំណត់សកម្មភាពដែលគ្រោងអនុវត្តជាមុន ទើបរៀបចំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដទៃទៀតជាក្រោយ ដែលធ្វើឱ្យផែនការដែលរៀបចំនោះជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដូចជាសកម្មភាពដែលគ្រោងឡើងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្ដែង នាំឱ្យកង្វះការគាំទ្រ កង្វះកិច្ចសហការ និងនាំឱ្យមានការបែកបាក់សាមគ្គីផ្ទៃក្នុង ធ្វើឱ្យកើនឡើងនូវទំនាស់ផលប្រយោជន៍ ព្រមទាំងនាំឱ្យការអនុវត្តមិនសម្រេចបានជោគជ័យជាដើម។ ជារួម ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យក្នុងខេត្តស្វាយរៀង មិនត្រូវបានអនុវត្តតាមនីតិវិធីត្រឹមត្រូវដូចដែលក្រសួងបានកំណត់នោះទេ។ ទោះបីយ៉ាងណាក៏ អ្នកចូលរួមទាំងអស់បានបង្ហាញពីការពេញចិត្តក្នុងកម្រិតពិន្ទុមធ្យមភាគ ៣.៥៩ លើផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំ និងបង្ហាញពីការពេញចិត្តមធ្យមក្នុងកម្រិតពិន្ទុមធ្យមភាគ៣.៤៣ ទៅលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំកន្លងមក។

យើងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះ អាចជំរុញ និងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ដើម្បីបង្កើតផែនការមួយដែលមានលក្ខណៈសមស្របឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការចាំបាច់របស់សាលារៀន។ យើងខ្ញុំក៏សង្ឃឹមដែរថា សាលារៀននឹងបង្កើតផែនការអភិវឌ្ឍន៍សាលារៀនមួយដែលទទួលបានការគាំទ្រពេញលេញនូវគ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងអនុវត្តប្រកបដោយតម្លាភាព គណនេយ្យភាព និងសម្រេចលទ្ធផលបានជោគជ័យត្រចេះត្រចង់ដែលធ្វើឱ្យសាលារៀនរីកចម្រើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ។

ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំយល់ថា ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនកំពុងជួបប្រទះនូវបញ្ហាប្រឈមច្រើនដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ**" យើងខ្ញុំសង្កេតឃើញថា ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនបានអនុវត្តត្រឹមត្រូវតាមនីតិវិធីដែលក្រសួងបានកំណត់នោះទេ។ អាស្រ័យហេតុនេះ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវ មានសំណូមពរមួយចំនួនដល់ភាគីពាក់ព័ន្ធមេត្តាចូលរួមឱ្យបានសកម្មដើម្បីគាំទ្រដល់ការរៀបចំផែនការបានល្អប្រសើរ ។

សំណូមពរទាំងនេះមានដូចជាៈ

១. ថ្នាក់ដឹកនាំវិទ្យាល័យគួរតែផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងអនុវត្តឱ្យបានពេញលេញទៅតាមនីតិវិធីដែលក្រសួងបានកំណត់

២. ថ្នាក់ដឹកនាំវិទ្យាល័យគួរតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ការអនុវត្ត និងលទ្ធផលសម្រេចបានដល់អ្នកពាក់ព័ន្ធទាំងអស់

៣. សាលារៀនគួរតែពង្រឹងតួនាទី និងភារកិច្ចគណៈកម្មការដែលមានស្រាប់ដើម្បីចូលរួមចំណែកធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការដែលបានគ្រោងឡើង

៤. មន្ទីរអប់រំ យុវជន និងកីឡាខេត្តគួរតែចូលរួមតាមដានត្រួតពិនិត្យពីដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនឱ្យបានច្បាស់លាស់

៥. មន្ទីរអប់រំ យុវជន និងកីឡាខេត្តគួរតែផ្តល់វគ្គបំប៉នសមត្ថភាពបន្ថែមពីនីតិវិធីក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

៦. ក្រសួងអប់រំ យុវជន និងកីឡាគួរតែបង្កើនកញ្ចប់ថវិកាទម្លាក់ដល់វិទ្យាល័យបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងបង្កើតយន្តការតាមដានត្រួតពិនិត្យឱ្យបានច្បាស់លាស់លើការអនុវត្តផែនការ និងការប្រើប្រាស់ថវិកា

៧. ក្រសួងអប់រំ យុវជន និងកីឡាគួរតែទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា ដើម្បីឱ្យវិទ្យាល័យអនុវត្តសកម្មភាពបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព

៨. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ពីលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាព ដោយធ្វើការសិក្សាប្រៀបធៀបនឹងសូចនាករដែល

មាននៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំនៅតាមវិទ្យាល័យគោលដៅនីមួយៗ

៩. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត និងសិក្សាស្រាវជ្រាវនៅខេត្តផ្សេងទៀត៕

# ឯកសារយោង


(១). UNESCO, (២០១៥) វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុង Incheon និងក្របខណ្ឌសម្រាប់សកម្មភាពទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

(២). ACE, (២០០៨) The ACE blueprint 2008-2015, ASEAN secretariat Jakarta

(៣). រាជរដ្ឋាភិបាលកម្ពុជា (២០១៤) ផែនការយុទ្ធសាស្រ្តជាតិ ២០១៤-២០១៨-ភ្នំពេញ

(៤). ក្រសួងអយក (២០១៧) ស្ថិតិអប់រំ និងសូចនាករ

(៥) ក្រសួងអយក (២០១៧) ឯកសារណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់សាលាបឋមសិក្សា

(៦) ក្រសួងអយក (២០១៦) ប្រកាសលេខ៧៦១ អយក.ប្រក ស្តីពីការកំណត់គោលការណ៍ លក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំ

(៧) រាជរដ្ឋាភិបាល (២០១៨) អនុក្រឹតលេខ ៥៤អនក្រ.បក ស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល

(៨) នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ (២០០៩) ការគ្រប់គ្រង រដ្ឋបាល

(៩) The Road Ahead–IV, (2000): A Report on Improving Schools through Greater Accountability (Report of the Education Improvement Commission) http://eic.edu.gov.on.ca.

(១០) មន្ទីរអេយកខេត្តស្វាយរៀង (២០១៨) ស្ថិតិបុគ្គលិក

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧២១៨ អយក.[illegible]

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ ឆ្នាំសិក្សា២០១៧-២០១៨ របស់វិទ្យាស្ថានជាតិអប់រំ។

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ នៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា ពីថ្ងៃទី២០ ខែមីនា ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ តាមបំណែងចែកដូចខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ភេទ | រាជធានី-ខេត្ត |
|---|---|---|---|
| ១ | ប៉ែន សុផល | ប | រាជធានីភ្នំពេញ |
| ២ | ប៊ុន វណ្ណា | ស | រាជធានីភ្នំពេញ |
| ៣ | លឹម កិត្យា | ស | រាជធានីភ្នំពេញ |
| ៤ | ស្រាង ម៉េងលី | ប | រាជធានីភ្នំពេញ |
| ៥ | ប៉ាង ង៉ែត | ប | រាជធានីភ្នំពេញ |
| ៦ | កែវ ចន្ទ័សីហា | ប | កណ្តាល |
| ៧ | គួន សុខគា | ប | កណ្តាល |
| ៨ | ហេង ណារិន | ប | កណ្តាល |
| ៩ | វិត ដួងច័ន្ទ | ប | កណ្តាល |
| ១០ | ទឹម វន | ប | តាកែវ |
| ១១ | ឈុំ សារ៉ាត់ | ប | ព្រះសីហនុ |
| ១២ | អ៊ូ សុខឃី | ស | ត្បូងឃ្មុំ |
| ១៣ | ប៉ែន ឆោមឆារ៉ែត | ប | ត្បូងឃ្មុំ |
| ១៤ | សែម ម៉ាក់ | ប | កំពង់ចាម |
| ១៥ | ប៊ើល ប៊ុណ្ណារិទ្ធិ | ប | កំពង់ឆ្នាំង |



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ១៦ | អួន សេងទ្រី | ប | កំពង់ធំ |
| ១៧ | គី ចន្នី | ប | ឧត្តរមានជ័យ |
| ១៨ | សុខ ផល្លា | ប | ឧត្តរមានជ័យ |
| ១៩ | ហៀល វដ្ឋា | ប | បន្ទាយមានជ័យ |
| ២០ | ក្រូច ពុទ្ធី | ប | ស្វាយរៀង |
| ២១ | ចិន សំណាង | ប | ស្វាយរៀង |
| ២២ | ចៅ ឧស្សាហ៍ | ប | ស្វាយរៀង |
| ២៣ | ជិន សំអន | ប | ស្វាយរៀង |
| ២៤ | កុល ថាន | ប | ស្វាយរៀង |

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

"ដើម្បីជាព័ត៌មាន"

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ
លេខ ៤១៥ វជអ

## បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥
## កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្ដីផ្ដើម | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ | ថ្ងៃសៅរ៍ |
| ២ | រំលឹកទ្រឹស្ដី | ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ | ថ្ងៃសៅរ៍ |
| ៣ | វិធិសាស្ត្រស្រាវជ្រាវ | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៨ | ថ្ងៃសៅរ៍ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការពិភាក្សា | ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨ | ថ្ងៃសៅរ៍ |
| ៥ | សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ | ថ្ងៃសៅរ៍ |

កំណត់សម្គាល់:

- ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រត្តិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្តម្ភ នៅវិទ្យាស្ថានជាតិអប់រំ។
- នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ បទបង្ហាញសាកល្បងការពារការសរសេរនិក្ខេបបទ។
- នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ពិធីការពារការសរសេរនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រត្តិបត្តិនៃការបណ្ដុះ បណ្ដាលថ្នាក់ក្រោយឧត្តម្ភនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់នងគណៈកម្មការប្រត្តិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្តមសម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោកបណ្ឌិត នូវ វីរ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ e-mail: viraneau@hotmail.com និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំe-mail: chapratana@gmail.com ។

រាជធានីភ្នំពេញថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
វិទ្យាស្ថានជាតិអប់រំ

**សូមគោរពជូន**
**ឯកឧត្តមនាយក វិទ្យាស្ថានជាតិអប់រំ**

| | |
|---|---|
| អនុញ្ញាតឲ្យនិស្សិតឈ្មោះ៖ | **ទៅ ឧស្សាហ៍** |
| ប្រធានបទស្រាវជ្រាវ ៖ | ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ករណីសិក្សា ខេត្តស្វាយរៀង) |
| ដើម្បីចូលរួម ៖ | ការពារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ម៉ោង៧. ៣០នាទីព្រឹក |
| ទីកន្លែង ៖ | វិទ្យាស្ថានជាតិអប់រំ |

យើងខ្ញុំជាសាស្ត្រាចារ្យដឹកនាំ និងដឹកនាំរង ពិតជាបានអនុញ្ញាតឱ្យនិស្សិតមានឈ្មោះខាងលើបានចូលរួមការពារសារណា ដើម្បីបំពេញលក្ខខណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ឆ្នាំសិក្សា២០១៧-២០១៨ តាមការកំណត់របស់វិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃចន្ទ ៧រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

**សាស្ត្រាចារ្យដឹកនាំ**

**បណ្ឌិត សៀង សុវណ្ណា**

**សាស្ត្រាចារ្យដឹកនាំរង**

**លោក ចាប រតនា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១៦០៧ អយក.វិស៊ា

*ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១*
*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨*

**សូមគោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥

**យោង** ៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំឆ្នាំសិក្សា២០១៧-២០១៨

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំ សូមជម្រាបលោកប្រធានថា និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ ចំនួន២៨នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី២០ ខែមីនា ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូមលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
-សាលារាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
"ដើម្បីជាព័ត៌មាន និងសហការ"
-កាលប្បវត្តិ
-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :.................... វជអ.

# លិខិតអញ្ជើញ

**សូមគោរពអញ្ជើញ ៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ដើម្បីបំពេញក្របខ័ណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំឆ្នាំសិក្សា២០១៧ - ២០១៨ វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា

**កាលបរិច្ឆេទ** ៖ ថ្ងៃទីពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ០៧:៣០-១៧:០០
(មានភ្ជាប់ជូនកម្មវិធី)

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ H នៅជាន់ទី១។

ថ្ងៃទីសុក្រ ៣កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ**[illegible]**អយក.**[illegible]

## លិខិតឧទ្ទេសនាម

**យោង** ៖-បទបញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ និងទី៦ ឆ្នាំសិក្សា២០១៧-២០១៨ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា**គណៈកម្មការរៀបចំការប្រឡង** សម្រាប់ការការពារសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក | ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ វជអ | អនុប្រធាន |
| ៣-លោក | ឡេង បុរី | ប្រធានការិយាល័យ វជអ | សមាជិក |
| ៤-លោក | សៀង វាសនា | មន្ត្រីដេប៉ាតឺម៉ង់ វជអ | សមាជិក |
| ៥-លោក | ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ វជអ | សមាជិក |
| ៦-លោក | ម៉ន មុនិន្ទ | មន្ត្រីដេប៉ាតឺម៉ង់ វជអ | សមាជិក |
| ៧-លោក | លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ វជអ | សមាជិក |

ឯកឧត្តម អស់លោក ដូចមានរាយនាមខាងលើ ត្រូវរៀបចំសំណុំលិខិតផ្សេងៗនៃការការពារសារណាចាប់ពីថ្ងៃចេញលិខិតនេះរហូតដល់ថ្ងៃប្រគល់ទទួលផល។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៣១៧៦ **អយក.**ខប

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទបញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ និងទី៦ ឆ្នាំសិក្សា២០១៧-២០១៨ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការទទួលខុសត្រូវចម្រុះការពារសារណា** សម្រាប់ការការពារសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ៖

១-ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធាន
២-ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន
៣-ឯកឧត្តម លាង សេងហាក់ អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ៣ កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធ

# កម្រងសំណួរអំពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

## សូមគោរពជូន: គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ

ខ្ញុំបាទឈ្មោះ**ចៅ ឧស្សាហ៍** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមប្រធានបទ "**ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ**"។

អាស្រ័យហេតុនេះសូមលោក លោកស្រី មេត្តាជួយផ្តល់ចម្លើយចំពោះសំណួរខាងក្រោមដោយអនុគ្រោះ។ **<u>គ្រប់ចម្លើយរបស់លោក លោកស្រីនឹងត្រូវបានរក្សាជាសម្ងាត់</u>**។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក លោកស្រី។

**កម្រងសំណួរស្រាវជ្រាវចែកចេញជា៤ផ្នែកដូចខាងក្រោម៖**

- **ផ្នែកទី១-ព័ត៌មានអ្នកផ្តល់ចម្លើយ**
- **ផ្នែកទី២-ការយល់ដឹងពីឧម្រទ់ និងខ្លឹមសារនៃផែនការអភិវឌ្ឍន៍សាលារៀន**
- **ផ្នែកទី៣-ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន**
- **ផ្នែកទី៤-ដំណាក់កាលក្រោយរៀបចំផែនការអភិវឌ្ឍន៍សាលារៀន**

**<u>ផ្នែកទី១៖ ព័ត៌មានអ្នកផ្តល់ចម្លើយ</u>**

សូមគូសសញ្ញា( ✓ ) ក្នុងប្រអប់ និង ឆ្លើយសំណួរខាងក្រោម៖

1. **តួនាទីអ្នកឆ្លើយសំណួរជា៖**

| | |
|---|---|
| ☐ នាយកសាលា | ☐ នាយករង |
| ☐ មន្ត្រីរដ្ឋបាល គណនេយ្យ | ☐ ប្រធានផ្នែក/ការិយាល័យសិក្សា |
| ☐ ប្រធានក្រុបច្ចេកទេស | ☐ អនុប្រធានក្រុមបច្ចេកទេស |
| ☐ គ្រូបង្រៀន | ☐ ផ្សេងៗ………………………………………. |

2. ទីតាំងវិទ្យាល័យដែលអ្នកបម្រើការស្ថិតនៅស្រុក/ក្រុង

| | |
|---|---|
| ☐ ស្រុកស្វាយជ្រំ | ☐ ស្រុកកំពង់រោទ៍ |
| ☐ ស្រុកស្វាយទាប | ☐ ស្រុករមាសហែក |
| ☐ ស្រុកចន្ទ្រា | ☐ ស្រុករំដួល |
| ☐ ក្រុងស្វាយរៀង | ☐ ក្រុងបាវិត |

## <u>ផ្នែកទី២៖ ការយល់ដឹងពីឧម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀន</u>

3. តើសាលារៀនរបស់អ្នកមានរៀបចំផែនការអ្វីខ្លះ? (☞<u>អ្នកអាចជ្រើសរើសចម្លើយបានច្រើន</u>)

☐ ផែនការអភិវឌ្ឍន៍សាលារៀន

☐ ផែនការយុទ្ធសាស្ត្រ

☐ ផែនការថវិកា

☐ ផែនការសកម្មភាពប្រចាំឆ្នាំ

☐ ផ្សេងៗ………………………………………………………………………………………។

4. សម្រាប់ផែនការអភិវឌ្ឍន៍សាលារៀន កន្លងមកតើអ្នកមានបានចូលរួមក្នុងដំណើរការរៀបចំវាទេ?

☐ បានចូលរួម

☐ មិនបានចូលរួមទេ

5. តើអ្នកដឹងពីខ្លឹមសារ ឬ សកម្មភាពនានាដែលគ្រោងធ្វើនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀននេះបានកម្រិតណា?

| | | | | |
|---|---|---|---|---|
| ☐ មិនដឹងសោះ | ☐ ដឹងតិចតួច | ☐ មធ្យម | ☐ ច្រើន | ☐ ច្រើនណាស់ |

6. តើកន្លងមក អ្នកណាខ្លះជាអ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនអ្នក? (☞<u>អ្នកអាចជ្រើសរើសចម្លើយបានច្រើន -តាមជាក់ស្តែង</u>)

☐ នាយក

☐ នាយករង

☐ មន្ត្រីផ្នែករដ្ឋបាល/គណនេយ្យ

☐ ប្រធានក្រុមបច្ចេកទេស

- ☐ អនុប្រធានក្រុមបច្ចេកទេស
- ☐ គ្រូបង្រៀន
- ☐ សិស្សានុសិស្ស
- ☐ ក្រុមប្រឹក្សា ឬគណៈកម្មការនានារបស់សាលា
- ☐ មាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស
- ☐ ប្រជាពលរដ្ឋសហគមន៍
- ☐ អាជ្ញាធរមូលដ្ឋាន
- ☐ ផ្សេងៗ…………………………………………………………………………………….

## <u>ផ្នែកទី៣៖ ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន</u>

7. **តើសាលារៀនអ្នក រៀបចំផែនការអភិវឌ្ឍន៍សាលារៀនដោយរបៀបណា? (☞<u>ចម្លើយជ្រើសរើសបានតែមួយប៉ុណ្ណោះ</u>)**

- ☐ នាយកជាអ្នករៀបចំទាំងស្រុង
- ☐ នាយករងជាអ្នករៀបចំទាំងស្រុង
- ☐ រដ្ឋបាល/គណនេយ្យជាអ្នករៀបចំទាំងស្រុង
- ☐ គណៈគ្រប់គ្រងសាលា (នាយក-នាយករង) ជាអ្នករៀបចំ រួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀន
- ☐ រៀបចំដោយគណៈគ្រប់គ្រងសាលា និងមានការចូលរួមពីដោយគ្រូបង្រៀនមួយចំនួន
- ☐ ប្រជុំពិភាក្សាគ្នារវាងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនទាំងអស់
- ☐ រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស...)
- ☐ ចម្លងតាមការណែនាំពីថ្នាក់មន្ទីរ
- ☐ ការិយាល័យអប់រំស្រុកជាអ្នករៀបចំឱ្យ
- ☐ យកគំរូតាមវិទ្យាល័យផ្សេង
- ☐ យកលំនាំតាមផែនការឆ្នាំចាស់ដដែល
- ☐ (ចម្លើយផ្សេងទៀត-បើមាន)………………………………………………………………

8. តើសាលារៀនអ្នក ជួបប្រទះបញ្ហាប្រឈមសំខាន់ៗអ្វីខ្លះ? (☞**<u>សូមជ្រើសរើសចម្លើយ ០៣ ដែលអ្នកគិតថា ជាបញ្ហាប្រឈមសំខាន់បំផុតនៅក្នុងសាលារៀនលោក-អ្នក នាពេលបច្ចុប្បន្ននេះ</u>**)

- ☐ បញ្ហាបរិស្ថានសាលារៀនមិនល្អ
- ☐ គ្រឿងបរិក្ខារនៅក្នុងសាលារៀនមានការខូចខាត ត្រូវការសាងសង់ ឬជុសជុល (ខ្នាតតូច)
- ☐ សមត្ថភាពគ្រូបង្រៀនមួយចំនួននៅមានកម្រិតលើជំនាញមួយចំនួនដែលត្រូវការបណ្តុះបណ្តាល និងបំប៉នបន្ថែមដើម្បីអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈឱ្យកាន់តែប្រសើរឡើង
- ☐ កង្វះសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងការិយាល័យ
- ☐ កង្វះសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន
- ☐ កង្វះបង្គន់អនាម័យ និងទឹកស្អាត
- ☐ សិស្សមិនសូវយកចិត្តទុកដាក់សិក្សារៀនសូត្រ
- ☐ អត្រាសិស្សបោះបង់ និងរៀនត្រួតថ្នាក់ខ្ពស់
- ☐ បញ្ហាផ្សេងៗទៀត បើមាន…………………………………………………………………………….

9. **តើផែនការអភិវឌ្ឍន៍សាលារៀនរបស់អ្នក ផ្តោតទៅលើអ្វីខ្លះ?** (☞<u>អ្នកអាចជ្រើសរើសចម្លើយបានច្រើន-តាមជាក់ស្តែង</u>)

- ☐ ផ្តោតតែទៅលើការកែលម្អបរិស្ថានសាលា
- ☐ ការសាងសង់ ឬជុសជុល ខ្នាតតូច
- ☐ សកម្មភាពគាំទ្រ និងអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន (ឧ. គាំទ្រសកម្មភាពប្រជុំក្រុមបច្ចេកទេស ប្រជុំគរុកោសល្យ គាំទ្រការសិក្សាបន្ត ឬវគ្គសិក្សានានាដល់គ្រូបង្រៀន...)
- ☐ ទិញសម្ភាររូវន្តប្រើប្រាស់ការិយាល័យ
- ☐ ទិញសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន
- ☐ រៀបចំផែនការផ្តោតតែសកម្មភាពទាំងឡាយណាដែលគណៈគ្រប់គ្រងសាលាបានស្នើឡើង
- ☐ សកម្មភាពទាំងឡាយណាដែលគ្រូបង្រៀនបានស្នើឡើង
- ☐ សកម្មភាពទាំងឡាយណាដែលសិស្សានុសិស្សបានស្នើឡើង
- ☐ (ចម្លើយផ្សេងៗទៀត-បើមាន)……………………………………………………………………

10. តើអ្នកពេញចិត្តនឹងផែនការអភិវឌ្ឍន៍សាលារៀនដែលបានបង្កើតឡើងនោះកម្រិតណា?

| | | | | |
|---|---|---|---|---|
| ☐ មិនពេញចិត្តសោះ | ☐ តិចតួច | ☐ មធ្យម | ☐ ខ្លាំង | ☐ ខ្លាំងណាស់ |

11. តើហេតុអ្វីអ្នកជ្រើសរើសកម្រិតពេញចិត្តខាងលើនេះ? (☞ សូមសរសេរចម្លើយផ្ទាល់របស់អ្នក)

…………………………………………………………………………………………………………….

…………………………………………………………………………………………………………….

## ផ្នែកទី៤-ដំណាក់កាលក្រោយរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

12. តាមបទពិសោធន៍កន្លង តើផែនការអភិវឌ្ឍន៍សាលារៀនដែលបានដាក់ចេញអាចយកទៅអនុវត្តបានកម្រិតណា?

| | | | | |
|---|---|---|---|---|
| ☐ មិនបានសោះ | ☐ បានតិចតួច | ☐ មធ្យម | ☐ ច្រើន | ☐ ច្រើនណាស់ |

13. តើរយៈពេល៥ឆ្នាំកន្លងមកនេះ លទ្ធផលនៃការអនុវត្តផែនការទាំងនោះ អ្នកពេញចិត្តកម្រិតណា?

| | | | | |
|---|---|---|---|---|
| ☐ មិនពេញចិត្តសោះ | ☐ តិចតួច | ☐ មធ្យម | ☐ ខ្លាំង | ☐ ខ្លាំងណាស់ |

14. តើហេតុអ្វីអ្នកជ្រើសរើសកម្រិតពេញចិត្តខាងលើនេះ? (☞ សូមសរសេរចម្លើយផ្ទាល់របស់អ្នក)

……………………………………………………………………………………………………………

……………………………………………………………………………………………………………

15. តើមានការលំបាកអ្វីខ្លះ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនអ្នក? (☞ អ្នកអាចជ្រើសរើសចម្លើយបានច្រើន)

- ☐ សកម្មភាពដែលសាលាស្នើឡើងហើយតែមន្ទីរមិនគាំទ្រ
- ☐ ដំណើរការរៀបចំ មិនទាន់មានការចូលរួមទូលំទូលាយពីអ្នកពាក់ព័ន្ធនៅឡើយ
- ☐ ថវិកាដែលរដ្ឋទម្លាក់នៅមានចំនួនតិចតួចនៅឡើយ
- ☐ គ្រោងសកម្មភាពដដែលៗដូចផែនការឆ្នាំចាស់ មិនមានដាក់បញ្ចូលសកម្មភាពថ្មី
- ☐ គ្រោងសកម្មភាពមិនទាន់ឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សាលា

☐ ទម្រង់ឯកសារផែនការដែលត្រូវបំពេញមានការលក្ខណៈស្មុគស្មាញ

☐ កង្វះធនធានមនុស្សដែលមានសមត្ថភាពដើម្បីរៀបចំផែនការប្រកបដោយប្រសិទ្ធភាព

☐ ការផ្សព្វផ្សាយឱ្យដល់គ្រូបង្រៀនទាំងអស់ និងអ្នកពាក់ព័ន្ធពីផែនការមិនទាន់ទូលំទូលាយ

☐ (ចម្លើយផ្សេងៗទៀត-បើមាន)…………………………………………………………………………។

**16. តើថវិកាដែលសាលាអ្នកទទួលបានពីរដ្ឋ ឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់អ្នកដែរឬអត់?**

☐ ឆ្លើយតប ☐ មិនឆ្លើយតប ☐ មិនដឹង

**☞ បើមិនឆ្លើយតប តើអ្នកមានដោះស្រាយយ៉ាងដូចម្តេច? (☞ អ្នកអាចជ្រើសរើសចម្លើយបានច្រើន)**

☐ ទុកសកម្មភាពទាំងនោះដាក់ចូលផែនការសម្រាប់ អនុវត្តឆ្នាំក្រោយៗទៀត

☐ កំណត់អាទិភាពសកម្មភាពដោយយកតែសកម្មភាពណាដែលចាំបាច់ត្រូវដោះស្រាយបន្ទាន់

☐ កៀរគរថវិកាពីប្រភពផ្សេងៗដើម្បីដោះស្រាយ

☐ កាត់តម្រឹមថវិកាសកម្មភាពនីមួយៗឱ្យឆ្លើយតបទៅនឹងចំនួនថវិកាដែលរដ្ឋផ្តល់ឱ្យ

☐ (ចម្លើយផ្សេងទៀត-បើមាន)…………………………………………………………………………..

**17. តើបន្ទាប់រៀបចំផែនការអភិវឌ្ឍន៍សាលារៀន មានការប្រជុំផ្សព្វផ្សាយបង្ហាញខ្លឹមសារ និងសកម្មភាពដែលគ្រោងអនុវត្ត នៅក្នុងផែនការនេះដល់លោកគ្រូ-អ្នកគ្រូ និងអ្នកពាក់ព័ន្ធនានាដែរឬទេ?**

| | | | | |
|---|---|---|---|---|
| ☐ មិនដែលផ្សព្វផ្សាយសោះ | ☐ បានតិចតួច | ☐ មធ្យម | ☐ ច្រើន | ☐ ច្រើនណាស់ |

**18. តើអ្នកមានសំណូមអ្វីខ្លះ ដើម្បីឱ្យការរៀបចំផែនការសាលារៀនរបស់អ្នកបានល្អប្រសើរ?**

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

**មតិយោបល់ផ្សេងទៀត-បើមាន**

………………………………………………………………………………………………………

………………………………………………………………………………………………………

(អរគុណចំពោះចម្លើយរបស់អ្នក)

**វិទ្យាស្ថានជាតិអប់រំ**

**National Institute of Education**

# "ស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ"

## តំបន់សិក្សាស្រាវជ្រាវ

**ខេត្តស្វាយរៀង**


**សាស្ត្រាចារ្យណែនាំ** ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

**សាស្ត្រាចារ្យជំនួយណែនាំ** លោក ឌី បណ្ណា

បេក្ខជន: ចៅ ឧស្សាហ៍

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ ជំនាន់ទី៥

# ខ្លឹមសារបទបង្ហាញ

១. គោលបំណងនៃការស្រាវជ្រាវ

២. សំណួរស្រាវជ្រាវ

៣. វិធីសាស្ត្រស្រាវជ្រាវ

៤. លទ្ធផលនៃការស្រាវជ្រាវ

៥. សេចក្តីសន្និដ្ឋាន

៦. សំណូមពរ

# ១-គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដើម្បី៖

- សិក្សាពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- ស្វែងរកយុទ្ធសាស្ត្រដែលអាចដោះស្រាយបញ្ហាប្រឈមទាំងនោះ
- ធ្វើសន្និដ្ឋាន និងផ្តល់អនុសាសន៍ដល់ស្ថាប័នពាក់ព័ន្ធពីរបៀបជំនះបញ្ហាប្រឈមទាំងនោះ និងអភិវឌ្ឍន៍វិទ្យាល័យប្រកបដោយប្រសិទ្ធភាព និងគុណភាព

# ២-សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើសំណួរស្រាវជ្រាវចំនួន ០២បានលើកឡើង៖

- តើស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង មានលក្ខណៈយ៉ាងដូចម្តេច និងជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?
- តើមានអនុសាសន៍អ្វីខ្លះ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?

# ៣-វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការជ្រើសរើសសំណាក

- ប្រើប្រាស់រូបមន្ត **Slovin** ក្នុងការគណនារកចំនួនសំណាកក្នុងកម្រិតជាក់លាក់៩៥%

$$n=N / (1+N e^2)$$

ចំនួនសំណាក=ចំនួនប្រជាករ ÷ (១+ចំនួនប្រជាករ x កម្រិតលម្អៀង²)

(ចំនួនប្រជាករ) បុគ្គលិកអប់រំទាំងអស់ដែលកំពុងបម្រើការនៅតាមវិទ្យាល័យក្នុងខេត្តស្វាយរៀង=១៣៨១នាក់

☛ ដូច្នេះ ចំនួនសំណាកដែលបានជ្រើសរើស៣១១

# ចំនួនសំណាក




- ចំនួនសំណាកប្រគល់ជូនអ្នកចូលរួមចំនួន ៣៤០ច្បាប់
- ប្រគល់ត្រឡប់មកវិញបាន ៣១១ច្បាប់
- បាត់បង់អស់២៩ ច្បាប់ ស្មើនឹង ៨.៥%



18
5.79%
8
2.57%
56
18%
229
73.63%
311
100%
គណៈគ្រប់គ្រង
មន្ត្រីរដ្ឋបាល/គណនេយ្យ
ថ្នាក់ដឹកនាំក្រុមបច្ចេកទេស
គ្រូបង្រៀន
សរុប

| ល.រ | ឈ្មោះស្រុក/ក្រុង | #វិទ្យាល័យ | #គ្រូបង្រៀន | ភាគរយ | #សំណាក | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រុងស្វាយរៀង | ២ | ២២៥ | ១៦.២៩% | ៥៩ | ១៩.០% |
| ២ | ស្រុកស្វាយជ្រំ | ៤ | ២៩៨ | ២១.៥៨% | ៥៨ | ១៨.៦% |
| ៣ | ស្រុកស្វាយទាប | ២ | ១៥២ | ១១.០១% | ៣១ | ១០% |
| ៤ | ស្រុករមាសហែក | ៣ | ២០១ | ១៤.៥៥% | ៣៤ | ១០.៩% |
| ៥ | ស្រុកកំពង់រោទ៍ | ២ | ១៥១ | ១០.៩៣% | ៤០ | ១២.៩% |
| ៦ | ស្រុករំដួល | ៣ | ២០៧ | ១៤.៩៩% | ៣០ | ៩.៦% |
| ៧ | ស្រុកចន្ទ្រា | ១ | ២៩ | ២.១០% | ១៩ | ៦.១% |
| ៨ | ក្រុងបាវិត | ២ | ១១៨ | ៨.៥៤% | ៤០ | ១២.៩% |
| សរុប | | ១៩ | ១៣៨១ | ១០០% | ៣១១ | ១០០% |

- សមាសភាពគម្រូជ្រើសរើស៖ ថ្នាក់ដឹកនាំសាលារៀន (នាយក/នាយិកា និងនាយករង/នាយិការង) មន្ត្រីរដ្ឋបាល/គណនេយ្យ ថ្នាក់ដឹកនាំក្រុមបច្ចេកទេស (ប្រធាន និងអនុប្រធានក្រុម) និងគ្រូបង្រៀន
- វិធីសាស្ត្រជ្រើសរើស៖ ដោយចៃដន្យ

## ៣.២. ឧបករណ៍ស្រាវជ្រាវ

- ឧបករណ៍ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យគឺកម្រងសំណួរ
- ប្រើប្រាស់កម្រងសំណួរតែមួយប្រភេទសម្រាប់អ្នកចូលរួមទាំងអស់
- កម្រងសំណួរមាន៤ផ្នែកគឺ៖ (១) ព័ត៌មានផ្ទាល់ខ្លួន (២) ការយល់ដឹងពីទម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀន (៣) ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និង(៤) ដំណាក់កាលក្រោយការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

- ប្រភេទសំណួរមាន២ទម្រង់៖ ទម្រង់បើក និងទម្រង់បិទ
- ការសាកល្បង និងកែសម្រួលកម្រងសំណួរ

## ៣.៣. នីតិវិធី និងដំណើរការប្រមូលទិន្នន័យ

- បង្ហាញពីក្រមសីលធម៌នៃការស្រាវជ្រាវ
- ការពន្យល់ណែនាំពីរបៀបនៃការបំពេញកម្រងសំណួរ
- ការបំពេញកម្រងសំណួររបស់ក្រុមគោលដៅរយៈពេល១៥ទៅ២០នាទី
- ការធ្វើសម្ភាសន៍ជាមួយថ្នាក់ដឹកនាំសាលា និងថ្នាក់ដឹកនាំក្រុមបច្ចេកទេសជាបុគ្គល

# ៣.៤. ការវិភាគទិន្នន័យ

- ការវិភាគបែបបរិមាណ និងគុណភាព
- ប្រើប្រាស់កម្មវិធី Ms Excel និង SPSS
- ប្រើប្រាស់វិធីសាស្រ្តរៀបចំទិន្នន័យជា បំណែងចែកប្រេកង់ ដ្យាក្រាម តារាង ភាគរយ និងរៀបចំជាចំណាត់ថ្នាក់ចម្លើយ

# ៤-លទ្ធផលនៃការស្រាវជ្រាវ

## ៤.១-ការយល់ដឹងពីទម្រង់ និងខ្លឹមសារផែនការអភិវឌ្ឍន៍សាលារៀន

### ក-ការយល់ដឹងពីផែនការនានារបស់សាលារៀន




ផែនការអភិវឌ្ឍន៍សាលារៀនមានការយល់ដឹងខ្ពស់ជាងគេ ដោយសារ៖

- ត្រូវបានរៀបចំ និងអនុវត្តជារៀងរាល់ឆ្នាំ ដោយប្រើប្រាស់ថវិកាដែលរដ្ឋទម្លាក់ឱ្យ និងថវិកាពីប្រភពផ្សេងទៀត

# ខ-ការយល់ដឹងពីផែនការអភិវឌ្ឍន៍សាលារៀន




**ការយល់ដឹងកម្រិតមធ្យមដោយសារៈ**

- មិនបានចូលរួមក្នុងដំណើរការរៀបចំដោយផ្ទាល់
- ការផ្សព្វផ្សាយក៏នៅមិនទាន់អនុវត្តបានទូលំទូលាយនៅឡើយ។

# ការយល់ដឹងពីផែនការអភិវឌ្ឍន៍សាលារៀនបែងចែកតាមតួនាទី






**មន្ត្រីរដ្ឋបាល/គណនេយ្យ មានកម្រិតយល់ដឹងខ្ពស់ជាងគេដោយសារៈ**

- មន្ត្រីទាំងនេះបានចូលរួមដោយផ្ទាល់ក្នុងដំណើរការរៀបចំផែនការ ការអនុវត្តផែនការ ការរៀបចំជម្រះបញ្ជីស្នាមផ្សេងៗ និងការរៀបចំប្រជុំផ្សព្វផ្សាយ

# គ-អ្នកចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន




ការចូលរួមពិគ្រោះយោបល់ក្នុងចំណោម-មអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន នៅមិនទាន់អនុវត្តបានទូលំទូលាយនៅឡើយ

# ៤.២. ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

## ក-របៀបរៀបចំផែនការអភិវឌ្ឍន៍សាលារៀន




ទិន្នន័យបង្ហាញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍន៍និងកែលម្អសាលារៀន ដោយសារៈ

- ❑ ការរៀបចំមិនមានការចូលរួមទូលំទូលាយប្រកបដោយតម្លាភាព គណនេយ្យភាព ដែលនាំឱ្យកង្វះការគាំទ្រ និងមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់អ្នកពាក់ព័ន្ធដទៃទៀត

# ខ-បញ្ហាប្រឈមសំខាន់ដែលសាលារៀនជួបប្រទះ




- ❑ បញ្ហាប្រឈមសិស្សមិនសូវយកចិត្តទុកដាក់សិក្សាសូត្រជាអាទិភាពបំផុតទីពីរតែដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនមិនបានផ្តល់ឱកាសដល់សិស្សានុសិស្ស ឬតំណាងក្រុមចូលរួមក្នុងពិគ្រោះយោបល់នោះទេ!

# គ-សកម្មភាពសំខាន់ៗដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន




- ❑ បញ្ហាប្រឈម និងដំណោះស្រាយមិនស៊ីសង្វាក់គ្នា
- ❑ បញ្ហាបរិស្ថានសាលារៀនមិនត្រូវបានចាត់ទុកថា ជាបញ្ហាប្រឈមជាអាទិភាពនោះទេ
- ❑ សកម្មភាពគ្រោងឡើងរៀបចំឡើងដើម្បីងាយស្រួលក្នុងការកិបកេង និងក្លែងបន្លំ
- ❑ សកម្មភាពគាំទ្រការអភិវឌ្ឍសមត្ថភាពគ្រូ ផ្តោតតែទៅលើការប្រជុំក្រុមបច្ចេកទេស

# យ-កម្រិតនៃភាពពេញចិត្តចំពោះផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំ




អ្នកចូលរួមបង្ហាញពីការពេញចិត្តដោយសារ៖

- សារៈសំខាន់នៃផែនការចំពោះការអភិវឌ្ឍសាលារៀន
- មានផែនការប្រសើរជាងមិនមាន
- បញ្ហាប្រឈមត្រូវបានដោះស្រាយបណ្តើរៗ

## ៤.៣. ដំណាក់កាលក្រោយការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

20

### ក-កម្រិតនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន




- ❑ កង្វះការចូលរួមរៀបចំផែនការ ការអនុវត្ត និងតាមដានត្រួតពិនិត្យ វាយតម្លៃពីសំណាក់អ្នកពាក់ព័ន្ធនានា
- ❑ កង្វះការផ្សព្វផ្សាយឱ្យបានទូលំទូលាយប្រកបដោយតម្លាភាព ដែលនាំឱ្យកង្វះការគាំទ្រ និងភាពជឿទុកចិត្តលើការអនុវត្ត និងទៅលើលទ្ធផល
- ❑ ការទម្លាក់កំហុសទៅលើការទម្លាក់ថវិកាយឺត

# ខ-កម្រិតនៃភាពពេញចិត្តចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនក្នុងរយៈពេល៥ឆ្នាំចុងក្រោយ




- ❑ លទ្ធផលមួយចំនួនមិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន
- ❑ មិនបានផ្សព្វផ្សាយលទ្ធផលចំណូល និងចំណាយ ឱ្យទូលំទូលាយ
- ❑ ការប្រើប្រាស់ថវិកាមិនមានតម្លាភាព
- ❑ ការបែកបាក់សាមគ្គីភាពផ្ទៃក្នុង

# គ-ការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន




- ការចូលរួមរៀបចំ និងការផ្សព្វផ្សាយមិនទាន់ទូលំទូលាយ
- កញ្ចប់ថវិកាតិចតួចនៅឡើយ
- ការទាញយកផលប្រយោជន៍តាមរយៈនៃការប្រព្រឹត្តអំពើពុករលួយ
- ការចម្លងគម្រូផែនការដែលមានស្រាប់

# ឃ-ថវិកាអភិវឌ្ឍន៍ តម្រូវការជាក់ស្តែង និងដំណោះស្រាយ




- ❑ អ្នកចូលរួម៩0% ឆ្លើយថា ថវិកាដែលរដ្ឋទម្លាក់ឱ្យសាលារៀន មិនឆ្លើយតបទៅនឹងតម្រូវការ។

# ដំណោះស្រាយ






- ការកំណត់អាទិភាពលើបញ្ហាប្រឈមដែលចាំបាច់ត្រូវដោះស្រាយបន្ទាន់ ព្រមទាំងធ្វើការកៀរគថវិកាពីប្រភពផ្សេងៗទៀតដើម្បីបំពេញថវិកាដែលខ្វះខាត និងតម្រូវការចាំបាច់។
- អ្នកចូលរួមចំនួនជាងពាក់កណ្ដាលផងដែរ ដែលមិនបានបង្ហាញពីដំណោះស្រាយសមស្របក្នុងការដោះស្រាយបញ្ហាចំពោះមុខ ពោលគឺទុកបញ្ហាទាំងនោះចោល ដោយរង់ចាំថវិកាទម្លាក់ឆ្នាំក្រោយៗ

## ង-កម្រិតនៃការប្រជុំផ្សព្វផ្សាយពីផែនការអភិវឌ្ឍន៍សាលារៀនដែលរៀបចំរួចដល់អ្នកពាក់ព័ន្ធ






ផ្អែកតាមទិន្នន័យបង្ហាញថា ការផ្សព្វផ្សាយ មិនទាន់អនុវត្តបានល្អប្រសើរនៅឡើយដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត

# ៥-សន្និដ្ឋាន

ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន មិនត្រូវបានរៀបចំស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយភាគច្រើនត្រូវបានរៀបចំឡើងដោយមិនមានតម្លាភាព គណនេយ្យភាព និងការចូលរួមទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ។ ជាទូទៅ ផែនការអភិវឌ្ឍន៍សាលារៀន៩០%ត្រូវបានរៀបចំដោយភាគីមួយចំនួនតូចតែប៉ុណ្ណោះ មិនបានឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់អ្នកពាក់ព័ន្ធដទៃទៀត ដែលវាធ្វើឱ្យកង្វះការគាំទ្រ កិច្ចសហការពីអ្នកពាក់ព័ន្ធនានា ការយល់ដឹងនៅមានកម្រិត និងធ្វើឱ្យការអនុវត្តមិនបានសម្រេចជោគជ័យពេញលេញ ពិសេសវាជាមូលហេតុចម្បងដែលធ្វើឱ្យបែកបាក់សាមគ្គីភាពផ្ទៃក្នុង និងការកើនឡើងនូវទំនាស់ផលប្រយោជន៍។ កត្តាទាំងនេះ ជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ដំណើរការអភិវឌ្ឍន៍ និងកែលម្អសាលារៀន។

# ៦.សំណូមពរ

សំណូមពរទាំងនេះមានដូចជាៈ

១. ផ្នាក់ដឹកនាំវិទ្យាល័យគួរតែផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងអនុវត្តឱ្យបានពេញលេញទៅតាមនីតិវិធីដែលក្រសួងបានកំណត់

២. ថ្នាក់ដឹកនាំវិទ្យាល័យគួរតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន ការអនុវត្ត និងលទ្ធផលសម្រេចបានដល់អ្នកពាក់ព័ន្ធទាំងអស់

៣. សាលារៀនគួរតែពង្រឹងតួនាទី និងភារកិច្ចគណៈកម្មការដែលមានស្រាប់ដើម្បីចូលរួមចំណែកធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការដែលបានគ្រោងឡើង

៤. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងក្រុមតាមដានត្រួតពិនិត្យ និងបណ្តុះបណ្តាលថ្នាក់ស្រុក DT MTគួរតែចូលរួមតាមដានត្រួតពិនិត្យពីដំណើរការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនឱ្យបានច្បាស់លាស់

៥. មន្ទីរអប់រំ យុវជន និងកីឡាខេត្តគួរតែផ្តល់វគ្គបំប៉នសមត្ថភាពបន្ថែមពីនីតិវិធីក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន

៦. ក្រសួងអប់រំ យុវជន និងកីឡាគួរតែបង្កើនកញ្ចប់ថវិកាទម្លាក់ដល់វិទ្យាល័យបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងបង្កើតយន្តការតាមដានត្រួតពិនិត្យឱ្យបានច្បាស់លាស់លើការអនុវត្តផែនការ និងការប្រើប្រាស់ថវិកា

៧. ក្រសួងអប់រំ យុវជន និងកីឡាគួរតែទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា ដើម្បីឱ្យវិទ្យាល័យអនុវត្តសកម្មភាពបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព

៨. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ពីលទ្ធផលសម្រេចបានពីការអនុវត្តសកម្មភាព ដោយធ្វើការសិក្សាប្រៀបធៀបនឹងសូចនាករដែលមាននៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដែលបានរៀបចំនៅតាមវិទ្យាល័យគោលដៅនីមួយៗ

៩. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត និងសិក្សាស្រាវជ្រាវនៅខេត្តផ្សេងទៀត។